
ទឹកភ្នែក
ពណ៌ស

**ផ្តួចផ្តើមគំនិតចងក្រងសៀវភៅ**
សេង រាសី
ខាត់ ស្រីនិច

**អ្នកសិក្សាស្រាវជ្រាវ**
ខាត់ ស្រីនិច
ពៅ ចាន់ស្រីលក្ខ

**អ្នកថតរូប**
ព្រីង ឃុន
ពៅ ចាន់ស្រីលក្ខ
អង្គការដៃគូ

**អ្នកកែសម្រួលអក្ខរាវិរុទ្ធ**
ម៉ក់ សិរីរ័ត្ន
ពៅ ចាន់ស្រីលក្ខ

**អង្គការសីលការ**
#៣៧BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
+៨៥៥ ២៣ ២៧១ ៨៧២/ +៨៥៥ ១២ ៧៩២ ៣៧៩

**បោះពុម្ពលើកទី១ ខែធ្នូ ឆ្នាំ២០២៣**
**បោះពុម្ពលើកទី២ ខែមីនា ឆ្នាំ២០២៥**

BY NC SA

# មាតិកា


អារម្ភកថា.........................................................................៥
សាច់រឿងទី១.......................................................................៧
សាច់រឿងទី២ .....................................................................១១
សាច់រឿងទី៣ .....................................................................១៨
សាច់រឿងទី៤.......................................................................២៦
ការធ្វើបច្ចុប្បន្នភាព ស្ថានភាពរបស់ ..............................................៣០
ក្រុមស្ត្រីជាកម្មករនៅក្រុមហ៊ុនចំការចេក និងកៅស៊ូ

សាច់រឿងទី៥.......................................................................៣៨
សាច់រឿងទី៦.......................................................................៤៤
សាច់រឿងទី៧ .....................................................................៤៤
សាច់រឿងទី៨.......................................................................៤៩
ការធ្វើបច្ចុប្បន្នភាព ស្ថានភាពរបស់ ..............................................៥៨
ក្រុមស្ត្រីផលិតកៅស៊ូជាលក្ខណៈគ្រួសារ

សាច់រឿងទី៩.......................................................................៦២
សាច់រឿងទី១០ ...................................................................៦៨
សាច់រឿងទី១១ ...................................................................៧៤
សាច់រឿងទី១២...................................................................៧៨
ការធ្វើបច្ចុប្បន្នភាព ស្ថានភាពរបស់ ..............................................៨២
ក្រុមស្ត្រីអភិរក្សធនធានធម្មជាតិ

ដំណើរការ នៃការចងក្រងសាច់រឿងរបស់ក្រុមស្ត្រី..........................៨៦

*ទឹកភ្នែកពណ៌ស*

# អារម្ភកថា

សៀវភៅ “ទឹកភ្នែកព័ណ៌ស” បានផលិតឡើងនៅឆ្នាំ២០២៣ ជាលើកទី១។ សៀវភៅនេះ ជាការសហការចងក្រង រវាងក្រុមស្ត្រីដែលជាម្ចាស់សាច់រឿង និងអង្គការសីលការ ដើម្បីរៀបចំកម្រងសាច់រឿងដែល ឆ្លុះបញ្ចាំងអំពីស្ថានភាពពិតរបស់ស្ត្រីចំនួន ១២នាក់ ដែលរួមមាន ស្ត្រីជាអ្នកផលិតកៅស៊ូជាលក្ខណៈគ្រួសារនៅក្នុងខេត្តត្បូងឃ្មុំ ស្ត្រីជាកម្មករនៅក្នុងចំការចេក និងកៅស៊ូនៅក្នុងខេត្តក្រចេះ និងស្ត្រីជាអ្នកអភិរក្សធនធានធម្មជាតិនៅក្នុងខេត្តរតនគីរី។ នៅក្នុងសាច់រឿងនីមួយៗ បានធ្វើអោយយើងឃើញពីភាពលំបាក ការតស៊ូ ភាពអត់ធ្មត់ ការរើសអើង ផ្នត់គំនិតសង្គម និងតម្រូវការ ព្រមជាមួយដំណោះស្រាយពីអ្នកពាក់ព័ន្ធ ដែលធ្វើអោយជីវិតរបស់ពួកគាត់ និងសហគមន៍ ទទួលបានការគោរព មានសមភាពយេនឌ័រ និងកន្លែងការងារមានសុវត្ថិភាព និងមានការការពារ។ តាមរយៈភស្តុតាងមួយនេះ រួមផ្សំហ្នឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់ក្រុមស្ត្រី បានធ្វើអោយកម្រងសាច់រឿងក្រុមស្ត្រីក្លាយទៅជាទីចាប់អារម្មណ៍ ពីតំណាងអ្នកពាក់ព័ន្ធ ទាំងស្ថាប័នរដ្ឋ ឯកជន សារពត័មាន និងអង្គការសង្គមស៊ីវិល រហូតធ្វើអោយស្ថានភាពមួយចំនួន ត្រូវផ្លាស់ប្តូរជាវិជ្ជមាន។

ចាប់តាំងពីសៀវភៅទឹកភ្នែកពណ៌ស ផលិតឡើង ក្រុមស្ត្រី និងក្រុមការងារអង្គការសីលការនៅតែបន្តជួបពិភាក្សាគ្នាដើម្បីធ្វើបច្ចុប្បន្នភាពលើបញ្ហា និងតម្រូវការរបស់ក្រុមស្ត្រី។ រយៈពេល ២ឆ្នាំមកនេះ ក្រុមស្ត្រីមានឱកាសជួបដោយផ្ទាល់ជាមួយអ្នកធ្វើគោលនយោបាយ និងស្ថាប័នពាក់ពន្ធ័ផ្សេងៗ ដើម្បីបន្តបន្លឺសំលេងស្ត្រី និងស្វែងរកដំណោះស្រាយ។ យើងទាំងអស់គ្នាមានសេចក្តីសោមនស្សរីករាយជាមួយវឌ្ឍនភាពក៏ដូចជាការឆ្លើយតបជាវិជ្ជមានចំពោះសំណើររបស់ក្រុមស្ត្រី។ ក្រោមកិច្ចពិភាក្សាយ៉ាងល្អិតល្អន់ និងពេញលេញរវាងក្រុមស្ត្រី និងអង្គការសីលការ យើងទាំងអស់គ្នាសម្រេចចិត្តបោះពុម្ពផ្សាយ សៀវភៅទឹកភ្នែកពណ៌ស ជាលើកទី២ ដោយបញ្ចូលបន្ថែមនូវបច្ចុប្បន្នភាពនៃការឆ្លើយតបរបស់អ្នកពាក់ពន្ធ័ និងភាពជាអ្នកដឹកនាំរបស់ក្រុមស្ត្រី។

យើងខ្ញុំសង្ឃឹមថា លោកអ្នកអាន នៅតែទទឹងចង់អាន និងគាំទ្រដល់កិច្ចការងារស្វែងរកការគាំទ្ររបស់ក្រុមស្ត្រី។ យើងខ្ញុំក៏សង្ឃឹមដែរថា សៀវភៅនេះ ហ្នឹងក្លាយជាភស្តុតាងរស់មួយដែលអ្នកអាន អាចយកទៅសិក្សាបន្ត និងបន្តរួមគ្នាស្វែងរកដំណោស្រាយជូនក្រុមស្ត្រី។ យើងខ្ញុំក៏សូមថ្លែងអំណរគុណាយ៉ាងជ្រាលជ្រៅដល់ម្ចាស់ជំនួយ អង្គការអ៊ុកស្វាមកម្ពុជា ដែលបានជួយជ្រុមជ្រែងឧបត្ថមលើការផលិតសៀវភៅ ក៏ដូចជាការអនុវត្តគម្រោង បរិយាបន្នខ្សែច្រវាក់តម្លៃកសិកម្ម_Fair4All។



"ពួកខ្ញុំធ្វើការនៅចំការចេកគឺពិបាកត្រង់ថានៅពេលដែលយើង ឈឺអីល្មមៗ អីនោះ គេមិន
ខ្វល់ថាយើងឈឺអីនោះទេ គេចង់តែបង្ខំអោយយើង ធ្វើទាំងឈឺនោះឯង។
ដូចយើងប្រាប់គេថាឈឺអីអញ្ចឹង យើងសុំបានត្រឹមតែមួយថ្ងៃ ទៅ២ថ្ងៃទេបើសម្រាកយូរ
ពេក គេដកយើងចេញ ដូចជាករណីប្តីរបស់ខ្ញុំអញ្ចឹង។ ចំពោះការចង់ឈប់សម្រាកកម្មករ
អាចសុំឈប់សម្រាកនៅរាល់កន្លះខែ បាន១ថ្ងៃ រឺច្រើន២ថ្ងៃ បន្ទាប់ពីបើកប្រាក់ឈ្នួល"

**សម្រង់សម្តីពីសាច់រឿងទី១**



# សាច់រឿងទី១

## បងស្រីជាកម្មករនៅក្រុមហ៊ុនចំការកៅស៊ូ

បងស្រីជាកម្មករដែលធ្វើការនៅក្នុង ក្រុមហ៊ុនចំការកៅស៊ូមួយកន្លែង។ បងស្រីបានចាកចេញពីផ្ទះទាំងគ្រួសារដើម្បីមករកការងារធ្វើនៅចំការនេះ ប្រមាណជា ៥ទៅ៦ឆ្នាំមកហើយ នៅក្នុងគ្រួសាររបស់បងស្រីមានសមាជិក៥នាក់ ដោយរួមមាន ប្តី កូនប្រុសច្បងអាយុ១៩ឆ្នាំ កូនប្រុសកណ្តាលអាយុ ១៧ឆ្នាំ និងកូនស្រីពៅអាយុ១០ឆ្នាំ។ បងស្រីបានប្រាប់ថា *"កូនប្រុសរបស់ខ្ញុំទាំងពីរមិនបានរៀនច្រើននោះទេ ពួកគេបានរៀនខ្លះៗកាលពីតូចនៅឯស្រុកកំណើត។ ដល់ពេលពួកគេ មានអាយុប្រមាណជា១២ទៅ១៣ឆ្នាំ ក៏បានឈប់រៀនហើយមកធ្វើការងារជាមួយខ្ញុំ តាំងពីពេល នោះមក។ ចំណែកកូនស្រីពៅ នាងទើបតែរៀនបានថ្នាក់ទី១ប៉ុណ្ណោះ ដោយសារសាលានៅឆ្ងាយពីកន្លែងធ្វើការ ដូចច្នេះខ្ញុំ ឬក៏ប្តីខ្ញុំត្រូវចំណាយពេលដើម្បី ជូនកូនស្រីទៅមកជារៀងរាល់ថ្ងៃ"*។ នៅក្នុងគ្រួសាររបស់បងស្រីសព្វថ្ងៃមនុស្សដែលអាចធ្វើការបានមានគ្នាទៅដល់០៤នាក់ តែដោយសារមានការចំណាយច្រើនទៅលើ ការហូបចុក និងធ្វើដំណើរជាប្រចាំថ្ងៃ ធ្វើអោយគ្រួសារលោកស្រីមិនបានសល់លុយកាក់អ្វីច្រើននោះទេ។ ហើយជា ធម្មតាក្រុមហ៊ុនមានគោលការណ៍បើកប្រាក់ឈ្នួលរយៈពេល១៥ថ្ងៃម្តង តែជាទូទៅបើកមិនទៀងនោះទេ គឺលើសថ្ងៃរហូត ហើយពេលបើកម្តងៗគ្រួសារបងស្រី និងកម្មករផ្សេងទៀតត្រូវទូទាត់ការជំពាក់ថ្លៃ អាហារ ហូបចុកជាមួយហ្នឹងអ្នកលក់ ដែលសុំជារគេមុននោះ វាស្ទើរតែអស់បាត់ទៅហើយ ព្រោះម្ហូប និងរបស់របរនៅទីនោះវាមានតម្លៃគុណហ្នឹងពីរ និងបី បើធៀបហ្នឹងតម្លៃទីផ្សារ។ ពីដើមឡើយគ្រួសាររបស់បងស្រី មកទីនេះធ្វើជាកម្មករនៅចំការចេកនោះទេ តែដោយសារ បញ្ហាធ្វើការនៅទីនោះមិនសល់លុយ និងចៅកែចិនបានបញ្ឈប់ប្តីរបស់បងស្រីផង ក៏ព្រោះតែប្តីបងស្រី ឈប់ សម្រាកមិនអាចទៅធ្វើការបានពេលកំពុងមានជំងឺ ដូច្នេះពួកគាត់ក៏សម្រេចចិត្តប្តូរទៅធ្វើ នៅចំការកៅស៊ូវិញទៅ។ ត្រង់ចំណុចនេះបងស្រីបានបញ្ជាក់ថា *"ពួកខ្ញុំធ្វើការនៅចំការចេកគឺពិបាកត្រង់ថានៅពេលដែលយើង ឈឺអីល្មមៗ អីនោះ គេមិនខ្វល់ថាយើងឈឺអីនោះទេ គេចង់តែបង្ខំអោយយើង ធ្វើទាំងឈឺនោះឯង។ ដូចយើងប្រាប់គេថាឈឺអីអញ្ចឹង យើងសុំបានត្រឹមតែ១ថ្ងៃ ទៅ២ថ្ងៃទេបើសម្រាកយូរពេក គេដកយើងចេញ ដូចជាករណីប្តីរបស់ខ្ញុំអញ្ចឹង។ ចំពោះការចង់ឈប់សម្រាបកម្មករ អាចសុំឈប់សម្រាកនៅរាល់កន្លះ*

*ខែ បាន១ថ្ងៃ  រឺច្រើន២ថ្ងៃ បន្ទាប់ពីបើកប្រាក់ឈ្នួល*"។  ក្នុងការមករស់នៅក្នុងចំការកៅស៊ូគេតម្រូវអោយកម្មករមានសម្ភារៈ  ប្រើប្រាស់ខ្លួនឯងដោយក្រុមហ៊ុនមានត្រឹមតែបន្ទប់ដេក  និងបន្ទប់ទឹកតែប៉ុណ្ណោះ និយាយទៅមិនសូវខុសគ្នាជាមួយចំការចេកប៉ុន្មានទេ។ ជាប្រចាំថ្ងៃគ្រួសាររបស់បងស្រី ងើបជៀរជ័រតាំងពីម៉ោង១ពេលព្រឹកព្រលឹម រហូតដល់ ម៉ោង  ៥ព្រឹកទើបជៀររួចរាល់ដល់ម៉ោង៦ព្រឹកបន្ទាប់ពីហូបបាយកកឆ្អែតខ្លះហើយ ពួកគាត់ក៏បន្តចូល បកជ័រចាន បន្ទាប់ពីបកជ័រចានចប់ប្រហែលជាម៉ោង៧កន្លះ  ដល់ម៉ោង ៨កន្លះទៅម៉ោង៩ ពួកគាត់ហ្នឹងបន្តទៅសារទឹកជ័ររហូតដល់ម៉ោង១០ទៅ១១ព្រឹកទើបចប់ការងារ ហើយបានសម្រាកហូបបាយថ្ងៃត្រង់។ ការធ្វើការនៅទីនោះ ថៅកែបានគិតថ្លៃឈ្នួល លើការជៀរជ័រ សារជ័រក្នុងមួយលេខ(ដែលមានដើមកៅស៊ូពី៦០០ទៅ៧០០ដើម) បានតម្លៃ២៥០០០៛ ហើយសម្រាប់គ្រួសាររបស់លោកស្រីធ្វើបានចំនួន៤លេខ  ដូច្នេះអាចទទួលបាន១០ម៉ឺនរៀលក្នុងមួយថ្ងៃ។ ក្រៅពីធ្វើការជាកម្មករជៀរជ័រកៅស៊ូហើយលោកស្រី ក៏ជាស្ត្រីមេផ្ទះ ដែលធ្វើការងារសព្វគ្រប់បែបយ៉ាងនៅក្នុងផ្ទះលោកស្រីផងដែរ។ លោកស្រីបានបង្ហាញអារម្មណ៍ទាំងនឿយហត់ថា "*ខ្ញុំបានមកពីធ្វើការហត់ហើយ មកដល់ផ្ទះត្រូវធ្វើការងារផ្ទះបន្ថែមទៀត  ចំណែកប្តីខ្ញុំ និងកូនប្រុសវិញមកដល់ផ្ទះ បានងូតទឹកហើយសម្រាកខ្លះ តែខ្ញុំមកដល់ផ្ទះ ត្រូវធ្វើម្ហូប ពេលខ្លះបានកូនស្រីពៅអាយុ១០ឆ្នាំ គាត់បានដាំបាយរួចរាល់ទៅរាងធូរបន្តិច  ខ្ញុំគ្រាន់តែធ្វើម្ហូបទៅបានញ៉ាំទាំងអស់គ្នាហើយ។ ក្រៅពីនេះទៀតខ្ញុំត្រូវបន្តបោកខោអាវ រៀបចំបន្ទប់  អោយបានរួចរាល់ទើបបានសម្រាក លេងរហូតដល់ម៉ោង១ព្រឹកស្អែកវិញទើបពួកយើងបន្តការងារទៀត*"។

ជាកម្មករនៅក្នុងចំការកៅស៊ូ  មិនមែនជារឿងស្រួលទេសម្រាប់បងស្រី និងកម្មករផ្សេងទៀត  រួមទាំងបងស្រីដែលមានរោគបេះដូងប្រចាំកាយផងដែរនោះ បងស្រីមិនអាចទៅជៀរជ័រដោយគ្មានគ្រួសារទៅជាមួយនោះទេ ព្រោះក្នុងចំការស្ងាត់ហើយ រាងងឹតខ្លាំងណាស់។ បងស្រីបានប្រាប់ថា  "*ខ្ញុំនិងកូនស្រីពៅ  មានជំងឺបេះដូងនេះយូរមកហើយ ជំងឺនេះបានបង្ករអោយខ្ញុំ  ខ្សោយកម្លាំង  វិលៗ  និងមានអារម្មណ៍ ឆាប់ភ័យ ញ័រៗពេលបានលឺសម្លេងអ្វីខ្លាំងៗ។  សម្រាប់ប្តី  និងកូនប្រុសរបស់ខ្ញុំ ពួកគេក៏ឧស្សាហ៍ជួបស្ថានភាព  ឈឺក្បាល វិលមុខ និងខ្សោយកម្លាំងដូចគ្នា  ដោយសារការងារជាកម្មករជៀរជ័រយើងត្រូវប្រើកម្លាំងច្រើន ពេលខ្លះយើងត្រូវប្រើកម្លាំងជាប់គ្នាមួយម៉ោងទៅពីរម៉ោងទើបរួចដែបានសម្រាកបន្តិច*"។ ក្រៅពីបញ្ហាសុខភាព  កម្មករក៏ជួបប្រទះបញ្ហាជាច្រើនដូចជា  ករណីពស់ចឹកជួបសត្វពីសផ្សេងៗដែលនៅក្នុងស្លឹកកៅស៊ូ ស្មៅ និងនៅដើមកៅស៊ូជាដើម ហើយក្រុមហ៊ុនមិនមានស្បែកជើងករវែង អោយកម្មករដើម្បីពាក់កាត់បន្ថយបញ្ហានោះទេ  មួយវិញព្រោះតែធ្វើការអំឡុងពេលយប់ស្ងាត់ ទើប

ស្ត្រីដែលគាត់មកតែឯង មិនមានគ្រួសារ ឬបងប្អូន គាត់ពិបាកក្នុងការធ្វើការងារមួយនេះណាស់ ព្រោះពួកគាត់តែងមានភាពភ័យខ្លាច និងគិតថាគ្មានសុវត្ថិភាពសម្រាប់ពួកគាត់។ ចំពោះបញ្ហាជៀរជ័រវិញបងស្រីមើលឃើញថាបើនៅរដូវវស្សាកម្មករ មិនបានទទួលប្រាក់ កម្រៃច្រើននោះទ ដោយសាររដូវវស្សាមានភ្លៀងធ្លាក់ច្រើន ធ្វើអោយកម្មករមិនអាចជៀរជ័របានគ្រប់លេខកំណត់ ពេលខ្លះបានមួយលេខ ឬពីរលេខតែប៉ុណ្ណោះ លោកស្រីបានបញ្ជាក់ថា *"បើពេលដែលយើងប្រាប់ទៅមេការថាយើងជៀរ បួនលេខនៅក្នុងថ្ងៃនេះ តែពេលព្រឹកទៅជៀរទើបបានពីរលេខ ឬមិនទាន់ហើយទាំងបួនលេខ ហើយមានភ្លៀងធ្លាក់មកនោះ គេមិនគិតថ្លៃឈ្នួលអោយនោះទេ ព្រោះគេថាជ័របានចូលទឹកខូចអស់ហើយ ដោយគេមិនខ្វល់ពីកម្លាំងយើង ដែលខំទៅជៀរតាំងពីពាក់កណ្តាលយប់នោះទេ"*។

ដើម្បីជាការឆ្លើយតបទៅកាន់បញ្ហា និងអោយកម្មករទទួលបានភាពងាយស្រួលក្នុងការធ្វើការងារ បងស្រី បានលើកជាសំណូមពរថា *"ខ្ញុំនៅធ្វើការកន្លែងពិបាកអញ្ចឹង ខ្ញុំចង់បានមន្ទីរពេទ្យនិងសាលារៀនបាននៅជិតកន្លែងធ្វើការ ដើម្បីបានកូនទៅរៀនហ្នឹងគេដែរ និងអោយក្រុមហ៊ុនគិតគូរបើកស្បែកជើងពាក់ការពារ កុំអោយសត្វខាំ ឬពស់ចឹកជាដើម។ ហើយមួយវិញទៀតចង់អោយក្រុមហ៊ុនគិតថ្លៃពលកម្មបានថ្លៃជាងនេះបន្តិច ដោយសាររាល់ថ្ងៃនេះមានការចំណាយខ្ពស់ខ្លាំងណាស់ និងគិតថ្លៃកម្លាំងពលកម្មអោយកម្មករពេលដែលជៀរបានខ្លះហើយតែមានភ្លៀងធ្លាក់ ព្រោះនេះវាមកពីធម្មជាតិ មិនបានមកពីកម្មករនោះទេ។ ជាពិសេសចង់អោយមាន បសស ដើម្បីប្រើប្រាស់ក្នុងករណីគ្រួសារ បងស្រី ឬកម្មករផ្សេងៗទៀត ឈឺថាបានទៅខាងមណ្ឌលសុខភាព ឬមន្ទីរពេទ្យ គេមើលជម្ងឺដោយមិនអស់លុយ"*។







"ខ្ញុំគិត ថាមនុស្សស្រីហ្នឹងហើយរវល់ជាងគេ បើថាហត់នឿយគឺហត់ខ្លាំងហើយ តែយើងធ្វើម៉េចបើយើងជាមនុស្សស្រី ការងារដាំបាយ លាងចាន ធ្វើម្ហូប ការងារផ្ទះហ្នឹងជាការងារយើងហើយ ពេលមកពីធ្វើការងារជាកម្មករវិញពេលខ្លះ ប្ដីខ្ញុំមានកម្លាំងគាត់ជួយដាំបាយទៅ តែបើគាត់ហត់ គាត់ក៏សម្រាកទៅ។ កូនប្រុសខ្ញុំអត់ចេះធ្វើអីទេ ពឹងម្ដងៗពិបាកដែរហ្នឹង"

**សម្រង់សម្ដីពីសាច់រឿងទី ២**



# សាច់រឿងទី ២
## បងស្រីម្នាក់ជាកម្មករនៅក្រុមហ៊ុនកៅស៊ូ

បងស្រីជាកម្មករជៀរជ័រ មកពីចំការកៅស៊ូនៅក្រុមហ៊ុនមួយកន្លែង។ សព្វថ្ងៃ បងស្រីរស់នៅជុំគ្នា ជាមួយស្វាមី និងកូនម្នាក់ អាយុ១៧ឆ្នាំ ដែលគាត់មិនបានទៅរៀនសូត្រទេ ដោយសារតែកត្តាជីវភាព។ គ្រួសារមានកម្រិតជីវភាពក្រីក្រ និងពឹងផ្អែកទាំងស្រុងទៅលើការធ្វើការងារជាកម្មករជៀរជ័រនៅក្រុមហ៊ុន។

បងស្រីបានចែករំលែកអំពីសកម្មភាពការងារប្រចាំថ្ងៃ របស់ពួកគាត់ទាំងបីនាក់ ថា "*យើងធ្វើ ការជៀរជ័រ គឺយើងក្រោកម៉ោង១យប់ ជៀរហើយខ្ទង់ម៉ោង៥កន្លះ បានយើងទៅបកជៀរចាន បានសម្រាកបន្តិចយើងទៅហូបបាយព្រឹក បន្ទាប់មកប្រហែលជាម៉ោង៩ បានគេអោយទៅសារទឹកជ័រ ពេលសារហើយយកជ័រមកចាក់ដាក់ឡាន ដែលប្តីខ្ញុំ និងកូនជាអ្នកលើកចាក់ចូលក្នុងធុងឡាន រួចយើងមកដាំបាយហូប និងសម្រាក រហូតដល់ម៉ោងយើងជៀរវិញ ទើបយើងចាប់ផ្តើមការងារហ្នឹងម្តងទៀត*"។ ជាស្ត្រីម្នាក់ដែលធ្វើជាកម្មករជៀរជ័រកៅស៊ូផង និងជាស្ត្រីម្នាក់ដែលជាមេផ្ទះផង មិនមែនមានតែគ្រួសាររបស់បងស្រីទេដែលមនុស្សស្រីត្រូវធ្វើការងារគ្រប់បែបយ៉ាងនៅក្នុងផ្ទះ និងត្រូវធ្វើការរកលុយនៅខាងក្រៅដែរ គឺមានគ្រួសារកម្មករនៅទីនេះ និងគ្រួសារនៅក្នុងសហគមន៍ឯស្រុករបស់បងស្រីក៏ទម្លាប់ធ្វើបែបនេះតៗគ្នាយូរមកហើយ តួយ៉ាង បងស្រីបានលើកឡើងថា "*ជាទូទៅពេលសម្រាកដាំបាយធ្វើម្ហូប ការងារផ្ទះ ខ្ញុំជាអ្នកធ្វើ ចំណែកពេលសម្រាកសេសសល់ ពេលខ្លះយើងបោសសំអាត ទុកដាក់សម្ភារៈក្នុងផ្ទះ បោកខោអាវអញ្ចឹងទៅ ពេលណាយើងហើយការងារយើងក៏ទៅសម្រាកទៅ។ ចំពោះប្តីខ្ញុំម៉ោងសម្រាក គាត់សម្រាកទៅគាត់អត់មានធ្វើអីទេ ដោយសារគាត់ចាស់ហើយ អត់ដូចយើងក្មេងទេ ចឹងពេលគាត់ចប់ការងារគាត់ងូតទឹក ហូបបាយហើយគាត់ក៏សម្រាកទៅ។ គ្រួសារផ្សេងទៀតក៏អញ្ចឹងដែរ មានតែមនុស្សស្រីទេដែរធ្វើការងារទាំងនេះ*"។ បងស្រីតែងតែមានការគិតវិជ្ជមានទៅលើការធ្វើការងាររបស់បងស្រីជានិច្ច និងគិតថាមនុស្សស្រី ត្រូវតែមានភាពរស់ និងនឿយហត់ជាងបុរសអញ្ចឹងហើយ សម្រាប់បងស្រីផ្ទាល់បានមើលឃើញថា "*មនុស្សស្រីហ្នឹងហើយរវល់ជាងគេ បើថាហត់នឿយគឺហត់ខ្លាំងហើយ តែយើងធ្វើម៉េចបើយើងជាមនុស្សស្រី ការងារដាំបាយ លាងចានធ្វើម្ហូប ការងារផ្ទះហ្នឹងជាការងារយើងហើយ ពេលមកពីធ្វើការងារជាកម្មករវិញពេលខ្លះ ប្តីខ្ញុំ*

*មានកម្លាំងគាត់ជួយដាំបាយទៅ តែបើគាត់ហត់ គាត់ក៏សម្រាកទៅ។ កូនប្រុសខ្ញុំអត់ចេះធ្វើអីទេ ពឹងម្តងៗពិបាកដែរហ្នឹង*"។

សម្រាប់ចំការកៅស៊ូដែលបងស្រីកំពុងធ្វើការមិនមានការបែងចែក ប្រភេទការងារប្រុសឬការងារស្រីនោះទេ មានការងារតែមួយគត់ គឺជៀរជ័រកៅស៊ូ។ ជាកម្មករនៅក្នុងក្រុមហ៊ុន ក្រុមហ៊ុនបានផ្តល់អោយកម្មកររួមមាន ផ្ទះស្នាក់នៅ ទឹក ភ្លើង ប្រាក់ឈ្នួលប្រចាំថ្ងៃចំនួន ២៤០០០រៀល បូកបន្ថែមលុយអង្ករចំនួន១០០០រៀល។ ផ្ទះដែលក្រុមហ៊ុនរៀបចំអោយមានតែសម្បកផ្ទះ តែសម្ភារៈផ្សេងដូចជា ចាន ឆ្នាំង ចង្ក្រាន មុងភួយ កម្មករត្រូវទិញខ្លួនឯង ចំណែកទឹកវិញ គឺប្រើប្រាស់ម៉ូទ័រទឹកដែលបូមចេញពីចំការចេកយកមកប្រើប្រាស់ សម្រាប់បោកគក់ ងូតទឹក និងចំអិនម្ហូបតែកម្មករមិនផឹកផ្ទាល់ទេ ដោយសារបារម្ភពីការជ្រៀប ឬហូរសារធាតុពុលពីចំការចេកមកចូលក្នុងទឹកនោះ។ ក្រៅពីនេះនៅពេលចាប់ផ្តើមការងារក្រុមហ៊ុនក៏មានការចែកសម្ភារៈមួយចំនួនដែរ ដោយបងស្រី រៀបរាប់ថា "*គេចែក ពន្លៀកកូម (ពិលក្បាល) ពិលហ្នឹងគេអោយលុយ២០០០០រៀលទៅតែយើងចូល ដើម៥០០០ ដោយសារតែវាមានតម្លៃ២៥០០០។ ខោអាវ ពាក់អាវករក្អមធម្មតា គ្មានអាវការពារអ្វីនោះទេ នៅក្នុងចំការហប់ បើខែរងារផងជៀរជ័រលែងរងាតែម្តង និយាយទៅយើងជិះតាមផ្លូវត្រជាក់ តែចុះជៀរបានតែពីរជួរអីចាប់ផ្តើមហប់ អត់តែម្តង*"។បងស្រីបានបន្តរៀបរាប់ពីស្ថានភាពមួយចំនួនទៀតទាក់ទងទៅហ្នឹងបទពិសោធន៍ក្នុងការជៀរជ័រកៅស៊ូថា "*យើងជៀរជ័រចឹងខ្លាចតែសត្វទេ ជាពិសេសពស់សំបូរហ្មង ដូចពស់ថ្នាំងអំពៅ មានច្រើនណាស់។ យើងពាក់តែទ្រនាប់ជើងឃ្លុប ឬស្បែកជើងករវែងត្រឹមៗជង្គង់ ស្បែកជើងករវែងហ្នឹងយើងទិញខ្លួនឯង ក្រុមហ៊ុនមិនបានចែកអោយទេ មួយគូរ២៥០០០រៀល ជាទូទៅស្បែងជើងអាចប្រើបានយូរដែរបើយើងថៃ។ ពេលយើងជៀរជ័រប្រើយើង អត់ស្រោមដៃអីទេហើយដៃខ្ញុំឧស្សាហ៍ឡើងហើមណាស់ដោយសារបុកស្លរាបព្រា*"។

ជាធម្មតាក្រុមហ៊ុនបើកប្រាក់ឈ្នួលប្រចាំថ្ងៃ ក្នុងរយៈពេល១៥ថ្ងៃម្តង ស្មើរមួយខែ២ដង តែក្នុងមួយខែហ្នឹងក្រុមហ៊ុនកាត់ទុក បីថ្ងៃហើយ។ ការកាត់ទុកនេះករណីកម្មករអត់ជៀរជ័រអីក្រុមហ៊ុនយកវាមកទូទាត់ ជូនកាលខ្លាចកម្មករយកពន្លៀកទៅបាត់ ហើយឈប់ធ្វើការតែម្តង។ ហើយ មានពេលខ្លះកម្មករប្រឈម ហ្នឹងការកាត់លុយទៀតផង ពេលដែលឈប់មិនប្រាប់គេ។ បងស្រីបានរៀបរាប់ថា "*យើងត្រូវធ្វើរាល់ថ្ងៃ បើយើងចង់សម្រាកត្រូវប្រាប់គេមុន បើអត់ប្រាប់គេមុនទេ គេអាចកាត់លុយយើងមួយថ្ងៃហ្នឹង ២៥០០០រៀលក្នុងម្នាក់ ប្រាក់ឈ្នួលថ្ងៃហ្នឹងមិនបានហើយ ត្រូវគេកាត់លុយថែមទៀត ករណីបែបនេះបើយើងឈឺភ្លាមៗអីពិបាកសុំគេណាស់*"។

មួយវិញទៀតការបើកប្រាប់ឈ្នួលមិនដែលទៀងទាត់ទេ ដែលធ្វើអោយកម្មករមានការពិបាកព្រោះខ្វះខាតទៅលើការចំណាយ។ នៅក្នុងចំការមានការ កំណត់លេខក្នុងការជៀរជ័រកៅស៊ូ មួយលេខវាមានចំនួន៦០០ដើមជាង ហើយជាប្រចាំគ្រួសាររបស់បងស្រីអាចជៀរជ័របាន៤លេខ ដែលស្មើរហ្នឹងលុយ១០ម៉ឺនរៀលក្នុងមួយថ្ងៃ។ សម្រាប់កម្មករណាដែលជៀរមិនគ្រប់លេខដែលបានប្រាប់មេការ នោះក្រុមហ៊ុនមិនគិតថ្លៃឈ្នួលអោយទេ បងស្រីបញ្ជាក់ថា "*ការងារពលកម្មហ្នឹង ថ្ងៃណាយើងធ្វើយើងបានលុយទៅ ថ្ងៃណាយើងអត់ធ្វើ យើងអត់បានទៅ ហើយវាពិបាកដែររឿងលុយឥឡូវអត់ស្រួលបើកទេ គឺថាបើកហួសថ្ងៃរហូតហ្នឹង បើកអត់ទៀងទាត់អោយយើងទេ។ អារឿងបើកអត់ទៀងហ្នឹងដោយសារ ពេលណាគេចង់បើកអោយយើងក៏បើកទៅ តែនៅពេលណាគេមិនចង់បើកអោយហ្នឹង គឺនៅរាងយូរទៅ តែមុនក្រោយគេនៅតែបើកទេ។ មួយទៀតធ្លាប់មានការជៀរជ័របានមួយលេខ ពីរលេខ គេមិនចេញថ្លៃពលកម្មអោយ និយាយទៅតែយើងជៀរអត់បានគ្រប់លេខ ហើយមេឃភ្លៀងមក គេអត់អោយយើងទេ ដល់ព្រឹកឡើងយើងទៅ បកបាត់ចានក៏គេមិនអោយលុយយើងដែរ ចឹងយើងបញ្ចេញកម្លាំងទទេរសុទ្ធ យើងអត់ងងុយ ក្រោកតាំងពីម៉ោង១ ម៉ោង២ហើយអត់បានថ្លៃឈ្នួលទៀត*"។ គ្រួសារបងស្រីបានធ្វើការទូទាត់ចំណូលក្នុងមួយថ្ងៃ១០ម៉ឺនជាមួយហ្នឹងថ្លៃហូបចុក ដែលមួយថ្ងៃ ចំណាយ៥ម៉ឺន ដោយមិនទាន់រាប់ពីការចំណាយទៅការឈឺថ្កាត់ និងការចាយវាយផ្សេងទៀតដែលជួនកាលអាចចំណាយពី២០ម៉ឺនទៅ៣០ម៉ឺន។ កន្លែងធ្វើការងារជៀរជ័រហ្នឹង គឺត្រូវធ្វើដំណើរដោយម៉ូតូ សព្វថ្ងៃ គ្រួសារគាត់ត្រូវ ប្រើម៉ូតូចំនួនពីរគ្រឿង ហើយចាក់សាំង១ថ្ងៃអស់១លីត្រកន្លះក្នុងមួយម៉ូតូ។ ដោយសារផ្លូវធ្វើដំណើរលំបាក ឆ្ងាយ ហើយកន្លែងខ្លះ គឺនៅលើភ្នំតែម្តង។ រាល់ថ្ងៃការផាត់ចំណូល និងចំណាយ គាត់អាចនៅសល់តិចតួចដែរ ដើម្បីទុកប្រើពេល ចាំបាច់ជាពិសេសពេលឈឺថ្កាត់ម្តងៗ។

រាល់ថ្ងៃនេះកម្មករចំការកៅស៊ូមានប្រហែល ៤០គ្រួសារ ដែលមានគ្រួសារខ្លះចំណាកស្រុកមកធ្វើការនៅទីនេះ និងខ្លះទៀតជាអ្នកភូមិនៅជិតតំបន់ចំការក្រុមហ៊ុន។ ចំពោះកូនៗកម្មករនៅចំការពួកគេ ត្រូវធ្វើដំណើរទៅរៀននៅសាលារៀនមួយកន្លែងនៅឆ្ងាយដែរពីក្រុមហ៊ុន និងផ្លូវមានការលំបាកខ្លាំង។ គ្រួសារមានលទ្ធភាពគាត់ដឹកកូនទៅរៀននៅពេលថ្ងៃនៅម៉ោង១២ថ្ងៃទៅ ដោយសារពេលព្រឹកពួកគាត់ជាប់រវល់ការងារ។ ចំពោះបសសវិញ ក្រុមហ៊ុនមិនទាន់បង់អោយនោះទេ ហើយពេលឈឺថ្កាត់ឬគ្រោះថ្នាក់ម្តងៗ ទាំងក្រៅម៉ោងធ្វើការងារ និងក្នុងម៉ោងធ្វើការងារ មិនចេញអោយនោះទេ ហើយកម្មករត្រូវចំណាយលុយខ្លួនឯងផ្ទាល់ក្នុងការព្យាបាល។ បងស្រីបាននិយាយថា "*បសសវាមានសារៈសំខាន់ក្នុងការជួយសម្រួលពេលមានជំងឺ*

អាចទៅពេទ្យ ដោយមិនបាច់បង់លុយ ពេលនេះពួកគាត់បានប្រមែប្រមូលគ្នាទាំងក្រុមនៅចំការចេក និងនៅចំការកៅស៊ូ ធ្វើការចុះឈ្មោះ និងរូបថតតាមរយៈសហជីព ដោយសារនៅកម្មករក្នុងចំការគាត់មិនទាន់មានបសសនៅឡើយទេ។ ហើយពេលគ្រោះថ្នាក់នៅម៉ោងការងារក្រុមហ៊ុនមិនដែលចេញលុយអោយនោះទេ។ តែយ៉ាងណាកម្មករដែលបានចុះឈ្មោះមានការបារម្ភ ដោយសារក្រុមហ៊ុនមិនចង់អោយពួកគេចូលសហជីព និងលើកការស្នើសុំអីមកក្រុមហ៊ុននោះទេ។ ក្រុមហ៊ុនបើដឹងថាកម្មករណាចូលសហជីព គេអត់អោយយើងធ្វើការទេ ហើយក្រុមហ៊ុនធ្លាប់បានដកចោលមួយចំនួនហើយ ដោយសារចឹងក៏ស្ងាត់មួយរយៈទៅវិញទាក់ទងរឿងចុះឈ្មោះសុំប.ស.សហ្នឹង"។ សហជីពនេះមានតាំងពីឆ្នាំមុន ដំបូងមានមេក្រុមចុះឈ្មោះហៅប្រជុំនៅចំការ កាលនោះមានកម្មករចូលរួមសមាជិកច្រើន ហើយក៏មានស្ត្រីត្រូវបានជ្រើសរើសជាប្រធានក្រុមដែរ។ ក្រុមសហជីពធ្លាប់ចង់អោយបងស្រីធ្វើជាប្រធានក្រុមដែរ តែបងស្រីបដិសេធមិនធ្វើ ដោយសារមិនចេះអក្សរ តែបងស្រីជឿថា បើមានប្រធានក្រុមជាស្ត្រីអាចស្រួលជជែកគ្នាជាមួយជាង ព្រោះជាមនុស្សស្រីដូចគ្នា។ ដើម្បីឆ្លើយតបស្ថានភាពលំបាក បងស្រីបានលើកជាគំនិតថា "មានតែសុំក្រុមហ៊ុនអោយតម្លើង ប្រាក់ឈ្នួលថ្លៃជាងនេះបន្តិច។ ដែលកាលពីមុនម្នាក់ៗបានលុយបើកកន្លះ ខែខ្លះបាន៥០ម៉ឺន ៦០ម៉ឺនអី តែឥឡូវបានតែ ៣០ទៅ ៤០ម៉ឺនអី មិនដឹងថីទេឥឡូវវាស៊ីពេកហើយ ព្រោះការងារធ្វើបានលទ្ធផលដូចគ្នាហ្នឹង។ ក្រុមហ៊ុនឥឡូវពិបាកអត់ដូចមុនទេ កាលពីមុនធ្វើ ពីរនាក់ប្តីកន្លះខែបាន ១លាន២០ម៉ឺន តែសារនេះបើរកអត់បានទេ។ មួយវិញទៀតខ្ញុំចង់អោយកម្មករទាំងអស់គ្នាមានបសសណាស់ ដើម្បីជួយសម្រួលការចំណាយទៅលើថ្លៃពេទ្យ និងអាចអោយកម្មករគាត់បានទៅពេទ្យខ្លះ ព្រោះមានកម្មករមួយចំនួន ដែលឈឺហើយតែគាត់មិនហ៊ានទៅពេទ្យទេ ព្រោះអត់មានលុយ។ និងចង់អោយក្រុមហ៊ុន បើកអោយមានសេរីភាពលើការបង្កើតក្រុមសហជីព ដើម្បីជាសម្លេងរបស់កម្មករគ្រប់គ្នា"។




40





“ខ្ញុំធ្លាប់ពុលថ្នាំ កាលហ្នឹងខ្ញុំដាំកូនចេកដំបូងកាលនៅតូច ពេលហ្នឹងខ្ញុំពុលអាគេបាញ់ស្មៅ នោះបង ពុលរាងសឹៗទៅដល់ផ្ទះវិញអត់ស្រួលខ្លួន បង ខ្ញុំអោយលេបថ្នាំនិងកោសខ្យល់ អញ្ចឹង ទៅបង ហើយយើងផឹកក្រូចឆ្មាទៅវាបន្សាបខ្លះហើយ។ ខ្ញុំពុលញ័ុកញាប់ដៃរបង និយាយទៅខ្ញុំខ្សោយ អោយតែពេលខ្ញុំទៅធ្វើការដែលពាក់ព័ន្ធហ្នឹងថ្នាំ ខ្ញុំអត់ស្រួលខ្លួន ហើយ។ ប៉ុន្តែខ្ញុំសុំមេដូរ តែគាត់អត់អោយខ្ញុំដូរទេគាត់ថា បើខ្ញុំដូរទៅមានអ្នកណាធ្វើ ជំនួស។ ដូចពេលគ្រប់កូនចេកដែលគេកំពុងហ្នឹងបាញ់បណ្តើរយើងគ្រប់បណ្តើរ ព្រោះ ខ្លាចកូនចេកត្រូវថ្នាំ ចឹងថ្នាំហ្នឹងបាញ់លើខ្លួនយើងពេញៗហ្មង។ អ្នកបាញ់ម្នា ក់ទៅពីរនាក់ យើងគ្រប់តែឯងទេ ហើយយើងមិនអាចឃឹតទេបង គេបាញ់ពីរនាក់ហើយ យើងត្រូវបង្ខំ ធ្វើអោយទាន់គេបាញ់ មិនអាចឈប់បានទេបង។ ហើយតិចថាពេលបាញ់ថ្នាំហ្នឹងយើង សម្រាកអីតិចហ្នឹង គេមកស្តីអោយតែម្តង។"

**សម្រង់សម្តីពីសាច់រឿងទី ៣**




He
RO

# សាច់រឿងទី ៣

## ប្អូនស្រី ជា គន្ធា ជាកម្មករនៅក្រុមហ៊ុនចំការរចេក

ប្អូនស្រី ឈ្មោះថា ជា គន្ធារាល់ថ្ងៃ ជាកម្មករធ្វើការនៅក្នុងចំការចេកមួយកន្លែង។ ស្ថានភាពគ្រួសារបច្ចុប្បន្ន ប្អូនស្រីបានលែងលះគ្នា ដែលមានកូនចំនួន២នាក់ ម្នាក់អាយុ៨ឆ្នាំ និងម្នាក់ទៀតអាយុ៦ឆ្នាំ ព្រមទាំងមានម្ដាយម្នាក់ ដែលស្ថិតនៅក្នុងបន្ទុកគ្រួសារ។ ប្អូនស្រីជាអ្នករ៉ាប់រងនូវសេដ្ឋកិច្ចគ្រួសារទាំងអស់ ដោយប្អូនស្រីបានចាកចេញ ពីស្រុកកំណើត និងមកធ្វើការជាកម្មករនៅក្នុងចំការចេកនៅក្នុងក្រុមហ៊ុនមួយកន្លែង។ ប្អូនស្រីបានសម្រេចចិត្តមកធ្វើការជាកម្មករចំការចេក ដោយសារយោងទៅលើអត្ថប្រយោជន៍ដែលក្រុមហ៊ុនផ្ដល់អោយដែលមានដូចជា កន្លែងស្នាក់នៅ ទឹក និងភ្លើងដោយឥតគិតថ្លៃ ព្រមទាំងការគិតថ្លៃឈ្នួលតាមចំនួនថ្ងៃដែលប្អូនស្រីគិតថា អាចមកមើលសុខទុក្ខកូនៗ និងម្ដាយពេលពួកគាត់ឈឺម្ដងម្កាលបាន។

ក្នុងរយៈពេលជាងមួយឆ្នាំនៃការធ្វើការងារជាកម្មករនៅចំការចេក គន្ធាបានធ្វើការដែលក្រុមហ៊ុនកំណត់ថា ជាការងាររបស់កម្មករជាស្ត្រី មានដូចជា កាច់ផ្កា ដោលស្លរឹក កាត់ស្លរឹក និងគ្របកូនចេកពេលគេបាញ់ថ្នាំ ជាធម្មតាប្រាក់ឈ្នួលប្រចាំថ្ងៃដែលស្ត្រីធ្វើគឺ ២៨០០០រៀលតែប៉ុណ្ណោះ។ ចំណែកការងារសម្រាប់កម្មករជាបុរសវិញ ដែលភាគច្រើនទៅលើការងារបាញ់ថ្នាំចេក ស្មៅ និងអូសទុយោរបូមទឹក ដែលជាទូទៅទទួលប្រាក់ឈ្នួលប្រចាំថ្ងៃ ៣០០០០រៀលទៅ៣៥០០០រៀល ក្នុងមួយថ្ងៃ។ ដោយឡែកសម្រាប់កម្មករជាស្ត្រីមួយចំនួនដែលធ្វើការងារដូចជាបុរសដែរ តែក្រុមហ៊ុនមិនគិតថ្លៃឈ្នួលអោយដូចគ្នានោះទេ។ ជាមួយគ្នានេះដែរ ម៉ោងពេលនៃការធ្វើការ របស់បុរសស្ត្រីក៏មានភាពខុសគ្នាដែរ ដោយបុរសត្រូវចេញនិងអនុញ្ញាតិអោយឈប់សម្រាកមុនស្ត្រីកន្លះម៉ោង ដូចជាម៉ោងធ្វើការចាប់ពីម៉ោង ៦កន្លះព្រឹក ដល់ម៉ោង៤កន្លះរសៀល កម្មករប្រុសសម្រាក នៅម៉ោង៤រសៀល។ ប្អូនស្រីធ្លាប់បានជជែក អំពីបញ្ហានេះទៅកាន់ក្រុមហ៊ុនដែរ ដោយប្អូនបានលើកជាករណីប្អូនផ្ទាល់ថា "*ខ្ញុំធ្លាប់បាញ់ថ្នាំស្លរឹកតែក្រុមហ៊ុនគិតថ្លៃឈ្នួលអោយធម្មតាគឺប្រាក់ឈ្នួលសម្រាប់ស្ត្រី (២៨០០០រៀល) ការងារដូចជាបើកទឹកវិញប្រុសបាន៣៣០០០រៀល ចំណែកកម្មករស្រីបានតែ២៨០០០រៀលទេ។ បើកទឹកតាមឡូ ខ្ញុំអីក៏ធ្លាប់ដែរបង។ ខ្ញុំធ្លាប់តវ៉ារឿងហ្នឹងដែរ ខ្ញុំសួរថាមេ ការងារស្រីជួនកាលប្រុសធ្វើ ការងារស្រីដែរហ្នឹង*

មេ តែនៅតែបានលុយថ្លៃជាងស្រីចឹង ហើយម៉ោងឡើងក៏លឿនជាងស្រីទៀត។ ដល់ពេលស្រីធ្វើការងារប្រុសវិញ បានលុយមិនដូចគេខាងប្រុសសោះ ចឹងពាក្យគាត់ឆ្លើយតបមកវិញថា ចឹងមិនទៅស្ពាយធុងបាញ់ថ្នាំដូចមនុស្សប្រុសទៅ ខ្ញុំអស់អីនិយាយតែម្តង"។

ក្រុមហ៊ុនមិនធ្លាប់ផ្តល់ ឬចែកសម្ភារៈអោយកម្មករ ដើម្បី ពាក់ការពារ សុវត្ថិភាពទេ ដូចជា ស្រោមដៃ ស្បែកជើង ម៉ាស់ ឬអាវការពារពីថ្នាំបាញ់ចេកនិង ស្មៅដល់កម្មករឡើយ ដោយកម្មករត្រូវចេះការពារដោយខ្លួនឯង។ គន្ធាលើកឡើងថា "និយាយទៅបង ក្រុមហ៊ុនគឺគេមានតែការងារធ្វើ អោយយើងតែមួយមុខគត់ លុយពលកម្មប្រចាំថ្ងៃ មានផ្ទះយើងស្នាក់នៅ និងទឹកភ្លើង។ ក្រៅពីនេះ ខ្ញុំត្រូវចំណាយទៅលើសម្ភារៈមានដូចជា ស្រោមដៃចឹងទៅ ខោអាវស្លៀកពាក់។ ការស្លៀកពាក់ហ្នឹង បើយើងកាច់ផ្កា គឺខោអាវយើងស្លៀកពាក់ធម្មតាទេ តែបើយើងទៅដោលស្លឹក ក៏ខោអាវ ធម្មតាដែរ តែចំពោះការងារអូសទុយោថ្នាំអី យើងត្រូវមានអីសម្រាប់ការពារខ្លួនឯងដូចម៉ាស់ជាដើម ព្រោះកុំអោយថ្នាំ ស្រោចចូលមុខ តែធ្វើចឹងក៏ការពារមិនបានប៉ុន្មានដែរបង ព្រោះយើងត្រូវដើរពីក្រោយគេអ្នកបាញ់ថ្នាំរហូតហ្នឹង"។ ប្អូនស្រីបន្តទៀតថា "ខ្ញុំធ្លាប់ពុលថ្នាំកាលហ្នឹងខ្ញុំដាំកូនចេកដំបូងកាលនៅតូច ពេលហ្នឹងខ្ញុំពុលអាគេបាញ់ស្មៅនោះបង ពុលរាងសឹៗទៅដល់ផ្ទះវិញអត់ស្រួលខ្លួន បង ខ្ញុំអោយលេបថ្នាំនិងកោសខ្យល់អញ្ចឹងទៅបង ហើយយើងផឹកក្រូចឆ្មាទៅវាបន្សាប់ខ្លះហើយ។ ខ្ញុំពុលញឹកញាប់ដែរបង និយាយទៅខ្ញុំខ្សោយ អោយតែពេលខ្ញុំទៅធ្វើការដែលពាក់ព័ន្ធនិងថ្នាំ ខ្ញុំអត់ស្រួលខ្លួនហើយ។ ប៉ុន្តែខ្ញុំសុំមេដូរ តែគាត់អត់អោយខ្ញុំដូរទេគាត់ថា បើខ្ញុំដូរទៅមានអ្នកណាធ្វើជំនួស។ ដូចពេលគ្របកូនចេកដែលគេកំពុងហ្នឹង គេបាញ់បណ្តើរយើងគ្របបណ្តើរ ព្រោះខ្លាចកូនចេកត្រូវថ្នាំ ចឹងថ្នាំហ្នឹងបាញ់លើខ្លួនយើងពេញៗហ្មង។ អ្នកបាញ់ម្នា ក់ទៅពីរនាក់យើងគ្របតែឯងទេ ហើយយើងមិនអាចយឺតទេបង គេបាញ់ពីរនាក់ហើយ យើងត្រូវបង្ខំ ធ្វើអោយទាន់គេបាញ់ មិនអាចឈប់បានទេបង។ ហើយតិចថាពេលបាញ់ថ្នាំហ្នឹងយើងសម្រាកអីតិចហ្នឹង គេមកស្តីអោយតែម្តង"។ ការងារនៅទីនេះមានភាពមមាញឹកច្រើន កម្មករហត់ចង់សម្រាកក៏គេមិនចង់អោយសម្រាកដែរ និងករណីឈឺថ្កាត់ក៏មិនអោយឈប់ដែរ។ ប្អូនស្រីលើកឡើងថា " ដូចថាយើងហត់ចឹង សុំគេអង្គុយក៏គេអត់អោយយើងអង្គុយដែរ ពេលឃើញយើងអង្គុយ គេស្តីអោយយើង ពេលខ្លះអាចគេដកយើងចេញក៏មានដែរបង។ មួយវិញទៀតដូចពេលខ្ញុំមករដូវចឹង ខ្ញុំចង់សម្រាកបន្តិច ព្រោះខ្ញុំឈឺពោះ ឈឺចង្កេះ ខ្ញុំពិបាកធ្វើការ តែខ្ញុំត្រូវតែទ្រាំមិនអាចឈប់សម្រាកបានទេបង។ ហើយបើគេថាដកចេញ គឺថ្ងៃនេះគេអត់អោយថ្លៃឈ្នួលហើយ និងគេអោយយើងឈប់ធ្វើតែម្តង។ ទាល់តែពេលណា អត់មានការងារធ្វើ ឬអត់មានកម្មករធ្វើចឹងបានគេហៅយើងចូលធ្វើវិញ និយាយគេអត់មានបានគេហៅយើង។"

តួយ៉ាងថ្មីៗនេះប្អូនស្រី និងកម្មករស្ត្រីចំនួនពនាក់ទៀតត្រូវបានដកចេញដោយអត់មានមូលហេតុ សព្វថ្ងៃពួកគាត់រងចាំដំណោះស្រាយពីក្រុមហ៊ុន តាមរយៈអន្តរាគមន៍ពីសហជីព ក្នុងអំឡុង ពេលដកប្អូនស្រី និងមិត្តរួមការងារ គឺពួកគាត់បានស្វែងរកកន្លែងផ្សេងៗនៅជិតៗនោះដើម្បីដោះស្រាយជីវភាព។ ប្អូនស្រី លើកឡើង "*បើដោះស្រាយមិនបានខ្ញុំមានតែរកការងារផ្សេងធ្វើទៅព្រោះខ្វះខាតជីវភាពយើងវាខ្សត់។ និយាយទៅពិបាករកការងារណាស់បង ពិបាករកមែនទែនម៉ង។ ថ្ងៃនេះខ្ញុំកំពុងស្វែងរកការងារ ក្បែរៗហ្នឹងដែរ ហើយលុយដែលនៅសល់ហ្នឹងខ្ញុំមិនទាន់បើកទេ ព្រោះខ្ញុំចង់ចូលធ្វើការវិញដែរ ព្រោះខ្ញុំគិតថា មកបញ្ឈប់យើងអត់មូលហេតុ ចឹងមិនត្រូវ។ ការបញ្ឈប់នោះបើតាមខ្ញុំគិត ដោយសារមេស្រីនោះគាត់មិនចូលចិត្តពួកខ្ញុំ*"។

ប្អូនស្រីបានរៀបរាប់បន្ថែមទៀតទាក់ទងទៅហ្នឹងស្ថានភាពលំបាក និងការប្រឈមក្នុងការធ្វើការងារ ក្នុងចំការចេក។ ប្អូនស្រីលើកឡើងថា យើងជាកម្មករមានការប្រឈមហ្នឹងគ្រោះថ្នាក់ជាច្រើន ដូចជា ពុលថ្នាំ មុតដៃមុតជើង ធ្លាក់ពីលើកាំជណ្តើរ សត្វធាតុខាំ ដូចជាពស់ ដែលកម្មករត្រូវប្រយ័ត្ន និងទទួលខុសត្រូវខ្លួនឯង។ ប្អូនស្រីបានលើកឡើងបន្ថែមទៀតអំពីបញ្ហាទឹក ភ្លើង និងកន្លែងស្នាក់នៅ គាត់បានរាយរាប់ថា "*បើទឹកគេបូមពីម៉ូទ័រធម្មតា ដាក់ទុយោកប់ដី។ ករណីគេបាញ់ថ្នាំអី ក៏វាប៉ះផ្ទះស្នាក់ដែរ តែគ្មានដំណោះស្រាយអីទេ។ ទឹកពេលខ្លះប្រើអត់គ្រប់គ្រាន់ទេ ដូចពីរ បី ខែមុនហ្នឹងខ្វះទឹក ដល់ថ្នាក់ខ្ញុំទៅសុំ អង្វរគេ សូមអោយបើកទឹក ខ្ញុំអត់មានទឹកបោកខោអាវ ទឹកងូតទេ ដល់ចឹងគាត់ប្រាប់យើងថា អោយយើង ប្រើទឹកអូរសិនទៅ។ ទឹកអូរហ្នឹងវា ហូរចេញប្រភពពីនេះពីនោះមក កាត់តាមចំការចេកខ្លះ ហូរចូលអូរដែរ ចឹងវាអាចមានជាតិពុលដែរ។ ទឹកពីអូរយកមកប្រើហ្នឹង យើងមិនបានមកសំអាត ឬសម្លាប់មេរោគទេ គឺយើងប្រើឆៅតែម្តង តែបើទឹកយើងញាំ គឺយើងដូរធុងគេ សម្រាប់ទឹកអូរយើងយកមកប្រើប្រាស់លាងចាន បោកខោអាវ និងងូតជាដើម។ ទឹកសម្រាប់ផឹកនោះក្នុងមួយធុង២៥០០រៀល ទឹកហ្នឹងពេលខ្លះយើងឃើញមានកំទិច ឬកករអីដែរហ្នឹងបង អ្នកខ្លះគេយកមកដាំឆ្អិនសិន អ្នកខ្លះទៀតគេផឹកតែម្តង*"។ សម្រាប់នៅកន្លែងស្នាក់នៅរបស់កម្មករវិញ មិនមានបង្គន់សម្រាប់ប្រើប្រាស់ឡើយ ដូចនេះកម្មករត្រូវទៅព្រៃនៅ ឆ្ងាយពីកន្លែងពូកគាត់ប្រហែលជិតពីរគីឡូ ពេលទៅម្តងៗត្រូវបបួលគ្នាទៅ បើទៅម្នាក់ឯងមិនហ៊ាននោះទេ ដោយសារពួកគាត់បារម្ភ ពីសុវត្ថិភាព និងការបៀតបៀនពីមនុស្ស និងសត្វផងដែរ។ មួយវិញទៀតនៅពេលឈឺថ្កាត់ម្តងៗ កម្មករត្រូវចេញ ទៅមណ្ឌលសុខភាព ឬពេទ្យឯកជនដែលនៅឆ្ងាយៗពីទីនេះណាស់ ហើយត្រូវចេញលុយខ្លួនឯង។ ចំពោះម្ហូប មានអ្នកលក់នៅជិតចំការនេះ ដែលតម្លៃ វាថ្លៃជាងទីផ្សារខ្លាំងណាស់ ដោយសារទីនោះផ្សារនៅឆ្ងាយពីចំការពេក។

ប្អូនស្រីនិងកម្មករផ្សេងទៀតក៏ធ្លាប់ស្នើរសុំក្រុមហ៊ុន ដើម្បីជួយសម្រួល និង ដោះស្រាយបញ្ហាមួយចំនួនខាងលើដែរ។ ប្អូនស្រីលើកឡើងថា "*ធ្លាប់ស្នើអីទៅកាន់ក្រុមហ៊ុនចឹង គាត់អត់ដែរគិតគូរទេ ធ្លាប់ស្នើបន្ទប់ទឹក ហើយហ្នឹងសំយ៉ាបមុខផ្ទះ លឺថាគាត់ធ្វើៗ តែប៉ុន្មានឆ្នាំហើយ អត់ដែលឃើញធ្វើផង។ តាំងពីអ្នកនៅមុនខ្ញុំទៀតគេថា ធ្លាប់ស្នើហើយ គេថាពីរ ឬបីខែទៀតគេធ្វើ កន្លះខែទៀតធ្វើ មួយឆ្នាំទៀតធ្វើ ពេលមកដល់ឥឡូវ ហ្នឹងអត់មាន អីសោះ។*" បច្ចុប្បន្ននេះ កម្មករនៅក្នុងចំការកៅស៊ូមិនទាន់មាន បសស នៅឡើយទេ សព្វថ្ងៃនេះកម្មករបាន ប្រមែលប្រមូលគ្នាចុះឈ្មោះ ដើម្បីស្នើក្រុមហ៊ុនអោយធ្វើ និងបង់បបសសម្រាប់កម្មករនៅថ្ងៃខាងមុខ។ ប្អូនស្រីបានរៀបរាប់អំពីការប្រមែលប្រមូលគ្នា និងមូលហេតុ ដែលចង់បានបសសថា "*ពួកខ្ញុំបានប្រមែល ប្រមូលគ្នាជាង១០នាក់ដែរហើយ តែយើងមិនទាន់បាន និយាយជាមួយថៅកែទេ ចាំប្រមូលគ្នាបានក្រែល បន្តិចចាំយើងចុះទៅនិយាយតែម្តង។ ខ្ញុំចង់បានបសសចឹង ព្រោះចង់អោយក្រុមហ៊ុនមានច្បាប់ទម្លាប់ កុំអោយមាន ការជិះជាន់ពលកម្មដល់កម្មករ និយាយទៅ គឺខ្ញុំចង់បានសន្តិភាព។ មួយវិញទៀតខ្ញុំចង់អោយខាងក្រុមហ៊ុនគេជួយគិតគូរពីរឿង បសស ហ្នឹងដែរ ដល់ពេលកម្មករឈឺចឹងពួកគាត់ទៅពេទ្យលុយខ្លួនឯង ណាមួយទៅពេទ្យហ្នឹងអត់បានធ្វើការត្រូវអត់ថ្លៃឈ្នួលហើយ។ ហើយកម្មករត្រូវចំណាយច្រើន ណាមួយម្ហូបអីក៏ថ្លៃ គាត់ធ្វើការបានតែមួយហូបចុកទេ គាត់អត់សល់អីបានច្រើនទេ គាត់សល់បានតិចតួច។ អ្នកខ្លះពេលឈឺ ជួនឈឺមួយគ្រួសារតគ្នា ដល់ពេលចឹងទៅលុយធ្វើការហ្នឹងមានអីសល់*"។

ជាចុងក្រោយ គន្ធាសូមលើកជាសំណូមពរទៅដល់ក្រុមហ៊ុនថា "*អោយជួយសម្រួល ដូចជាកន្លែងស្នាក់នៅអោយបានសមរម្យ ទឹកភ្លើងល្អជាងមុនបន្តិច ហើយហ្នឹងសម្រួលការបើកលុយអោយទៀងទាត់ ដូចជាផ្លូវធ្វើអោយស្អាត ព្រោះពេលចេញមកក្រៅ ផ្លូវពិបាកណាស់ ភក់ចង់លិចម៉ូតូ ឬពាក់កណ្តាលម៉ូតូហើយ។ ខ្ញុំចង់បានផ្លូវធ្វើដំណើរ អោយស្រួលព្រោះពេលឈឺថ្កាត់អីម្តងៗ យើងមកពេទ្យមិនយឺតដំណើរ ហើយហ្នឹងសុំអោយប្រាក់ថ្ងៃហ្នឹង ឡើងបន្តិចទៅ ម៉ោងអីហ្នឹងសុំអោយដូចមនុស្សប្រុសទៅ ដូចថា រាល់ថ្ងៃប្រុសចេញម៉ោង៤ គត់ ស្រីចេញម៉ោង៤ ២០នាទី។ គេអោយស្រីៗចេញក្រោយប្រុសៗ២០នាទី គេថាដោយសារការងារស្ត្រីអត់សូវធ្ងន់ដូចប្រុស តែពេលស្រីធ្វើការប្រុសមិនថាផងទេ*"។

















"ដាក់ជីហ្នឹងគឺចូកហ្នឹងដៃយើងហ្នឹង ហើយអត់មានអីពាក់ទេ បើយើងអាចមាន ស្រោមដៃកៅស៊ូដូចគេពាក់ធ្វើសំណង់ហ្នឹងខ្លួនឯង យើងអាចពាក់បាន តែក្រុមហ៊ុន អត់បានអោយទេ។ បើអ្នកអត់មានស្រោមដៃ ប្រើដៃផ្ទាល់ហ្នឹងចូក ពេលចូកហើយដៃ ឡើងហើមប៉ុនៗមេជើង វាអត់ឈឺអីទេ ប៉ុន្តែវារីក ហើមដៃ ប្រហែលមួយថ្ងៃអីហ្នឹងបាត់ ហើយ យើងអាចលាងទឹកអោយខ្លាំងតិចទៅលែងអីហើយ។ ពេលខ្លះដៃហ្នឹងមាន របក ឬរមាស់ ចេញកន្ទួលៗដូចចែងថ្ងៃលើដៃចឹង"

**សម្រង់សម្ដីពីសាច់រឿងទី ៤**




DIOR

# សាច់រឿងទី៤

## ប្អូនស្រីថៃលស្រីពៅជាកម្មករនៅក្រុមហ៊ុនចំការចេក

ស្រីពៅបានចាកចេញពីស្រុកកំណើត មកធ្វើការជាកម្មករនៅក្នុងក្រុមហ៊ុនចំការចេកមួយកន្លែងនៃភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ជីវិតជាកម្មករនៅក្នុងចំការចេក ស្រីពៅត្រូវក្រោកតាំងពីម៉ោង ៤កន្លះព្រឹក ដើម្បីដាំបាយ ធ្វើម្ហូប សម្រាប់អាហារពេកព្រឹក និងថ្ងៃត្រង់។ ប្អូនស្រីត្រូវទៅដល់ចំការអោយបានមុនម៉ោង ៦កន្លះព្រឹក ដើម្បីចាប់ផ្តើមការងារ។ ក្រុមហ៊ុនអនុញ្ញាតឲ្យ សម្រាកបាយថ្ងៃត្រង់នៅម៉ោង១១ព្រឹក និងចូលធ្វើការវិញនៅម៉ោង ១ថ្ងៃនិងបញ្ចប់នៅម៉ោង៤កន្លះល្ងាច។ ពេលចេញពីធ្វើការងារវិញ ស្រីពៅ និងមិត្តរួមបន្ទប់ឆ្លៀតបោកខោអាវដាំបាយស្ល លាងចាន និងពេលខ្លះរៀបចំបន្ទប់គេង។ ក្រុមហ៊ុនបានផ្តល់អោយកន្លែងស្នាក់នៅដែលមានផ្ទះរៀបជាបន្ទប់សង់ឡើងពីដែក មានភ្លើងអគ្គីសនី និងទឹកក្នុងការប្រើប្រាស់។ តែទោះយ៉ាងណាក៏ដោយក៏មិនមានការផ្តល់ជូនបន្ទប់ទឹក និងបង្គន់អនាម័យសមរម្យ ទាំងនៅកន្លែងស្នាក់នៅ និងកន្លែងធ្វើការងារ។ ត្រង់ចំណុចនេះស្រីពៅបានលើកឡើងថា "*ពួកយើងគ្មានបន្ទប់ទឹកប្រើទេ យើងត្រូវទៅបន្ទោរបង់នៅក្រៅឆ្ងាយ និងទៅត្រូវមានគ្នាទៅជាមួយព្រោះទីនោះស្ងាត់ណាស់។ ជួនពេលខ្លះយើងឈឺពោះរាគអីចឹង ហើយសុំគេចេញទៅច្រើនដងពេក គេស្តីអោយថាចេញទៅច្រើនចឹងម៉េចក៏មិនឈប់ម៉ងទៅ។ ទឹកអីពេលខ្លះប្រើអត់គ្រប់គ្រាន់ទេ ទឹកប្រើហ្នឹងគឺទឹកអណ្តូងបូមដោយម៉ូទ័រ។ និយាយទៅក្រុមហ៊ុនមានតែផ្ទះ ទឹក និងភ្លើងអគ្គីសនីអោយយើង តែគ្រឿងរបស់របរ មុងភួយ ចានឆ្នាំង ប្រើប្រាស់ផ្សេងៗក្នុងផ្ទះយើងត្រូវចំណាយខ្លួនឯងទាំងអស់*"។

នៅក្នុងក្រុមហ៊ុនចំការចេក ការងារត្រូវបានបែងចែកទៅតាមភេទសម្រាប់ការងារមនុស្សប្រុសផ្សេង និងការងារសម្រាប់មនុស្សស្រីផ្សេងដោយគេមើលឃើញថាការងារបុរសមាននឿយហត់ជាង ដូច្នេះហើយប្រាក់ឈ្នួលក៏ខុសគ្នាដែរ។ ផ្ទុយទៅវិញបើទោះជាស្ត្រីដែលបានធ្វើការងារដូចគ្នាទៅហ្នឹងបុរស ក៏ដោយក៏ការគិតប្រាក់ឈ្នួលអោយ កម្មករជាស្ត្រីនៅតែមិនស្មើហ្នឹងកម្មករជាបុរសនោះទេ។ ស្រីពៅជាមនុស្សម្នាក់ដែលអាចធ្វើការងារបានសព្វគ្រប់បែបយ៉ាងនៅក្នុងចំការចេកមួយនេះ មិនថាការងារដែលក្រុមហ៊ុនកំណត់ថាជាការងារសម្រាប់ស្ត្រី ឬការងារដែលក្រុមហ៊ុនកំណត់ថាជាការងាររបស់បុរស។ ការអោយប្រាក់ឈ្នួលទៅបុរសថ្លៃជាងលើការងារ

ដូចគ្នាដែលប្អូនស្រីបានធ្វើក្នុងមួយថ្ងៃ។ ការងារបុរសដែល ប្អូនស្រីអាចធ្វើបានមានដូចជា បើកម៉ូទ័រអូសចេក កាប់ដី បើកទឹកជាដើម ជាក់ស្តែងប្អូនស្រីបានលើកឡើងថា "*ខ្ញុំធ្វើបានគ្រប់មុខ មិនថាការងារប្រុស ឬការងារស្រី ខ្ញុំធ្វើបានទាំងអស់ ហើយគេក៏ប្រើខ្ញុំទាំងអស់ដែរ តែគេគិតថ្លៃអោយប្រុសៗដែលបាញ់ថ្នាំ ឬបើកម៉ូទ័រហ្នឹង បានមួយថ្ងៃ៣៥០០០រៀល តែដូចខ្ញុំជាស្រីហើយបើកម៉ូទ័រដែរ តែបានតែ២៨០០០រៀលធម្មតា ក្រោមប្រុសៗជិតមួយម៉ឺន ហើយការងារហ្នឹងលទ្ធផលសម្រេចអោយក្រុមហ៊ុនបានដូចគ្នា។ ខ្ញុំធ្លាប់សួរនាំមេដែរថា មេម៉េចខ្ញុំបើកម៉ូទ័រអូសចេកដែរ តែអោយខ្ញុំតែ២៨០០០រៀលចឹង តែបើកអោយគេ ៣៥០០០រៀល តែគាត់ឆ្លើយថាមិនដឹងយក៣៥០០០រៀលទៅណាទេ យកតែ២៨០០០រៀលទៅបានហើយ គាត់ថាចឹង។ ហើយខ្ញុំក៏ធ្លាប់ប្រាប់គាត់ដែរថា បើអោយខ្ញុំចឹងទៀតខ្ញុំឈប់ធ្វើហើយ បន្ទាប់មកគាត់ថា បើចឹងទៅកាច់ផ្កាចេកវិញទៅ តែពេលណាដែលអត់អ្នកបើកម៉ូទ័រគាត់អោយខ្ញុំមកវិញដដែល ហើយលុយអោយដដែលដូចគ្នា ហើយថាបើខ្ញុំអត់ធ្វើទេ ឈប់ទៅ។ ហើយរឿងបើកទឹកក៏ចឹងដែរ បើគាត់អោយគេ៣៣០០០រៀល តែអោយខ្ញុំតែ២៨០០០រៀលទេ ហើយថ្លៃសាំងម៉ូតូជិះបើកទឹកហ្នឹង មួយថ្ងៃអស់២លីត្របាត់ហើយព្រោះចំការធំណាស់*"។ នៅក្នុងការងារសម្រាប់បុរសមានតែការបាញ់ថ្នាំមួយប៉ុណ្ណោះ ដែលស្រីពៅ អត់ព្រមធ្វើ ព្រោះស្រីពៅប្រាប់ថា "*ខ្ញុំងាយហ្នឹងប្រតិកម្មថ្នាំ បាញ់ថ្នាំហ្នឹងយើងស្លរៀកពាក់ធម្មតា*"។  នៅក្នុងចំការការងារនីមួយៗសុទ្ធតែប្រឈមហ្នឹងគ្រោះថ្នាក់ ហើយក្រុមហ៊ុនមិនផ្តល់សម្ភារៈនិងឯកសណ្ឋានក្នុងការការពារខ្លួននោះទេ សម្រាប់កម្មករដែលត្រូវបាញ់ថ្នាំចេក ថ្នាំស្មៅ ចាក់សូយោង ក្រុមហ៊ុនគ្មានខោអាវការពារអោយទេ បើកម្មករមានសមត្ថភាព គេទិញខ្លួនឯង បើអត់មានទេ គឺពាក់តែខោអាវធម្មតា។ ដើម្បីការការពារខ្លួន ពីការសាចទឹកថ្នាំត្រូវ មានកម្មករមួយចំនួនបានចំណាយលុយខ្លួនឯងក្នុងការទិញសម្ភារះខ្លះមកប្រើប្រាស់ មានដូចជាអាវភ្លៀង មានម៉ាស់ និងស្បែកជើងករវែង។ មួយវិញទៀតសូម្បីតែសម្ភារៈដែលប្រើប្រាស់នៅក្នុងការ ធ្វើការងារនៅក្នុងចំការក៏ដោយ ក៏ក្រុមហ៊ុនគ្មានគ្រប់គ្រាន់អោយដែរ ដូចជា កណ្តៀវកាត់ស្លឹកចេកវាឡើងសឹងមុខអស់ កាត់លែងចង់មុតហើយ ក៏ក្រុមហ៊ុនមិនទិញថ្មីអោយដែរ និងធុងបាញ់ថ្នាំ ដែលពីមុនក្រុមហ៊ុនមានអោយ តែកម្មករត្រូវទិញអាគុយដាក់ខ្លួនឯង ហើយអាគុយហ្នឹងមួយ៨ម៉ឺនរៀល វាជិតស្មើថ្លៃឈ្នួលរបស់កម្មករពីរថ្ងៃហើយ។ ហើយពេលនេះកម្មករត្រូវធុងបាញ់ថ្នាំទិញខ្លួនឯងទៀត សម្រាប់តម្លៃធុងបាញ់ថ្នាំមួយគឺមានតម្លៃ១៤ម៉ឺនរៀល ។ សម្រាប់ការងាររបស់កម្មករជាស្ត្រីនៅក្នុងចំការមានដូចជាកាច់ផ្កាចេក កាត់ស្លឹកចេកដោលស្លឹក ដែលធ្លាក់ចេញពីសូយោងមក អោយវាទៅលើ បញ្ឈិតវាកុំអោយវាបាំងផ្លែ កាយស្លរឹក អូសទុយោរបាញ់ថ្នាំ ដាក់ជី និងកូរជីក្នុងឃ្លាំង។ មិនថាការងារអ្វីនោះមនុស្សស្រីបានមួយថ្ងៃ

ត្រឹមតែ២៨០០០រៀលប៉ុណ្ណោះ។ ហើយការងារនីមួយៗក៏មានគ្រោះថ្នាក់ដែរ ដូចជាការកូរជីក្នុងឃ្លាំង ដាក់ជី កាច់ផ្កាចេក អូសទោយូបាញ់ថ្នាំ ស្រីពៅបាននិយាយថា "*ដាក់ជីហ្នឹងគឺចូកហ្នឹងដៃយើងហ្នឹង ហើយអត់មានអីពាក់ទេ បើយើងអាចមានស្រោមដៃកៅស៊ូដូចគេពាក់ធ្វើសំណង់ហ្នឹងខ្លួនឯង យើងអាចពាក់បាន តែក្រុមហ៊ុនអត់បានអោយទេ។ បើអ្នកអត់មានស្រោមដៃ ប្រើដៃផ្ទាល់ហ្នឹងចូក ពេលចូកហើយដៃឡើងហើមប៉ុនៗមេជើង វាអត់ឈឺអីទេ ប៉ុន្តែវារីក ហើមដៃ ប្រហែលមួយថ្ងៃអីហ្នឹងបាត់ហើយ យើងអាចលាងទឹកអោយខ្លាំងតិចទៅលែងអីហើយ។ ពេលខ្លះដៃហ្នឹងមានរបក ឬរមាស់ ចេញកន្ទួលៗដូចចែងថ្ងៃលើដៃចឹង*"។ កម្មករនៅក្នុងចំការនិងស្រីពៅមិនដឹងថាជី ដែលខ្លួនប៉ះពាល់រាល់ថ្ងៃនេះ វាមានផលអាក្រក់អ្វីខ្លះដល់ពួកគាត់នៅថ្ងៃខាងមុខនោះទេ ព្រោះពួកគាត់ជាកម្មករ ធ្វើការដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ យ៉ាងណាក៏ត្រូវតែធ្វើដែរ។ តាមការសង្កេតឃើញរបស់ប្អូនស្រី ជីដែលដាក់នៅគល់ចេក វាបានធ្វើអោយចេកឆាប់ធំ វាកាត់រោគចេក ធ្វើអោយចេកមានសុខភាពល្អ។ សម្រាប់ថ្នាំដែលបាញ់នៅលើផ្លែចេក វាបានធ្វើអោយផ្លែចេកឆាប់ធំល្អ គ្មានការបំផ្លាញពីសត្វល្អិតតូចៗ។ នៅក្នុងអំឡុងពេលដែលគេបាញ់ថ្នាំលើផ្លែចេកនេះដែរ ក៏ពេលជាដែលកម្មករជាស្ត្រី ត្រូវដើរកាច់ផ្កាចេកតាមក្រោយផងដែរ ដើម្បីអោយទាន់ពេលវេលា ស្រីពៅបានបន្តថា "*ពេលគេបាញ់ថ្នាំលើផ្លែហើយ យើងត្រូវកាច់ផ្កាចេកតាមក្រោយ ជួនកាលពេលគេប្រញាប់ខ្លាំង អ្នកបាញ់បណ្តើរ គេទៅមុខចឹង យើងដើរកាច់ភ្លាមៗ ក្រោយគេហ្នឹងតែម្តង ហើយទឹកថ្នាំដែលបាញ់លើផ្លែហ្នឹង វាហូរមិនទាន់ស្ងួត វាចូលក្រចកដៃ ហើយគេអត់អោយយើងពាក់ស្រោមដៃទេ គេខ្លាចខូចផ្លែចេកគេ។ ថ្នាំហ្នឹងវាប៉ះផ្ទាល់ដូចយើងកាន់ទឹកថ្នាំលេងធម្មតាហ្នឹង*"។ កន្លងមកមានកម្មករមួយចំនួនតូចធ្លាប់ពុលថ្នាំ តែនៅក្នុងកម្រិតស្រាល គាត់គ្រាន់តែមានអារម្មណ៍ថាវិលមុខ អស់កម្លាំង ក្អួត តែក៏បាត់ទៅវិញបន្ទាប់ពីគេផឹកទឹកក្តៅជាមួយទឹកឃ្មុំ និងក្រូចឆ្មា។ ហើយក៏មានកម្មករមួយចំនួនក៏ធ្លាប់ ថ្នាំចូលភ្នែក ធ្វើអោយក្រហាយភ្នែក ១ ទៅ២ថ្ងៃ ទើបបាត់វិញ។ មានអ្នកខ្លះទៀតត្រូវថ្នាំសាចត្រូវខ្លួនធ្វើអោយរមាសខ្លាំង។ នេះគ្រាន់តែជាផលប៉ះពាល់ដែលកើតឡើងភ្លាមៗ ពេលដែលកម្មករបានប៉ះពាល់ថ្នាំ តែនៅថ្ងៃក្រោយ មិនដឹងថាមានផលប៉ះពាល់អ្វីខ្លះទៀតទេ ដល់ពួកគាត់។ ស្រីពៅបានប្រាប់ថា "*តែងបារម្ភពេលខ្ញុំចាស់ទៅ ខ្ញុំអាចហ្នឹងមើលលែងឃើញ ព្រោះពេលគេបាញ់ថ្នាំហើយយើងត្រូវទៅកាត់ផ្កាចេកភ្លាម ចឹងថ្នាំអាចចូលភ្នែក។ ខ្ញុំបារម្ភតែភ្នែក ដូចមិត្តភក្តិខ្ញុំនោះក៏គាត់មានបញ្ហាភ្នែកដែរ គាត់កំពុងតែមើលអត់សូវឃើញ គាត់រាងស្រវាំងៗ មើលឆ្ងាយគាត់មើលអត់សូវច្បាស់ទេ តែគាត់អូសទុយោរ ពេលគេបាញ់ថ្នាំស្លរឹក គាត់អាចហ្នឹងចូលថ្នាំហ្នឹងគាត់អាចហ្នឹងពិបាកជាងហ្នឹង*"។

សម្រាប់កម្មករជាស្ត្រី មានរឿងដែលពិបាកមួយជារៀងរាល់ខែនោះគឺការមករដូវ ប្អូនស្រីបានប្រាប់ថា "*ពេលយើងមកចឹងវាឈឺពោះ និងឈឺចង្កេះណាស់ តែក៏មិនហ៊ានឈប់ដែរ ព្រោះខ្លាចអត់អីហូប តែពេលទៅធ្វើទៅយើងឈឺខ្លាំងពេក ឈរបន្តិចឬអង្គុយបន្តិចអី តែគេឃើញ គេស្តីអោយយើងហើយ គេថាបើមកឈរដដែលឈប់ល្អជាង*"។ មានបងប្អូនស្រីកម្មករមួយចំនួន គាត់មានការបារម្ភពីបញ្ហារោគស្ត្រីរបស់ពួកគាត់ ដែលបានកើតបន្ទាប់ពីមកធ្វើការនៅក្នុងចំការ ព្រោះពីមុនមកមិនដែលមានបញ្ហាអីនោះទេ។ ជាធម្មតានៅពេលដែលកម្មករ នៅក្នុងចំការមាន បញ្ហាសុខភាពផ្សេងៗ ពួកគាត់មិនសូវមានអ្នកទៅទទួលការព្យាបាលនៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យនោះទេ ព្រោះពួកគាត់ខ្លាចខាតពេលវេលា បាត់បង់ចំណូល និងអស់លុយថ្លៃព្យាបាល ថែមទៀតផង។ ស្រីពៅលើកឡើងថា "*អត់ដែលមានអ្នកណាទៅពេទ្យអីផង ព្រោះអីយើងខ្លាច ខាត បើសិនជាយើងឈប់ថ្ងៃហ្នឹង យើងអត់មានប្រាក់ចំណូលចូលនោះទេ ព្រោះក្រុមហ៊ុនមិន គិតថ្លៃឈ្នួលអោយ ពេលដែលយើងអត់ទៅធ្វើការ ណាមួយនៅហ្នឹងកម្មករភាគច្រើនរកមួយថ្ងៃ ចាយមួយថ្ងៃ បើអ្នកគេរិះចាំទៅគេរកមួយថ្ងៃ គេអាចសល់ខ្លះទុកសន្សំឬទៅផ្ញើកូន ឬអ្នកផ្ទះចឹង ទៅ។ បើឈឺថ្កាត់តិចតួចអី នៅមើលខ្លួនឯង មានទិញថ្នាំប៉ាណាឌុល ថ្នាំបាត់ឈឺក្បាល ថ្នាំបាត់ រាគ មួយបន្ទះៗទុកលេបខ្លួនឯង ទាល់តែឈឺខ្លាំងទៅលែងរួចបានខ្ចីលុយគេទៅពេទ្យតែម្តង ហើយការខ្ចីគេហ្នឹងការប្រាក់ដល់ទៅ ១៥%នៃលុយដើមទៀត*"។ ក្នុងការឆ្លើយតបទៅហ្នឹង បញ្ហាផ្សេងៗដែលបានលើកឡើងខាងលើ ស្រីពៅបានរៀបរាប់នៅតម្រូវការមួយចំនួនដែលចង់ អោយក្រុមហ៊ុនផ្តល់អោយ កម្មករទាំងអស់គ្នា ថា "*សូមអោយមានសម្ភារៈការពារកុំអោយត្រូវថ្នាំ ច្រើនពេក អោយពេលធ្វើការឃ្លាតឆ្ងាយពីគេបាញ់ថ្នាំ ជាងហ្នឹង ព្រោះអីឥលូវ វាច្របូកច្របល់គ្នា ខ្លាំង។ ហើយចង់អោយមានសម្ភារៈគ្រប់គ្រាន់ កុំអោយទិញសម្ភារៈ ចេញលុយខ្លួនឯង ប្រើប្រាស់ ក្នុងក្រុមហ៊ុន។ បើពេលខ្ញុំបើកទឹក សូមអោយក្រុមហ៊ុនចេញលុយថ្លៃសាំងអោយ។ ហើយសម្រាប់ ការបញ្ឈប់ការងារ សូមអោយមេដែលធំជាងខ្ញុំហ្នឹង ពេលបញ្ឈប់ខ្ញុំសូមអោយមានហេតុផល ច្បាស់លាស់ជាងហ្នឹងតិច ខ្ញុំអត់ចូលចិត្តអោយបញ្ឈប់ឆៅ ដោយអត់មានហេតុផលចឹងទេ។ ខ្ញុំ អត់ចិត្តខ្លាំងណាស់ ដែលខ្មែរគ្នាឯងហ្នឹង ធ្វើអោយខ្មែរគ្នាឯងឈប់។ ខ្ញុំធ្លាប់តែឃើញ និងលឺ ថា ចិន ឬវៀតណាម ដែលធ្វើចឹងមកលើកម្មករខ្មែរ តែឥលូវជួបហើយខ្មែរធ្វើចឹងមកលើខ្មែរ។ ចឹង អោយក្រុមហ៊ុនធ្វើប័ណ្ណ បង់ប.ស.សអោយកម្មករ នៅចំការចេកអោយបានគ្រប់គ្នា ព្រោះអីអ្នក នៅចំការចេកហ្នឹងភាគច្រើនគាត់ចាស់ៗហើយ*"។

# ការធ្វើបច្ចុប្បន្នភាព ស្ថានភាពរបស់ក្រុមស្ត្រី ជាកម្មករនៅក្រុមហ៊ុនចំការចេក និងកៅស៊ូ

ក្រុមស្ត្រីជាកម្មករនៅក្រុមហ៊ុនចំការចេកនិងកៅស៊ូ ជាក្រុមមួយដែលបានចងក្រងបង្កើតឡើងតាំងពីខែសីហា ឆ្នាំ២០២៣ ពីតំណាងស្ត្រីដែលជាកម្មករមានសមាជិក ១០នាក់ បានចូលរួមជាសមាជិកសហជីពតំណាងកម្មករនៅក្នុងក្រុមហ៊ុនចំនួន០២កន្លែង នៅក្នុងខេត្តក្រចេះ។ នៅ ខែមករា ឆ្នាំ២០២៥ កន្លងទៅ ក្រុមស្ត្រី បានចូលរួមជជែកពិភាក្សាជាលក្ខណៈក្រុម ដើម្បីធ្វើបច្ចុប្បន្នភាពទៅលើការផ្លាស់ប្តូរ ស្ថានភាព និងតម្រូវការរបស់ពួកគាត់ បន្ទាប់ពីសមាជិក ០៤នាក់ធ្លាប់លើកឡើងនូវសាច់រឿងពិត របស់គាត់នៅក្នុង សៀវភៅ ទឹកភ្នែកពណ៌ស

## តួនាទី និងការទទួលខុសត្រូវ

បច្ចុប្បន្នសមាជិកខ្លះ មានតួនាទីជាសមាជិក ហិរញ្ញឹក និងជាប្រធានសហជីពជាដើម។ នៅក្នុងតួនាទីមួយនៅក្នុងសហជីព លោកស្រីជាប្រធានសហជីពម្នាក់ បានលើកឡើងថា “ខ្ញុំបានចូលរួមកិច្ចប្រជុំជាមួយសហជីពផ្តល់ព័ត៌មានផ្សេងៗដល់សមាជិកនៅក្នុងក្រុម និងចូលរួមក្នុងការជជែកជាមួយក្រុមសហជីព អំពីបញ្ហា និងតម្រូវការ  ផ្សេងៗ ដើម្បីជម្រុញអោយលក្ខណៈការងាររបស់កម្មករបានល្អប្រសើរ”។

## ការចូលរួមនិងការផ្លាស់ប្តូរជាវិជ្ជមាន

ចំណុចដែលបានលើកឡើងពីការផ្លាស់ប្តូររបស់ក្រុមស្ត្រី សុទ្ធសឹងជាតម្រូវការដែលក្រុមស្ត្រីលើកឡើងនៅពេលចូលរួមជាមួយជាក្រុមស្ត្រីដំបូង។ នៅពេលដែលក្រុមស្ត្រី គាត់ទទួលបានព័ត៌មានច្រើន ធ្វើអោយពួកគាត់ក្លាហាន ហ៊ានជជែក និងសាកសួរមេការ ឬក្រុមហ៊ុនពីព័ត៌មានមួយចំនួនដែលគាត់ពួកមិនច្បាស់លាស់។ ក្រៅពីការចូលរួមជាមួយសហជីព ក្រុមស្ត្រីបានចូលរួម កិច្ចប្រជុំ សិក្ខាសាលា វេទិកា និងវគ្គបណ្តុះបណ្តាល ដែលរៀបចំឡើងដោយ

អង្គការ និងស្ថាប័ន ក្នុងគម្រោង បរិយាប័ន្នខ្សែច្រវាក់តម្លៃកសិកម្ម។ នៅក្នុងកម្មវិធីដែលក្រុមស្ត្រី បានចូលរួម ក្រុមស្ត្រីក៏មានឱកាសបានជួប រៀនសូត្រ និងទទួលព័ត៌មាន ពីតំណាងអ្នកពាក់ព័ន្ធ ដូចជាតំណាងមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បេឡាជាតិសន្តិសុខសង្គម(ប.ស.ស) ក្រុមប្រឹក្សាខេត្ត តំណាងក្រុមហ៊ុនចំការចេក និងកៅស៊ូផ្សេងៗ ក្រុមសហគមន៍តាមវិស័យ និងអង្គការសង្គមស៊ីវិលជាដើម។ តាមរយៈឱកាសដែលបានចូលរួមទាំងអស់នោះ បានធ្វើអោយក្រុមស្ត្រី មានការផ្លាស់ប្តូរ ទាំងចំណេះដឹង ព័ត៌មាន ទំនុកចិត្ត ភាពក្លាហាន និងទំនាក់ទំនង ក្នុងនោះក្រុមស្ត្រីបានលើកឡើងថា “ខ្ញុំបានដឹងពីព័ត៌មាននៃអត្ថប្រយោជន៍ របបបេឡាជាតិសន្តិសុខសង្គម ដែលយើងមាន និងដឹងថាក្នុងនាមយើងជាកម្មករដែលធ្វើការដូចពួកយើងចឹង ក្រុមហ៊ុនត្រូវបង់ប.ស.ស អោយកម្មករ។ ខ្ញុំទទួលបានព័ត៌មាន និងយល់ដឹងពីច្បាប់ការងារ”។ ដឹងថាមានក្រុមហ៊ុនផ្សេងគេបានអនុវត្តន៍លើច្បាប់ការងារ និងធ្វើអោយកម្មករទទួលបានប្រយោជន៍ប្រសើរជាងក្រុមហ៊ុនដែលខ្ញុំកំពុងធ្វើការ ដូចជាមានបង់ ប.ស.ស អោយកម្មករមានប្រាក់អតីតភាពការងារ និងប្រាក់លើកទឹកចិត្តជាដើម”។ ក្រុមស្ត្រីបានបន្តថា “ ខ្ញុំបានស្គាល់គេឯងច្រើនជាងមុន ជាពិសេសបងដែលតំណាងមកពី ប.ស.ស ដែលខ្ញុំមានឱកាសជម្រាបគាត់ពីស្ថានភាពនៃ ប.ស.ស នៅកន្លែងខ្ញុំ។ ខ្ញុំសង្ឃឹមហ្នឹងទទួលបាន ប.ស.ស ដូចកម្មករដែលនៅចំការមួយទៀត”។ ក្រុមស្ត្រីបានបន្ថែមថា “ខ្ញុំអាចស្វែងយល់ពីខ្លួនឯង ស្គាល់ពីខ្លួនឯង ហ្នឹងមានភាពក្លាហាន និងហ៊ាននិយាយខ្លាំងជាងមុន។ ពីមុនខ្ញុំមិនហ៊ានជជែក ឬសួរនាំមេការនោះទេ តែពេលនេះខ្ញុំហ៊ានសួរនាំ ពីរឿងរ៉ាវមួយចំនួនបានច្រើនជាងមុន។ លើសពីនោះ ពេលបានជួបក្រុមស្ត្រី និងបុគ្គលិកខាងអង្គការសីលការ ខ្ញុំមានអារម្មណ៍ថាកកក្តៅ និងធូរស្រាលក្នុងចិត្ត មិនណែនក្នុងអារម្មណ៍ ព្រោះបានចែករំលែកពីរឿងនៅក្នុងចិត្ត។ ខ្ញុំសប្បាយចិត្តដែលក្រុមស្ត្រីយើងចេះដឹងច្រើន ចេះសួរ ចេះតវ៉ា ដឹងពីតួនាទីការងារ បានច្រើន”។ ភាពផ្លាស់ប្តូរជាវិជ្ជមានរបស់ក្រុមស្ត្រី ក៏បានធ្វើអោយគ្រួសារសប្បាយចិត្ត និងមានការគាំទ្រ ជាក់ស្តែងក្រុមស្ត្រីបានលើកឡើងថា “គ្រួសារខ្ញុំគាត់គាំទ្រ មិនដែលថាអីនោះទេ ពេលឃើញខ្ញុំអាចនិយាយជាមួយមេការ ឬមេឡូរបាន ពួកគាត់កាន់តែសប្បាយ គាត់ថាកុំអោយខ្លាចគេ។ តែសម្រាប់កម្មករមិនចូលរួមជាមួយសហជីព គេមិនសូវហ៊ាននិយាយចូលពួកខ្ញុំទេ ព្រោះគេខ្លាចខាងមេ គិតថាគេចូលរួមជាមួយខ្ញុំ។ សម្រាប់ក្រុមហ៊ុន មេការ អ្នកថ្នាក់លើ គេមិនពេញចិត្តក្នុងការអោយកម្មករមានសហជីពនោះទេ។ ពេលខ្លះសុំច្បាប់គេរឿងផ្ទាល់ខ្លួន ក៏គេថាយើងទៅចូលរួមប្រជុំ សិក្ខាសាលា ជាមួយក្រុមសហជីពដែរ។ គេមិនសូវចូលចិត្តពួកយើងនោះទេ”។ ត្បិតតែការចូលរួមរបស់ក្រុមស្ត្រី មានការរើសអើងពីកម្មករដូចគ្នា និងក្រុមហ៊ុនក្តី តែពួកគាត់នៅចង់បន្តធ្វើជាមួយក្រុមសហជីព និងក្រុម

ស្ត្រីដដែល ជាក់ស្តែងក្រុមស្ត្រីលើកឡើងថា“ខ្ញុំមិនដែលគិតថាចង់បោះបង់នោះទេ ការងារនេះបានជួយខ្ញុំច្រើនណាស់ បានដឹងពីច្បាប់ច្រើន គេមិនសូវមើលងាយយើង ហើយយើងមានហេតុផលនិយាយជាមួយគេបាន”។

## វឌ្ឍនៈភាពនៃការផ្លាស់ប្តូរលើបញ្ហា និងតម្រូវការ

ស្ថានភាពកម្មករនៅក្នុងក្រុមហ៊ុនទី១ ដែលកម្មករជាក្រុមស្ត្រី ចំនួន ០៨នាក់ធ្លាប់បានលើកឡើងនៅក្នុងសាច់រឿងពិត ពាក់ព័ន្ធហ្នឹង បន្ទប់ទឹកនៅកន្លែងធ្វើការនិងស្នាក់នៅឯកសណ្ឋាន និងសម្ភារៈសម្រាប់ការពារពេលធ្វើការងារ ថ្លៃឈ្នួលស្មើគ្នាសម្រាប់កម្មករស្រី និងប្រុសលើប្រភេទការងារដូចគ្នា និងពេលវេលាស្មើគ្នា ចុះបញ្ជីបេឡាជាតិសន្តិសុខសង្គម និងបង់ជូនកម្មករគ្រប់គ្នា និងអោយក្រុមហ៊ុនគោរពច្បាប់ការងារចំពោះកម្មករជាដើម។ ជុំវិញរឿងនេះកម្មករជជែក និងបានលើកឡើងថា “ពិបាកអោយក្រុមហ៊ុនធ្វើតាមណាស់ ព្រោះពេលចូលរួមសិក្ខាសាលាផ្សេងៗ ដែលអង្គការបានរៀបចំ មានអញ្ជើញក្រុមហ៊ុនចូលរួម ខ្ញុំមិនដែលឃើញតំណាងក្រុមហ៊ុនខ្ញុំចូលរួមនោះទេ ឃើញមានតែក្រុមហ៊ុនគេទៅ។ ហើយបើមានដំណឹងថាហ្នឹងមានខាងរដ្ឋ ឬអ្នកខាងក្រៅចុះទៅទៀតនោះ គឺមេអោយកម្មករ ៣ ទៅ ៤នាក់ទៅធ្វើជាអ្នកកាប់ព្រៃ ឬធ្វើស្មៅនៅម្តុំផ្លូវហើយ ហើយបើឃើញមានអ្នកជិះចូលមកចម្លែក មេអោយប្រាប់ទៅគាត់ភ្លាម។ គេអាចខ្លាចថាមានអ្នកចុះពិនិត្យ និងត្រូវអោយគេធ្វើនេះ ឬធ្វើនោះ។ ...សម្រាប់ ប.ស.ស កម្មករកន្លែងខ្ញុំមិនទាន់បានប្រើនោះទេ។ បន្ទាប់ពីទៅចូលរួមសិក្ខាសាលានៅខែតុលា ២០២៤ ពេលនោះបានជជែករឿង ប.ស.ស ជាមួយបងខាងតំណាង ប.ស.ស ហើយពេលមកធ្វើការវិញ ខាងមេការមកសុំថតអត្តញ្ញាណប័ណ្ណ កម្មករខាងចេក ៤នាក់ និងកៅស៊ូ៦នាក់ សរុប១០ នាក់ថាយកទៅធ្វើប័ណ្ណ ប.ស.ស អោយ។ ប្រហែលជាខាង ប.ស.ស បាននិយាយជាមួយក្រុមហ៊ុនហើយយ៉ាង។ ពេលនោះសប្បាយចិត្តណាស់ ថាជិតបានហើយ តែមកដល់ពេលនេះ នៅតែមិនទាន់បានទៀត។ ធ្លាប់កាលពីច្រើនខែមុន ក៏ធ្លាប់ខាងមេការថតអត្តសញ្ញាណប័ណ្ណ កម្មករ ៤ ៥ នាក់ដែលធ្វើការយូរឆ្នាំ ហើយប្រាប់ថាយកទៅធ្វើ ប.ស.ស ចឹងដែរ តែក៏មិនបានចឹងដែរ។ ...ប្រាក់ឈ្នួលរបស់កម្មករនៅដដែល តាមប្រភេទប្រុស ប្រភេទស្រី និងនៅពេលល្ងាច ក្រុមស្រីត្រូវចេញក្រោយប្រុស ២០នាទីទៀតផង។ យើងធ្វើការគ្មានសៅរ៍ អាទិត្យ ឬបុណ្យនោះទេ មួយអាទិត្យ០៧ថ្ងៃ គឺធ្វើរហូត ពេលសុំច្បាប់ម្តងៗក៏ពិបាកណាស់។...ក្រុមហ៊ុនគ្មានសម្ភារៈអ្វីអោយប្រើប្រាស់ ដើម្បីការពារសុវត្ថិភាពនោះទេ តែក៏ធ្លាប់បានស្នើទៅមេឡូ ពេលខ្លះមេឡូ ក៏យកលុយគាត់ទិញ អោយយើងក៏មាន។ តែមិនធ្លាប់ស្នើទៅក្រុមហ៊ុនទៅដល់ផ្ទាល់ទេ។

...កន្លែងខ្ញុំស្នាក់នៅ និងធ្វើការរាល់ថ្ងៃនៅតែគ្មានបន្ទប់ទឹកក្នុងការប្រើប្រាស់ដដែល ចឹងយើងពិបាកណាស់”។ លើសពីការធ្វើបច្ចុប្បន្នភាព លើតម្រូវការរបស់ក្រុមស្ត្រី គាត់ក៏បានលើកឡើងពីស្ថានភាពដែល បានកើតឡើងនៅពេលក្រោយនេះទៀតផង ក្នុងនោះមាន “ក្រុមហ៊ុនទើបប្រាប់មកកម្មករ ពីច្បាប់ថ្មី ការសុំច្បាប់ឈប់សំរាក ត្រូវសុំមុន០៣ថ្ងៃ បើសុំភ្លាមៗត្រូវកាត់លុយ។ គ្រាន់តែប្រាប់ភ្លាមកាត់លុយភ្លាម ទាំងការឈប់នោះ មុនពេលប្រាប់ច្បាប់ថ្មីសោះហ្នឹង តែយើងក៏ជជែកជាមួយគាត់ តែគាត់មិនកាត់លុយពួកខ្ញុំទេ តែនៅតែកាត់លុយអ្នកផ្សេងដដែល។ ម៉ោងពេលក៏តឹងជាងមុនទៀត និងមានការកំណត់ចំនួន ថាក្នុងមួយថ្ងៃត្រូវអោយហើយក្នុងចំនួនប៉ុន្មាន តែធ្វើអត់គ្រប់ក៏គេកាត់លុយដែរ។ តែបើធ្វើគ្រប់មុនម៉ោងក៏ មិនអោយឈប់មុនដែរ ត្រូវធ្វើរហូតដល់ម៉ោង។ អំឡុងពេលធ្វើការក៏មិនអាចឈប់តិចតួចបានដែរ”។

សម្រាប់ស្ថានភាពនៃក្រុមហ៊ុនទី២ ក្រុមហ៊ុនមួយដែលមានចុះឈ្មោះ និងបង់បេឡាជាតិសន្តិសុខសង្គម អោយក្រុមកម្មករគ្រប់គ្នា ទាំងធានារ៉ាបរងសុខភាព និងសោធននិវត្តន៍។ ការបង់ ប.ស.ស ក្រុមហ៊ុនចេញ៥០% កម្មករចេញ៥០% ជារៀងរាល់ខែ។ នៅក្រុមហ៊ុនមានកន្លែងស្នាក់នៅអោយកម្មករ មានបន្ទប់ទឹក និងសម្ភារះប្រើប្រាស់ក្នុងពេលធ្វើការ។ ក្រុមស្ត្រីដែលជាកម្មករនៅក្នុងចំការនេះបានលើកឡើងថា “កម្មករមាន ប.ស.ស ប្រើពេលទៅពេទ្យមិនអស់លុយទេ គេបង់អោយ។ សម្រាប់ការងារនៅក្នុងក្រុមហ៊ុន មានអ្នកខ្លះគាត់ធ្វើការកៅស៊ូ អ្នកខ្លះទៀតខាងស្វាយចន្ទី។ ពេលផុតរដូវរើសគ្រាប់ស្វាយចន្ទី កម្មករខ្លះ ក៏ធ្វើស្មៅ កាប់ព្រៃ និងអាចទៅធ្វើខាងកៅស៊ូបណ្តោះអាសន្ន តាមការងារដែលមាន និងការចាត់ចែងរបស់មេការ។ ក្រុមស្ត្រីបានចូលរួមថា “ប.ស.ស នៅកន្លែងខ្ញុំមាន ក្រុមហ៊ុនបង់៥០% សាមីខ្លួនបង់៥០%។ សម្ភារះគេបើកអោយរាល់ឆ្នាំ មានស្បែកជើងករវែង អាវបាញ់ថ្នាំ ស្រោមដៃស្រោមជើង និងម៉ាសជាដើម។ ខែនេះគេបានអោយពួកខ្ញុំប៉ុន្មាននាក់ទៅជៀរជ័រកៅស៊ូ តែពួកយើងប្រកែកថាមិនទៅ ព្រោះកម្លាំងពួកខ្ញុំធ្វើមិនដល់នោះទេ អាយុខ្លះសែជាង ហាជាង ហុកជាងអស់ហើយហ្នឹង មានកម្លាំងឯណា ដល់ពេលចឹងគេក៏ថាបើមិនទៅជៀរជ័រទេ មិនបាច់ទៅធ្វើការទៀតចឹង គេដេញចេញហើយ ពួកខ្ញុំក៏រើសអីវ៉ាន់មកនៅផ្ទះ ខ្លះក៏ជួលផ្ទះគេនៅខាងក្រៅសិន ព្រោះចាំក្រែកគេហៅចូលវិញ។ កន្លងមកគេបញ្ឈប់ហើយ គេតែងហៅចូលវិញជានិច្ច ព្រោះខ្វះកម្មករ។ ពេលគេបញ្ឈប់ចឹងពួកខ្ញុំខ្លះក៏បង់ប.ស.ស បន្តខ្លួនឯង ខ្លះទៀតក៏មិនបានបង់ដែរ។ ក្រុមហ៊ុនពេលខ្លះផ្តល់ព័ត៌មានមិនច្បាស់លាស់ កាលពីរដូវកាលរើសគ្រាប់ស្វាយចន្ទីឆ្នាំមុន មានកម្មករមួយចំនួន រួមទាំងពួកខ្ញុំ បានទៅរើសគ្រាប់ចន្ទី ដោយមុនពេលចាប់ផ្តើមខាងមេការក្រុមហ៊ុន ប្រាប់ថារើសបានមួយគីឡូ ៧០០៛ សម្រាប់គ្រាប់ល្អ និងមួយគីឡូ ១០០៛ សម្រាប់គ្រាប់ដែលខូចៗ។ តែដល់ពេលរើស

បានមួយអាទិត្យហើយ ខាងក្រុមហ៊ុនមិនទាន់បើកថ្លៃឈ្នួល អោយទៀត តែគេអាចអោយខ្ចីបានម្នាក់ ១០០០០០៛ ទៅ ១២០០០០៛។ ដល់ពេលរើសជិតអស់ហើយ ក្រុមហ៊ុននៅតែមិនបើកថ្លៃឈ្នួលអោយទៀត ពួកយើងក៏សួរនាំ និងសុំអោយបើកអោយពួកយើងជារៀងរាល់ថ្ងៃរហូតដល់ពេលរើសអស់ហើយ ទើបមេការប្រាប់ថា គ្រាប់ចន្ទីដែលរើសនោះ មួយគីឡូបានតែ៩០រៀលប៉ុណ្ណោះ។ ចឹងហើយខាងក្រុមហ៊ុនមិនត្រូវបើកថ្លៃឈ្នួលអោយទៀតទេ ព្រោះលុយដែលបានអោយខ្ចីនោះ ក៏វាមានចំនួនលើសថ្លៃឈ្នួលត្រូវបានដែរ។ ខ្ញុំ និងកម្មករផ្សេងៗទៀតបានតវ៉ាដែរ តែគ្មានលទ្ធផលអីទេ។ ហើយក្នុងអំឡុងពេលនោះខាងសហជីព ក៏មិនមានកិច្ចប្រជុំអ្វីដែរ ទើបយើងមិនបានសុំការជួយពីពួកគាត់”។

តាមរយៈស្ថានភាពរបស់កម្មករជាក្រុមស្ត្រី នៅតែគ្មានស្ថេរភាព និងមិនទាន់បានឆ្លើយតបទៅហ្នឹងតម្រូវការដែលធ្លាប់ឡើង ក្រុមស្ត្រីនៅតែលើកថា “ចង់អោយក្រុមហ៊ុនបង់ ប.ស.សអោយកម្មករគ្រប់គ្នា មានសម្ភារៈសុវត្ថិភាពភាពប្រើប្រាស់ពេលធ្វើការងារ មានបន្ទប់ទឹកសម្រាប់កម្មករ និងអោយប្រាក់ឈ្នួលស្មើគ្នា។ ចង់អោយក្រុមហ៊ុនផ្តល់ព័ត៌មានអោយកម្មករអោយច្បាស់លាស់ពីថ្លៃឈ្នួលនៃការរើសគ្រាប់ស្វាយចន្ទី និងមិនកេងចំណេញថ្លៃឈ្នួល និងកម្លាំងរបស់កម្មករ។ អាជ្ញាធរចុះត្រួតពិនិត្យ ហើយចុះកុំឱ្យគេដឹង បើគេដឹងគេមិនឱ្យចូលដល់ចំការចេកទេ។ បានត្រឹមតែចូលដល់ក្រុមហ៊ុន តែ ក្រុមហ៊ុន មិនឱ្យចូលដល់ចំការចេកនោះទេ។ ចង់ឱ្យសហជីពជួយដោះស្រាយ ការបញ្ឈប់ការងាររបស់កម្មករផង”។







"ឆ្នាំនេះម្រាមដៃខ្ញុំ ចាប់ផ្ដើមរបក ដោយសារជ័រត្រូវបង្កកអាស៊ីតវាកាត់ដៃធ្វើអោយរបកស្បែក និងហើមផងដែរ។ ខ្ញុំធ្លាប់ប្រើ ស្រោមដៃពេទ្យនិងស្រោមដៃស៊ីម៉ង់ពាក់ការពារដែរ តែពិបាក បកជ័រពេក ថែមទាំងឃើតទៀតផង ដូចនេះ ខ្ញុំបកអត់ប្រើស្រោមដៃទៅ"

**សម្រង់សម្ដីពីសាច់រឿងទី ៥**




ឈ្មោះ

# សាច់រឿងទី ៥

## បងស្រី ឡឹក ពឿន ជាគណៈកម្មការនៅក្នុងសហគមន៍ផលិតកៅស៊ូជាលក្ខណៈគ្រួសារ

បងស្រី ឡិប ពឿន មានអាយុ៣៥ឆ្នាំ មកពីភូមិពពេល ឃុំពពេល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ បងស្រីមានគ្រួសារ និងបានរៀបការ មានកូនម្នាក់ អាយុ១៨ឆ្នាំ រាល់ថ្ងៃមានមុខរបរធ្វើស្រែចំការ និងដាំកៅស៊ូប្រហែល ជិត៣ហិចតា។ បងពឿន គ្រួសារគាត់មានសមាជិកប្រាំនាក់ តា យាយ កូន ប្ដី និងប្រពន្ធ ដែលស្ថិតនៅក្នុងស្ថានភាព ជីវភាពកំរិតមធ្យម។ ជាស្ត្រីមួយរូប បងស្រីត្រូវបំពេញតួនាទីជាស្ត្រីមេផ្ទះគ្រប់ពេលវេលា និងចូលរួមយ៉ាងសកម្មនៅក្នុងការជៀរជ័រកៅស៊ូ ប្រមូលជ័រកៅស៊ូ និងធ្វើស្រែចំការ។ ការងារផ្ទះសម្បែងទាំងនោះរួមមាន ការដាំបាយ ធ្វើម្ហូប មើលថែទាំសមាជិកគ្រួសារ និងការងារផ្ទះផ្សេងទៀត។ បងស្រីលើកឡើងថា *"ទោះបីអត់រដូវភ្ជុំបិណ្ឌក៏ដោយ ខ្ញុំត្រូវដាំបាយ ធ្វើម្ហូប តែខ្ញុំអត់ដាំពេលងងឹតពេកទេ ខ្ញុំដាំពេលភ្លឺម៉ោង៥អញ្ចឹង។ បើថ្ងៃសីលពុកម៉ែខ្ញុំទៅវត្តទៅ ចំណែកខ្ញុំ ជួនកាលព្រឹកឡើងទៅចំការជំរះស្មៅដំឡូង តែសព្វថ្ងៃជំរះស្មៅស្រូវ។ ប្ដីខ្ញុំក៏ទៅជាមួយខ្ញុំដែរ កូនទៅរៀន។ សម្រាកម៉ោង ១១ ឬ១២ អី ជួនកាលម៉ែធ្វើម្ហូបអោយទៅ ជួនកាលមកដល់ធ្វើទៀតទៅ បើពេលរសៀល វិញជួនរវល់ជួនទំនេរ ភាគច្រើនរសៀលទៅចំការ ឬទៅស្រែ។"*

គ្រួសាររបស់បងស្រីបានជ្រើសរើស និងចាប់ផ្ដើម ដាំកៅស៊ូជាង១០ឆ្នាំមកហើយ ឆ្នាំនេះជាឆ្នាំទី២ ដែលគ្រួសារគាត់បានប្រមូលផលជ័រកៅស៊ូ និងបានទិញបន្ថែមដីដែលមានដំណាំកៅស៊ូស្រាប់មួយកន្លែងទៀត។ ការទិញបន្ថែមគាត់ និងស្វាមីបានពិភាក្សាគ្នា និងសម្រេចចិត្តខ្ចីលុយធនាគារ ដើម្បីយកដីនោះ។ ដីចំការកៅស៊ូមានបីកន្លែងផ្សេងគ្នា បងស្រី និងប្ដីត្រូវធ្វើដំណើរទៅតំបន់ចំការទាំងបី ដើម្បីទៅជៀរជ័រ នៅម៉ោង១១យប់ ឬ១២អាធ្រាតអាស្រ័យលើភាពអំណោយផលនៃអាកាសធាតុមានភ្លៀង ឬអត់។ ជាធម្មតាការជៀរជ័រកៅស៊ូរបស់ពួកគាត់ តែងតែរួចរាល់នៅម៉ោង៤ព្រឹក។ មកដល់ផ្ទះសម្រាក ដាំបាយទឹក ហូបចុករួចរាល់ នៅម៉ោង៩ ឬ១០ព្រឹក រហូតដល់១២ ថ្ងៃត្រង់ ពួកគាត់ត្រូវទៅចំការទាំងបីកន្លែងដើម្បីធ្វើការបង្កកជ័រ។

បន្ទាប់ពីបង្កកជ័រ ហើយពួកគាត់ត្រូវទៅបកជ័រពីម៉ោង៣ព្រឹកដល់៧ ឬយូរបំផុតម៉ោង៨ព្រឹក ជាធម្មតាការជៀរជ័រ គឺត្រូវរំលង២ថ្ងៃទើបបានជៀរម្តងទៀត។ ទិន្នផលនៃការប្រមូលជ័រទាំងបីកន្លែងម្តង គឺបានប្រហែល ៩៥គីឡូសម្រាប់ឆ្នាំនេះ តែឆ្នាំទៅកៅស៊ូហក់ឡើងដល់១០០ទៅ១០៤គីឡូ ដោយសារបានបន្ថែមជីដល់ ឆ្នាំនេះជីវភាពខ្វះខាតទើបមិនបានដាក់ជីពេញលេញ។ បងស្រីបានលើកឡើងថា កៅស៊ូអាចលក់អោយឈ្មួញកណ្តាល ឬអាចលក់រួមជាមួយសហគមន៍។ បងស្រីបានលើកបទពិសោធន៍ការសម្រេចចិត្តលក់ទៅអោយឈ្មួញកណ្តាល និងការលក់រួមជាមួយសហគមន៍ ដោយគាត់បានលើកឡើងថា "*ខ្ញុំអត់ចូលលក់ក្រុមទេ ខ្ញុំចូលលក់ ក្រៅៗហ្នឹង ចាំលក់រួមគ្នា វាបានថ្លៃមែន តែខ្ញុំពិបាកដឹកមកផ្ទះ ហើយបានសហគមន៍មកប្រមូលហើយវាអាចស្រកគីឡូ។ បើកាលខ្ញុំសួរគេ កាលហ្នឹងគេទិញនៅនោះគេអោយ២០ទៅនៅ នេះគេអោយ ២១ចឹងទៅ បើគិតៗទៅខុសគ្នាតែ១០០ហ្នឹង សុខចិត្តខាតដោយសារទុកយូរវាស្រកគីឡូដែរហ្នឹង។ តែខ្ញុំគិតថា បើលក់នៅនេះ (លក់ខ្លួនឯង)បានថ្លៃជាង ព្រោះថាលក់នោះនៅចាំយូរហើយខាតពេលវេលាធ្វើការទៀត នៅចាំសហគម៍គាត់ប្រមូលពីភូមិនេះភូមិនោះបានមកយកយើង។*"

សព្វថ្ងៃនេះមានឈ្មួញកណ្តាលជាច្រើនដើរទិញដល់ចំការផ្ទាល់ ឈ្មួញកណ្តាលទាំងអស់ហ្នឹង ទិញជ័រ យកទៅលក់អោយថៅកែភូមិ ហើយថៅកែលក់បន្តអោយក្រុម នេះបើតាមការរៀបរាប់ របស់បងស្រីពី ការទិញលក់កៅស៊ូ។ បងស្រីមានការថ្នាញថ្នែរចំពោះឈ្មួញកណ្តាលដោយគាត់លើកថា "*ឈ្មួញឥឡូវចូលរម៉ក់ទៅដល់ចំការទៀត តែដូចខ្ញុំនិយាយចឹងខ្ញុំអត់លក់ ព្រោះឈ្មួញខ្លះវាលេងជញ្ជីង បើឈ្មួញខ្ញុំលក់ខ្លួនឯងហ្នឹងថ្លឹងគីឡូខ្ញុំអត់សួរអីទេ*"។ បងស្រីបន្តមុនលក់គាត់ក៏បានស្វែងរកព័ត៌មានតម្លៃ កៅស៊ូពីមិត្តភក្តិ សាច់ញាតិនៅភូមិផ្សេងទៀត ដើម្បីកុំអោយឈ្មួញកូរតម្លៃ ឬបន្លោកតម្លៃ។ បងស្រីមើលឃើញថា ការលក់អោយឈ្មួញ ដែលគេទិញលក់តៗគ្នាហ្នឹង គឺបានចំណេញ ជាពិសេស អាចលក់អោយក្រុមហ៊ុនផ្ទាល់ គាត់ថា បើសហគមន៍អាចមកផ្ទាល់ដល់ក្រុមជ័រកៅ ស៊ូរិតតែ បានថ្លៃខ្ពស់ តែគ្រាន់ថា គាត់សាញក្នុងការរង់ចាំលក់ជុំគ្នា ហើយការទិញសហគមន៍ហ្នឹង គឺតម្រូវអោយជៀរពីរពន្លៀក តែគ្រួសារគាត់ជៀរតែមួយពន្លៀកតែប៉ុណ្ណោះ។

ក្រៅពីនេះបងស្រីចាប់ផ្តើមធ្វើការកត់សម្គាល់ និងបារម្ភអំពីសុខភាពដែរ ដោយសារការប្រើជីគីមី ទឹកអាស៊ីតបង្កក និងប៉ះទឹកអាស៊ីតផ្ទាល់ពេលបកជ័រ។ បងស្រីបានលើកឡើងថា "*ឆ្នាំនេះម្រាមដៃខ្ញុំ ចាប់ផ្តើមរបក ដោយសារជ័រត្រូវបង្កកអាស៊ីតវាកាត់ដៃធ្វើអោយរបកស្បែកនិងហើមផងដែរ។ ខ្ញុំធ្លាប់ប្រើ ស្រោមដៃពេទ្យនិងស្រោមដៃស៊ីម៉ង់ពាក់ការពារដែរ តែពិបាកបកជ័រពេក ថែមទាំងយឺតទៀតផង ដូចនេះ ខ្ញុំបកអត់ប្រើស្រោមដៃទៅ*"។

កន្លងមកមានខាងមន្ទីរកសិកម្ម ក្រុមហ៊ុនជី និងអាជ្ញាធរបានចុះមកផ្សព្វផ្សាយពីបច្ចេកទេសកៅស៊ូ ការផលិតកៅស៊ូអោយត្រូវតាមស្តង់ដារ និងការប្រើប្រាស់ជីដែរ។ ការប្រជុំនោះបងស្រីបានលើកឡើងថា គាត់មិនបានចូលរួមគ្រប់ប្រជុំទេ ពេលខ្លះម្តាយគាត់ និងពេលខ្លះប្តីរបស់គាត់។ គាត់ថា ដូចថ្មីៗនេះប្តីគាត់ ទៅប្រជុំនៅសហគមន៍ គាត់បានសម្រេចចិត្តមិនចូលរួមលក់ជាមួយសហគមន៍ទេ ដោយសារគាត់មានការ លំបាករឿងដឹកជញ្ជូន និងតម្លៃអាចលើសគ្នាតិចតួច ហើយអាចចំណេញពេលសម្រាប់គាត់។ គាត់បានបន្តថា ប្តីរបស់គាត់បានជជែកជាមួយគ្នាអំពីការសម្រេចចិត្តនេះដែរ ហើយពេលខ្លះគាត់ទៅ ប្រជុំហ្នឹងអាចអត់បានព័ត៌មានអីទេជាពិសេសពេលម្តាយរបស់គាត់ទៅប្រជុំជំនួស។ នៅតាមប្រជុំក្នុង សហគមន៍ គាត់សង្កេតឃើញមានស្ត្រីចូលរួមច្រើនដែរ តែភាគច្រើនស្ងាត់ តែទាក់ទងរឿងទិញលក់ជាមួយ ឈ្មួញ គឺស្ត្រីភាគច្រើនជាអ្នកតថ្លៃជាមួយឈ្មួញ។



ទឹកក្អែកពណ៌ស









"ពីដំបូងឡើយការដាំកៅស៊ូដោយអត់សូវមានបច្ចេកទេស វាមិនមែនជារឿងងាយស្រួល
នោះទេ ពេលខ្លះអាចជ្រើសរើសពូជដាំខុស ពេលខ្លះជៀរទៅមុខធំធ្វើអោយដើមឆាប់ខូច
ពេលខ្លះជៀរទៅជ្រៅពេកអាចធ្វើអោយដើមដំបៅ និងពេលខ្លះឆាប់ជៀរយកជ័រទាំងដែរ
កៅស៊ូនៅអាយុកាលខ្ចីពេក ក៏ធ្វើអោយដើមឆាប់ខូចផងដែរ"

**សម្រង់សម្តីពីសាច់រឿងទី ៦**





# សាច់រឿងទី៦

## បងស្រី ឡូយ ធារី ជាគណៈគណៈកម្មការនៅក្នុង សហគមន៍ផលិតកៅស៊ូ ជាលក្ខណៈគ្រួសារ

លោកស្រី ឡូយ ធារី មកពីភូមិជ្រៃភ្លក់ ឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។ លោកស្រីមានតួនាទីជា មេភូមិ ហើយក៏ជា គណៈកម្មការម្នាក់ដែលមានតួនាទីជា ហិរញ្ញឹក នៅក្នុងក្រុមផលិតកៅស៊ូនៅក្នុងសហគមន៍ ដែលមានឈ្មោះថា "*សហគមន៍កសិកម្មតំបែររុងរឿង*" ផងដែរ។ ជាស្ត្រីដែលមានតួនាទីច្រើន ក៏ដោយក៏លោកស្រីនៅតែអាចឆ្លៀតពេលដើម្បីជួយធ្វើការនៅចំការកៅស៊ូជាមួយគ្រួសារបានផងដែរ។ គ្រួសាររបស់លោកស្រីបានដាំដំណាំកៅស៊ូនេះ តាំងពីមុនពេលលោកស្រីរៀបការមកម៉្លេះ បើគិតទៅកៅស៊ូដែលគាត់ ប្រមូលផលនេះបានជាង១០ឆ្នាំមកហើយលើផ្ទៃដី ប្រមាណ៣ហិចតា។ សព្វថ្ងៃលោកស្រី និងប្តី ក៏កំពុងតែពង្រីកផ្ទៃដីដាំដុះបន្ថែម ២ហិចតាកន្លះទៀត ហើយសម្រាប់ដើមកៅស៊ូចាស់ៗ លោកស្រីក៏មានផែនការកាប់ដើម្បី ដាំកូនកៅស៊ូថ្មីហើយជ្រើសប្រភេទពូជណាដែលល្អជាងមុន។ ចំពោះការងារធ្វើកៅស៊ូ លោកស្រីបានយល់ដឹងទៅលើបច្ចេកទេសបានច្រើន ដោយសារលោកស្រីមាន ឱកាស បានចូលរួមជាមួយសហគមន៍ និងស្ថាប័នផ្សេងៗដែលជួយបង្ហាត់បង្ហាញពី បច្ចេកទេសដាំកៅស៊ូដើម្បី យកមកអនុវត្តន៍ផ្ទាល់ជាមួយការងារប្រចាំថ្ងៃ។ លោកស្រីបានលើកឡើងថា "*ពីដំបូងឡើយការដាំកៅស៊ូដោយអត់សូវមានបច្ចេកទេស វាមិនមែនជារឿងងាយស្រួលនោះទេ ពេលខ្លះអាចជ្រើសរើសពូជដាំខុស ពេលខ្លះជៀរទៅមុខធំធ្វើអោយដើមឆាប់ខូច ពេលខ្លះជៀរទៅជ្រៅពេកអាចធ្វើអោយដើមដំបៅ និងពេលខ្លះឆាប់ជៀរយកជ័រទាំងដែរកៅស៊ូនៅអាយុកាលខ្ចីពេកក៏ធ្វើអោយដើមឆាប់ខូចផងដែរ*"។ បទពិសោធន៍ម៉េចក៏មានដែរសម្រាប់គ្រួសាររបស់លោកស្រី។

រាល់ថ្ងៃនេះ គ្រួសាររបស់លោកស្រី បានទទួលប្រាក់ចំណូលច្រើនគួរសមពីដំណាំកៅស៊ូ សម្រាប់ផ្គត់ផ្គង់ ទៅលើការចំណាយផ្សេងៗ ជាពិសេសសង់បំណុលដែរលោកស្រី និងប្តីបានខ្ចី ដើម្បីពង្រីកផ្ទៃដីដាំកៅស៊ូថ្មីបន្ថែម។ ទោះបីជាការងារធ្វើកៅស៊ូអាចជួយអោយ គ្រួសារបានល្អប្រសើរពិតមែន តែក៏វាមិនស្រួលនោះទេសម្រាប់លោកស្រីជាស្ត្រី ដែលត្រូវងើបពីយប់អាធ្រាតដើម្បីទៅជៀរជ័រ ហើយពេលខ្លះអាចជួបហ្នឹងសត្វពស់ ឬសត្វមានពិសផ្សេងៗទៀតដែរ

នោះ។ គ្រប់ពេលលោកស្រីត្រូវពាក់ស្បែកជើងករវែង ខោជើងវែងក្រាស់ៗដើម្បីការពាររាជានិច្ច។ មូលហេតុដែលលោកស្រីត្រូវងើបទៅដៀរជ័រពេលយប់ដោយសារកៅស៊ូចេញជ័រខ្លាំងតែពេល ត្រជាក់ ជាក់ស្តែកទៅចាប់ពីម៉ោង ១០យប់ដល់ម៉ោង០៥ព្រឹក ជាពេលដែលត្រជាក់។ សម្រាប់ រដូវដែលជ័រចេញបានច្រើន គឺនៅរដូវវស្សា ហើយបើខែក្តៅវិញជាពិសេសខែកុម្ភៈ ទៅដល់ ពាក់កណ្តាលខែមិនា កៅស៊ូអត់ចេញជ័រទេ។

បន្ថែមពីការងារដាំកៅស៊ូជាលក្ខណៈគ្រួសារ លោកស្រី ឡូយ ធារី ជាគណកម្មការ ម្នាក់ក្នុងចំណោមគណៈកម្មការ៧នាក់ផ្សេងទៀតក្នុងក្រុមផលិតកៅស៊ូ ក្នុងនោះលោកស្រីក៏បាន ខិតខំស្វែងរកទីផ្សារជ័រកៅស៊ូជូនទៅដល់សមាជិក ផងដែរ ។ ពីដើមឡើយក្រុមសហគមន៍របស់ លោកស្រី លក់ត្រឹមជ័រដែលបានបង្កករួចតែប៉ុណ្ណោះ បន្ទាប់លោកស្រីបានទាក់ទងទៅក្រុមហ៊ុន បារាំងមួយដែលគេព្រមទទួលទិញ ជ័រទឹកតែម្តង។ នៅក្នុងដំណើរការនេះលោកស្រីបានដឹកនាំ សមាជិកដើម្បីលក់ទឹកជ័របាន ចំនួនពីរដងមកហើយ លើកទី១ មានសមាជិកចូលរួម៦គ្រួសារ បានជ័រសរុបប្រមាណ ៣០០គីឡូក្រាមជាង និងលើកទី២ មានសមាជិកជាង១០គ្រួសារបានជ័រ សរុប១៥០០គីឡូក្រាមជាង។ ដោយការប្រមូលទិញនោះ លោកស្រីបានពន្យល់អោយដឹងថា "*ខាងក្រុមហ៊ុនគិតជាគីឡូ ដេសេ មានន័យថា បើទឹកជ័រយើង ១០០គីឡូក្រាម ពេលគេយក ទៅដុតចេញជា ដេសេ បាន ៥០ ដេសេ នោះមានន័យថាគេយកចំនួន៥០ គុណជាមួយតម្លៃ ជាក់ស្តែង ដូចជាក់ស្តែងពេលនោះ ក្រុមរបស់លោកស្រីលក់ក្នុងតម្លៃ៥០០០៛ ក្នុងមួយគីឡូ* "។ ចំពោះលោកស្រី ឡូយ ធារី ផ្ទាល់ មានអារម្មណ៍ថា "*សប្បាយចិត្តដែរបានលក់ទឹកជ័រតែម្តង ដោយមិនចាំបាច់ត្រូវការបង្កកវាអោយ រឹង ព្រោះខ្ញុំគិតថា ពេលបង្កកជ័រអោយរឹង នោះយើង ត្រូវប្រើប្រាស់ អាស៊ីត ហើយអាស៊ីតនោះហើយដែរអាចហ្នឹង ធ្វើអោយប៉ះពាល់ដល់សុខភាព ខ្ញុំនិងគ្រួសារ ហើយខ្ញុំមិនចាំបាច់បង្កកយូរ គ្រាន់តែដៀរបានចន្លោះពី៤ទៅ៦ម៉ោងអាចប្រមូល ទឹកជ័របាន ហើយលក់តែម្តង ហើយមិនចាំបាច់ចំណាយទៅលើការទិញអាស៊ីតមកបង្កកទៀត*"។

ទោះបីជាមើលឃើញពីចំណុចល្អច្រើនយ៉ាងណាក្តីតែលោកស្រីនៅតែ មានការលំបាក ក្នុងការទៅពន្យល់សមាជិកផ្សេងទៀតអោយចូលរួមលក់បានជុំគ្នាដដែលដោយសមាជិកខ្លះ យល់ឃើញថាលក់បានតម្លៃតិចជាងជ័របង្កករួចខ្លះទៀតមិនទាន់ យល់ដឹង ពីដំណើរការទិញ លក់ច្បាស់ ខ្លះទៀតក៏មិនចង់ដឹកទៅឆ្ងាយ។ ហើយសម្រាប់ក្រុមហ៊ុនប្រមូលទិញវិញ គេអាច ចុះមកយកលុះត្រាតែសហគមន៍ អាចប្រមូលជ័រ បានចាប់ពី ៥០០គីឡូក្រាមឡើងទៅ ដូចនេះ ក្នុងនាមគាត់ជា គណៈកម្មការគាត់ត្រូវដើរ ពន្យល់សមាជិកមួយៗអោយយល់ និងត្រូវខល បញ្ជាក់ពីពេលវេលាប្រមូលអោយត្រូវគ្នាផងដែរ។សម្រាប់បញ្ហាដែលមានអ្នកខ្លះគិតថាលក់ជ័រ

កកបានថ្លៃជាងនោះ លោកស្រីក៏បានចូលរួមពិសោធន៍ផងដែរ នៅពេលដែលពិសោធន៍រួចហើយ ទើបដឹងថាជ័រកកពិតជាលក់បានថ្លៃជាងមែន។លោកស្រីបានប្រាប់ថា "*តម្លៃជ័រកក២៣០០រៀល ក្នុងមួយគីឡូ ជ័រទឹក ៥០០០រៀលក្នុងមួយដេសេជ័រទឹក តម្លៃនេះបើមើលទៅឃើញថាជ័រទឹកបានថ្លៃជាង តែអត់ទេព្រោះតម្លៃនេះវាស្មើតែ២ដងនៃតម្លៃជ័រកកប៉ុណ្ណោះ តែជាក់ស្តែងទាល់តែស្មើហ្នឹង២ដងកន្លះទៅ៣ដងនៃតម្លៃជ័រកកទើបអាចថាបានស្មើគ្នាឬថ្លៃជាង*"។ បន្ទាប់មកលោកស្រីក៏សម្រេចចិត្តឈប់លក់ជ័រទឹកសិនទៅ។

ទោះបីជាហត់ច្រើននិងលទ្ធផលមិនបានដូចការគិតពិតមែនតែលោកស្រីបានគិតថាបោះបង់ឡើយ ហើយហ្នឹងមានគោលដៅចង់លក់ជ័រទឹកដដែល តែសូមអោយនាយកដ្ឋានដំណាំកៅស៊ូ ជួយតំឡើងថ្លៃជ័រទឹកអោយថ្លៃជាងនេះបន្តិតទៀតមក អាចគុណាហ្នឹង៣ដងនៃតម្លៃជ័រកក ព្រោះលោកស្រីនៅតែគិតថាការលក់ជ័រកក វាប៉ះពាល់សុខភាពរបស់ប្រជាពលរដ្ឋ ព្រោះត្រូវប៉ះពាល់ផ្ទាល់ជាមួយហ្នឹងអាស៊ីត និងត្រូវចំណាយលុយទិញអាស៊ីតមកបង្កកទៀតផង។ ជាចុងក្រោយលោកស្រីមានសំណូមពរ ចង់ឲ្យមានការចូលរួមពីនាយកដ្ឋានដែលពាក់ព័ន្ធ ជាមួយដំណាំកៅស៊ូ ជួយចុះពន្យល់ទៅប្រជាជនអោយយល់ដឹងកាន់តែច្បាស់ពី ជ័រកក និងជ័រទឹក ដើម្បីលក់បានតម្លៃខ្ពស់លើទីផ្សារ។



ទឹកភ្នែកពណ៌ស







"ពេលរកឈ្មួញទិញកៅស៊ូបាន ហើយ គាត់ត្រូវខលប្រាប់សមាជិក ពេលខ្លះដើរប្រាប់ បន្ថែមដើម្បីអោយការប្រមូលផលជ័របានជុំគ្នា តែពេលខ្លះមានភ្លៀងអត់បានប្រមូល ខ្លះទៀតគេ មិនចង់ចាំឡានមកយកពេលយប់ជ្រៅ គេលក់អោយ ឈ្មួញផ្សេងតម្លៃខុសគ្នាបន្តិចបន្តួច។ ពេលខ្លះ សមាជិកចង់អោយ ប្រធានសហគមន៍ប្រមូលទិញដោយខ្លួនឯង"

**សម្រង់សម្តីពីសាច់រឿងទី ៧**



# សាច់រឿងទី ៧

## បងស្រី អ៊ុក វណ្ណី ជាគណៈកម្មការនៅក្នុងសហគមន៍ផលិតកៅស៊ូជាលក្ខណៈគ្រួសារ

លោកស្រី អ៊ុក វណ្ណី អាយុ៤៣ឆ្នាំ ជាពលរដ្ឋរស់នៅក្នុងភូមិទូលចាន់ ឃុំ ពពេល ស្រុកពញាក្រែក ខេត្ត ត្បូងឃ្មុំ។ ក្នុងគ្រួសាររបស់លោកស្រីមានសមាជិក ៤នាក់រួមមានប្តី កូនប្រុសច្បងអាយុ ១០ឆ្នាំ និងស្រីពៅអាយុ ៧ឆ្នាំ។ ដែលមានតួនាទីជាប្រធានក្រុមផលិតកៅស៊ូនៅក្នុងសហគមន៍ ដែលមានឈ្មោះ ថា *"ក្រុមផលិតកៅស៊ូទូលចាន់ជោគជ័យ"*។ ដំណើរការចង់ក្រងក្រុម ផលិតកៅស៊ូនេះត្រូវបានបង្កើត ឡើងមួយឆ្នាំមកហើយ ក្នុងនោះ មានសមាជិក២៦នាក់ ស្មើហ្នឹង២៦គ្រួសារ ដែរមានរចនាសម្ព័ន្ធភាគ ច្រើនជាស្ត្រីជាអ្នកដឹកនាំ។ លោកស្រីបានប្រាប់ថា *"តួនាទីជាប្រធានក្រុមនេះ មិនមានការបោះឆ្នោតអ្វី នោះទេ គ្រាន់តែដំបូងឡើយ ពួកគាត់មានការប្រជុំគ្នា ហើយអ្នកចូលរួមបាននាំគ្នាលើកគាត់អោយធ្វើជា ប្រធានក្រុម តាំងពីពេលនោះមកដល់ឥឡូវ"*។ ក្រៅពីតួនាទីជាប្រធានក្រុម គ្រួសាររបស់លោកស្រីក៏ជាអ្នកដាំកៅស៊ូជាលក្ខណៈគ្រួសារផងដែរ បន្ថែមពីនោះទៀតក៏មាន ដាំដំឡូង និងធ្វើស្រែផងដែរ។ ដោយសារចំការកៅស៊ូនៅឆ្ងាយពីផ្ទះ ហើយការ ជៀរជ័រត្រូវធ្វើពេលយប់ផងដែរនោះ លោកស្រីមិនបាន ជួយលើការជៀរជ័រកៅស៊ូនោះទេ ភាគច្រើនគឺប្តីរបស់គាត់ តែលោកស្រីបានធ្វើការងារនៅក្នុងផ្ទះជាច្រើន ដូចជា ធ្វើបាយធ្វើម្ហូប មើលថែកូនៗ បោសជូតផ្ទះ និងការងារផ្សេងៗទៀតជាច្រើន តែសម្រាប់ការងារ ដាំដំឡូង និងស្រែចំការ គឺលោកស្រី និងប្តីធ្វើទាំងអស់គ្នា។

ចំពោះបទពិសោធន៍ លើការដាំកៅស៊ូជាលក្ខណៈគ្រួសារ លោកស្រីជួបប្រទះការលំបាកខ្លាំង ដោយត្រូវមានការយកចិត្តទុកដាក់ថែទាំនៅពេលចាប់ផ្តើមដំបូង រហូតដល់កៅស៊ូបានអាយុ៣ឆ្នាំ ក្នុងការ ដាក់ជី បាញ់ថ្នាំស្មៅ ជាពិសេសត្រូវការទឹកគ្រប់គ្រាន់ បើមិនដូច្នេះទេកៅស៊ូហ្នឹងនិងងាប់ ហើយគាត់ហ្នឹងត្រូវជួសថែទាំម្តងទៀត។ សម្រាប់តម្លៃជ័រកៅស៊ូវិញរាល់ថ្ងៃនេះមិនមានការកំណត់តម្លៃជាក់លាក់ឡើយវាឡើងចុះទៅតាមតែអ្វីដែលឈ្មួញបានកំណត់

ពេលខ្លះលក់បានតម្លៃ ២០០០រៀល ឬ ២០៥០រៀល ឬ ២១០០រៀល។ ឈ្មួញខ្លះទៀតកំណត់តម្លៃទៅតាមប្រភេទជ័រអាយុកាលរបស់ដើម និងបច្ចេកទេសនៃការបង្កក ពេលខ្លះពួកគាត់បង្កកដោយប្រើ អំបិល ឬ ម្សៅ ឬ អាស៊ីតជូ។ ត្រង់បច្ចេកទេសនេះលោកស្រីបានបញ្ជាក់ថា "*ការបង្កកដោយប្រើអាស៊ីតជូ ល្អ វាអាចធ្វើអោយជ័រ រឹងល្អ មិនជ្រាយ ដូចនេះពេលយើងលក់ទៅអោយឈ្មួញបានតម្លៃល្អតាមហ្នឹងដែរ*"។ លោកស្រី អ៊ុក វណ្ណី និងគ្រួសារចាប់ផ្តើមប្រកបការងារជាអ្នកដាំកៅស៊ូនេះប្រមាណជា ១០ឆ្នាំមកហើយ ដំបូងឡើយគាត់បានធ្វើវាបន្តពីគ្រួសារខាងប្តីរបស់គាត់ ដោយពេលនោះកៅស៊ូចាប់ផ្តើមទទួលបានផលហើយដែរ ។

ទោះបីជាការធ្វើកៅស៊ូមានការលំបាកខ្លាំង តែបើចំពោះលោកស្រី នៅតែយល់ថា "*វាល្អបើធៀបជាមួយ ដំណាំផ្សេងទៀតដូចជា ស្វាយចន្ទី ឬ ដំឡូងដែលប្រមូលផលបានតែពេលវេលាមួយ តែដំណាំកៅស៊ូ វាមានអាយុកាលប្រមូល ផលទៅដល់ ៤០ឆ្នាំ*"។ ក្រៅពីការងារនៅក្នុងគ្រួសារ លោកស្រី អ៊ុក វណ្ណី ក៏បានចំណាយពេលដើម្បីចូលរួមជាមួយ សហគមន៍ ក្នុងគោលបំណងចង់អោយក្រុមផលិតកៅស៊ូមាន ដំណើរការល្អ ក្នុងនោះលោកស្រីត្រូវ ស្វែងរកទីផ្សារ (ឈ្មួញ) អោយសមាជិកខ្លួន ធ្វើយ៉ាងណាអោយ តម្លៃជ័រកៅស៊ូរបស់ពួកគេទទួលបានតម្លៃមួយសមរម្យអាចទទួលយកបាន។ លោកស្រីបានបង្ហាញពី ការលំបាករបស់ខ្លួនថា "*នៅក្នុងសហគមន៍របស់គាត់សមាជិកដាំកៅស៊ូម្នាក់ៗមានផ្ទៃដីតិច អ្នកខ្លះ កន្លះហិចតា ទៅ១ហិចតា អ្នកខ្លះ២ហិត ទៅ៣ហិចតាចឹងទៅ ដូចនេះធ្វើអោយការប្រមូលជ័របានតិច ហើយពេលខ្លះការប្រមូលជ័រអត់បានជុំគ្នាទៀត*"។ លោកស្រីបន្ថែមថា "*ពេលរកឈ្មួញទិញកៅស៊ូបាន ហើយ គាត់ត្រូវខលប្រាប់សមាជិក ពេលខ្លះដើរ ប្រាប់បន្ថែមដើម្បីអោយការប្រមូលផលជ័របានជុំគ្នា តែពេលខ្លះមានភ្លៀងអត់បានប្រមូល ខ្លះទៀតគេ មិនចង់ចាំឡានមកយកពេលយប់ជ្រៅ គេលក់អោយឈ្មួញផ្សេងតម្លៃខុសគ្នាបន្តិចបន្តួច។ ពេលខ្លះ សមាជិកតចង់អោយប្រធានសហគមន៍ប្រមូលទិញដោយខ្លួនឯង*"។ ក្នុងចំនុចនេះលោកស្រី អ៊ុក វណ្ណី មានគំនិតក្នុងការប្រមូលទិញជ័រពីសមាជិកខ្លួនដែរ តែបច្ចុប្បន្ននេះក្រុមសហគមន៍របស់លោកស្រី មិនទាន់មាន ធនធាន និងមធ្យោបាយដឹកជញ្ជូន ជាពិសេសមិនទាន់បានទាក់ទងក្រុមហ៊ុនណាមួយជាក់លាក់ ដើម្បីទិញ និងកំណត់តម្លៃ ជ័រកៅស៊ូពីពួកគាត់នៅឡើយទេ។ លើសពីការងាររកទីផ្សារជួយសហគមន៍ លោកស្រី អ៊ុក វណ្ណី និងសមាជិកបានចូលរួមរៀនសូត្រ និងចែករំលែក ចំណេះដឹងជាមួយសហគមន៍ផ្សេងៗ ដែលមានបទពិសោធន៍ ដើម្បីយកមកបន្តអនុវត្តន៍ធ្វើអោយសហគមន៍របស់លោកស្រីទទួលបានដំណើរការល្អពីការចង់ក្រុង។ ក្នុងនាមជាស្ត្រី មានភាពមមាញឹកទាំងការងារផ្ទះ ស្រែចំការ និងការងារជាប្រធានក្រុមផងនោះ លោកស្រីនៅតែសប្បាយរីករាយបន្ត

ការងារជាមួយសហគមន៍ ដោយទាំងអស់នោះក៏មានការជួយគាំទ្រពីគ្រួសារ និងសមាជិករបស់ខ្លួន ផងដែរ។

ជាសំណូមពររបស់លោកស្រី និងសមាជិកផ្សេងទៀត ដើម្បីជួយអោយក្រុមចងក្រងមានដំណើរការល្អ និងរឹងមាំ លោកស្រីសង្ឃឹមថាហ្នឹងទទួលបាននូវបទពិសោធន៍ទៅលើបច្ចេកទេសដាំដំណាំកៅស៊ូបន្ថែមនិងបានយល់ដឹង ពីជំនាញទំនាក់ទំនងដើម្បីងាយ ស្រួលក្នុង ការជជែករកទីផ្សារ ជួយដល់សហគមន៍ លោកស្រីផងដែរ។











"ខ្ញុំគិតថាការងារទាំងអស់ក្នុងផ្ទះជាការងាររបស់មនុស្សស្រីជាអ្នកធ្វើ ហើយត្រូវតែអោយធ្វើ ព្រោះតាំងពីតូចមកគ្រប់គ្រួសារតែងតែបង្រៀនកូនស្រីអោយចេះធ្វើ មិនដែលបង្រៀនកូនប្រុសទេ ហើយគ្រប់ៗគ្រួសារមានតែស្ត្រីប៉ុណ្ណោះដែលធ្វើរឿងនេះស្ទើរតែមួយជីវិតរបស់ពួកគាត់ទៅហើយ"

**សម្រង់សម្ដីពីសាច់រឿងទី ៨**




SMILE
FALL IN LOVE

# សាច់រឿងទី៨

## ប្អូនស្រី ហ៊ូ ចន្ទី ជាគណៈកម្មការនៅក្នុងសហគមន៍ផលិតកៅស៊ូជាលក្ខណៈគ្រួសារ

យុវនារី ហ៊ូ ចន្ទី មានអាយុ ២៨ឆ្នាំ រស់នៅភូមិក្រសោមសត្វ ឃុំកក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ហើយសព្វថ្ងៃជាគ្រូបង្រៀននៅមត្តេយ្យសហគមន៍។ ចន្ទីរស់នៅជាមួយឪពុកម្តាយ និងមានដីដែលមានដើមកៅស៊ូ កន្លះហិចតា ដែលកំពុងប្រមូលផល ចន្ទីបានលើកឡើងថា "*ពុកម៉ែអាយុច្រើន ការប្រមូលផល កៅស៊ូកន្លះហិចតាហ្នឹងខ្ញុំជៀរម្នាក់ឯង តែកាលដាំពុកម៉ែជាអ្នកដាំ។ ក្រៅពីជៀរកៅស៊ូ ខ្ញុំក៏ធ្វើស្រែដែរ*"។ សម្រាប់ការងារផ្ទះ ដូចជាដាំបាយស្លរ បោកខោអាវ និងការងារផ្សេងទៀតនៅក្នុងផ្ទះ ភាគច្រើនចន្ទី និងម្តាយជាអ្នកទទួលបន្ទុក។ មិនត្រឹមតែគ្រួសារចន្ទីទេ ដែលគិតថាកាងារផ្ទះ ជាការងាររបស់ស្ត្រី ក៏នៅមានគ្រួសារជាច្រើនទៀតនៅក្នុងសហគមន៍ផងដែរ ក៏គិតបែបនេះ ចន្ទីបានលើកឡើងថា "***ខ្ញុំគិតថាការងារទាំងអស់ក្នុងផ្ទះជាការងាររបស់មនុស្សស្រីជាអ្នកធ្វើ ហើយត្រូវតែអោយធ្វើ ព្រោះតាំងពីតូចមកគ្រប់គ្រួសារតែងតែបង្រៀនកូនស្រីអោយចេះធ្វើ មិនដែលបង្រៀនកូនប្រុសទេ ហើយគ្រប់ៗគ្រួសារមានតែស្ត្រីប៉ុណ្ណោះដែលធ្វើរឿងនេះស្ទើរតែមួយជីវិតរបស់ពួកគាត់ទៅហើយ***"។

ដោយសារៈស្រលាញ់ការងារស្ម័គ្រចិត្តនៅក្នុងសហគមន៍ចន្ទីបានចូលរួមជាអ្នកស្ម័គ្រចិត្ត នៅក្នុងគណៈកម្មការនៃក្រុមផលិតកៅកៅស៊ូ ដែលមានឈ្មោះថា "*ក្រុមផលិតកៅស៊ូគ្រួសារសាមគ្គីកី*" ចន្ទីមានតួនាទីជាលេខា នៃក្រុមមួយនេះផងដែរ។ ចន្ទីជាក្មេងស្រីម្នាក់ដែលត្រូវ សហគមន៍ទុកចិត្តអោយកាន់តួនាទី ជាលេខាក្រុមផលិតកៅស៊ូនេះ ជាមួយហ្នឹងមនុស្ស០២នាក់ទៀត ដែលកាន់តួនាទីជាប្រធាន និងអនុប្រធាន ក្នុងនោះមានមនុស្សប្រុសកាន់តួនាទីជាប្រធានក្រុម។ ក្នុងរយៈពេលមួយឆ្នាំដែលចន្ទីបានស្ថិតនៅក្នុង គណៈកម្មការមួយនេះ ចន្ទីបានចូលរួមក្នុងការចងក្រងក្រុម ដើម្បីលក់ជ័រកៅស៊ូកករួមគ្នា តែក្រុមយើងបានលក់រួមគ្នាបានតែម្តងគត់ ដោយសារតែមានការលំបាកច្រើន ចន្ទីបានលើកឡើងថា "*ខ្ញុំពិបាក ក្នុងការពន្យល់ទៅកាន់ពួកគាត់ថា ការលក់រួមហ្នឹងវាបានផលអ្វីខ្លះ និយាយទៅគាត់មិនសូវចង់ស្តាប់ខ្ញុំទេ ព្រោះបទពិសោធន៍នៃការលក់បានម្តង បានធ្វើអោយគាត់គិតថាការលក់រួមគ្នាហ្នឹងត្រូវ*

*ចាំគ្នាយូរ គាត់ខ្លាចទុកយូរទៅជ័រស្រកគីឡូ អ្នកខ្លះត្រូវដឹកងមកឆ្ងាយ គ្មានមធ្យោបាយក្នុងការដឹកជញ្ជូន។ ណាមួយការលក់រួមគ្នា បានថ្លៃជាងតែ២០០រៀលទេ ចឹងហើយល្មមៗគេលក់ផ្សេងៗគ្នាហើយ*"។ ទោះជាមានការលំបាកច្រើន ក៏ចន្ទីមិនដែលរាយថយក្នុងការធ្វើជាគណៈកម្មការក្រុមផលិតជ័រកៅស៊ូដែរ ចន្ទីបានបង្ហាញការតាំងចិត្តថា "*ពេលនេះខ្ញុំ និងក្រុមកំពុងមានផែនការក្នុងការចង់ក្រងក្រុមថ្មី ហើយក៏ចង់បន្តជាមួយក្រុមចាស់ដែរ*"។ ក្រៅពីការងារចងក្រង ចន្ទីក៏បានចូលរួមប្រជុំប្រចាំខែជាមួយម៉ែៗ ដែលជាសមាជិកនៃក្រុមលផលិតជ័រកៅស៊ូគ្រួសារផងដែរ។ ចន្ទីតែងសង្កេតឃើញ នៅក្នុងក្រុមមានសមាភាពជាស្ត្រីច្រើនជាងបុរស ទើបចន្ទីតែងហៅអ្នកចូលរួមក្រុមថា ក្រុមម៉ែៗ ជាទូទៅក្រុមម៉ែៗមានការចូលរួមជជែក និងចែករំលែកបទពិសោធន៍បានច្រើន ហើយការសម្រេចចិត្ត បើត្រូវសម្រេចចិត្តភ្លាមៗ គឺគ្មានត្រូវចាំសួរនាំប្តី ឬអ្នកនៅក្នុងគ្រួសារសិនទេ។ សម្រាប់ព័ត៌មានដែលក្រុមតែងលើកមកជជែកគ្នា ចន្ទីមានដូចជា "*បញ្ហាជ័រកៅស៊ូចុះថោក អ្នកខ្លះទៅបញ្ហាជ័រគាត់អត់រឹង ពេលខ្លះគាត់បារម្ភពីសុវត្ថិភាពដែរ ព្រោះដៃគាត់ត្រូវទឹកអាស៊ីតវាស៊ី ឡើងរមាស់ និងហើម តាមទំលាប់យើងមិនដែរពាក់ស្រោមដៃទេ គាត់បារម្ភ បារម្ភហើយ តែគាត់នៅតែមិនដែលពាក់ ព្រោះពេលពាក់ទៅធ្វើមិនស្ទិត វាស្អិតៗ បកជ័រមិនលឿន*"។

ចន្ទីតែងស្រម៉ៃថា ខ្លួនហ្នឹងអាចចងក្រងក្រុមបានជោគជ័យក្នុងការលក់ជ័រកៅស៊ូ ទន្ទឹមហ្នឹងនេះចន្ទីក៏បានស្គាល់ពីខ្លួនឯងដែរថា "*ខ្ញុំមិនសូវមានទំនុកចិត្តនិងភាពក្លាហានក្នុងការនិយាយពីគោលបំណង នៃការចងក្រងក្រុមប្រាប់ទៅពួកគាត់នោះទេ*"។ ដើម្បីដោះស្រាយបញ្ហាមួយនេះ ចន្ទីបានសំណូមអោយមានជាវគ្គបណ្តុះបណ្តាលអំពីការពង្រឹងភាពក្លាហាននិងហ៊ាននិយាយជាសាធារណៈ។





"ជាមនុស្សស្រីកុំរៀនច្រើនពេក ត្រឹមចេះសរសេរអក្សរទៅបានហើយ កូនស្រីមិនចេះការងារផ្ទះសម្បែង ខ្មាសគេណាស់"។

**សម្រង់សម្ដីពីសាច់រឿងទី ៩**





# ការធ្វើបច្ចុប្បន្នភាព ស្ថានភាពរបស់ក្រុមស្ត្រី ផលិតកៅស៊ូជាលក្ខណៈគ្រួសារ

ក្រុមស្ត្រីផលិតកៅស៊ូជាលក្ខណៈគ្រួសារ ជាក្រុមមួយដែលបានចងក្រងឡើងពីតំណាងស្ត្រីដែលជា សមាជិក ហិរញ្ញិក អនុប្រធាន និងជាប្រធាន នៃក្រុមផលិតកៅស៊ូជាលក្ខណៈគ្រួសារ និងសហគមន៍កសិកម្ម នៅក្នុងស្រុកតំបែរ និងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ ក្រុមស្ត្រីផលិតកៅស៊ូជាលក្ខណៈគ្រួសារមានសមាជិក ១០នាក់ ដែលបង្កើតឡើងតាំងពីខែសីហា ឆ្នាំ២០២៣។ នៅខែមករា ឆ្នាំ២០២៥ កន្លងទៅ ក្រុមស្ត្រីផលិតកៅស៊ូជាលក្ខណគ្រួសារ បានចូលរួមជជែកពិភាក្សាជាលក្ខណៈក្រុម ដើម្បីធ្វើបច្ចុប្បភាពទៅលើការផ្លាស់ប្តូរ ស្ថានភាព និងតម្រូវការរបស់ពួកគាត់ បន្ទាប់ពីក្រុមស្ត្រី០៨នាក់ ធ្លាប់លើកឡើងនៅក្នុងសាច់រឿងពិតនៅក្នុង សៀវភៅ ទឹកភ្នែកពណ៌ស ដែលបានបោះពុម្ពនៅ  ឆ្នាំ២០២៣ ។

## តួនាទី និងការទទួលខុសត្រូវ

ក្នុងក្រុមផលិតកៅស៊ូលក្ខណៈគ្រួសារ នៃសហគមន៍កសិកម្មក្រុមស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តតួនាទីរបស់ខ្លួន ដែលធ្វើអោយក្រុមមើលឃើញពីសក្តានុពលរបស់ខ្លួន រហូតបានជម្រុញ លើកទឹក និងជ្រើសរើសគាត់អោយកាន់តួនាទីសំខាន់ៗក្នុងរចនាសម្ព័ន្ធនៃថ្នាក់សម្រេចចិត្ត។ ជាក់ស្តែង លោកស្រី ឡឹក កាពឿន បានក្លាយជាសមាជិក នៃក្រុមប្រឹក្សាភិបាល និងកញ្ញា ហ៊ូ ចន្ធី ក្លាយជាហិរញ្ញឹក នៃសហគមន៍កសិកម្ម។ ក្នុងនោះលោកស្រី ម៉េង ហាក់លីនដា បានលើកឡើងថា “ពេលនេះខ្ញុំជាអនុប្រធាននៃសហគមន៍កសិកម្មដូនមាសមានជ័យ។ កាលមុនគ្រាន់តែជាសមាជិកក្រុមផលិត បន្ទាប់មកជាហិរញ្ញឹក។ ក្នុងតួនាទីជាអនុប្រធាន ខ្ញុំកាន់លុយរបស់ក្រុមសហគមន៍ រៀបចំអាហារសម្រាន់ និងហៅសមាជិកមកប្រជុំ ជាដើម។ លើសពីនោះខ្ញុំកៀងគរសមាជិកបន្ថែម ក្នុងការលក់ជ័រកៅស៊ូជាក្រុម។ ពេលយើងប្រមូលបានគ្នាច្រើនទើបឈ្មួលអោយតម្លៃល្អ មិនក្រឡុកតម្លៃរបស់យើងបាន ហើយឈ្មួញក៏មានអោយភាគលាបចំនួន២០រៀល ក្នុងងមួយគីឡូកៅស៊ូដែលក្រុមបាន ដល់សហគមន៍ទៀតផង។ ដែលភាគលាប

នេះជាថវិកាក្រុមសម្រាប់ជួយទ្រទ្រង់ក្រុមបន្តទៀត។ លទ្ធផលនេះធ្វើអោយក្រុមសប្បាយចិត្តខ្លាំងណាស់ ហើយខ្ញុំក៏មានមោទនភាពលើខ្លួនឯងដែរ ដែលខ្ញុំអាចជួយក្រុមបាន”។ ក្នុងនាមជាប្រធានក្រុមផលិតម្នាក់ លោកស្រី អ៊ុក វណ្ណីក៏បានលើកឡើងថា “ខ្ញុំប្រមូលសមាជិកផង ដើរសុើបតម្លៃជ័រកៅស៊ូពីឈ្មួញកណ្តាលផង និងជជែកជាមួយឈ្មួញដើម្បីអោយក្រុម បានលក់កៅស៊ូបានតម្លៃល្អស្មើគេ”។

## ការចូលរួមនិងការផ្លាស់ប្តូរជាវិជ្ជមាន

នៅក្នុងការចូលរួមជាមួយក្រុមស្ត្រី និងជាមួយសហគមន៍កសិកម្ម ក្រុមស្ត្រីបានមានឱកាសចូលរួម ក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកា និងកិច្ចប្រជុំផ្សេងៗ តាមរយៈការរៀបចំបង្កើតឱកាស ដោយអង្គការសីលការ និងអង្គការដៃគូក្នុងគម្រោងបរិយាបន្នខ្សែច្រវាក់តម្លៃកសិកម្ម។ ការចូលរួមរបស់ក្រុមស្ត្រី បានធ្វើអោយពួកគាត់ទទួលបានចំណេះដឹងលើបច្ចេកទេសលើដំណាំកៅស៊ូ ក្នុងនោះក្រុមស្ត្រីបានលើកឡើងថា “ពេលចូលរួមជាក្រុមផលិត ឬសហគមន៍កសិកម្មបានធ្វើអោយ យើងដឹងពីព័ត៌មានរបស់សហគមន៍ផ្សេងៗ គំរូភាពការៀបចំបញ្ជី ចំណូល ចំណាយ ប្រចាំខែ ប្រចាំឆ្នាំ។ ចេះលើបច្ចេកទេស ទាំងការ ដាំដុះ ថែទាំការប្រមូលផល និងស្គាល់ឈ្មួញបានច្រើន។ បើការមុនវិញ មិនដឹងទេ ថាដីយើងត្រូវដាំពូជអ្វីអោយតែគេថាល្អ គឺដាំតាមគេហើយ”។ លោកស្រី ឡឹង ការពឿន បានបន្ថែមថា “កាលមុន ខ្ញុំមិនទាន់ដឹងថាពូជណាដាក់លើដីណាទេ អោយតែកូនកៅស៊ូចេះតែទិញយកមកដាំហើយ ។ ឥឡូវបានដឹងហើយ ដីខ្ញុំគេថាដាំ វីន៧១២ វាធនហ្នឹងខ្យល់ និងមិនបាក់។ ការជៀរក៏បានត្រឹមត្រូវដែរ មិនជៀរយកមុខធំៗដូចមុនទៀតទេ កាលមុនគិតថា អោយតែដាច់ធំ មានជ័រច្រើន តែការធ្វើចឹងយូរៗទៅធ្វើអោយខូចដើមកៅស៊ូទៅវិញ។ ការដាំក៏ចឹងដែរ តែដាំញឹកពេកមិនល្អដែរ ធ្លាប់តែគិតថាដាំញឹក បានដើមកៅស៊ូច្រើន មានជ័រច្រើនដែរ តែលោកគ្រូខាង អគ្គនាយកកៅស៊ូថា ដាំចឹងបានតែអុសដុតនោះទេ ស្តង់ដាកៅស៊ូដែលដាំល្អ ៦ ៣ (៦ជំហាននៃដើរដើរ និង៣ម៉ែត្រគំនាតពី ជួរមួយទៅ ជួរមួយទៀត)”។ នេះជាលទ្ធផលមួយនៃការផ្លាស់ប្តូររបស់ក្រុមស្ត្រីដែលចង់បាន កាលពីចូលរួមជាមួយក្រុមស្ត្រីដំបូង ដែលចំណេះដឹងទទួលបានទាំងនេះ បានជម្រុញអោយការផលិតជ័រកៅស៊ូរបស់ក្រុមស្ត្រី និងសហគមន៍ បានលទ្ធផលល្អជាងមុន មិនខូចដើមនិងលក់បានតម្លៃល្អ។ លើសពីនោះ នៅក្នុងវឌ្ឍនៈភាពវិជ្ជមានរបស់ក្រុមស្ត្រី ក៏មានលើកឡើងពីភាពក្លាហាន មានទំនុកចិត្ត ទំនាក់ទំនង និងស្មារតីក្រុមផងដែរ។ លោកស្រី ម៉េង ហាក់លីនដា បានលើកឡើងថា “ពីមុនតែលឺថាប្រជុំ គឺខ្លាចតែម្តង។ ជាលើកទីមួយដែលសម្រេចចិត្ត

ចូលប្រជុំជាមួយ សីលការ ហើយខ្ញុំនៅតែរំភើប អំពីអារម្មណ៍ដំបូងនៃកិច្ចប្រជុំមួយនោះ ហើយសប្បាយចិត្តដែលខ្ញុំបានបើកឱកាសខ្លួនឯង អោយសម្រេចចិត្តចូលរួមប្រជុំលើកនោះ។ ពេលបានចូលរួមបន្តបន្ទាប់មកទៀត ធ្វើអោយខ្ញុំក្លាហានហ៊ាននិយាយជាឈ្នួញកណ្តាល ធ្វើអោយតម្លៃស្ថិតនៅលើការជជែកគ្នា មិនមែននៅលើមាត់ឈ្នួញទៀតទេ។ នៅពេលដែលខ្ញុំមានទំនុកចិត្តលើខ្លួនឯង ខ្ញុំទទួលបានឱកាសច្រើន”។ ចំណែកឯ លោកស្រីឡឹក កាពឿន បានលើកឡើងថា “ពេលចូលរួមជាមួយក្រុមស្រី ខ្ញុំខំណាស់ គឺខំរៀនឡើងវិញ ខ្ញុំខានអានអក្សរយូឡើងភ្លេចបាត់ហើយ តែពេលបានចូលរួមខ្ញុំខំអាន ខំរៀន ក ខ ឡើងវិញ ពេលនេះចេះអានខ្លះវិញហើយ”។ ទន្ទឹមហ្នឹងភាពផ្លាស់ប្តូរជាវិជ្ជមាន ការចូលរួមរបស់ក្រុមស្ត្រី នៅក្នុងសហគមន៍ និងការទទួលបានឱកាសច្រើន ក៏ក្រុមស្ត្រីមួយចំនួនទទួលបានការគាំទ្រ និងលើកទឹកចិត្តពីក្រុមគ្រួសារ និងសហគមន៍ ចំពោះករណីនេះលោកស្រី ម៉េង ហាក់លីនដា បានចែករំលែកថា “ក្រុមគ្រួសារខ្ញុំគាត់សប្បាយចិត្តពេលឃើញខ្ញុំចូលរួមជាក្រុមសហគមន៍ និងក្រុមស្ត្រី ព្រោះខ្ញុំផ្លាស់ប្តូរច្រើន អាចទៅណាមកណាឆ្ងាយតែម្នាក់ឯងបាន និងធ្វើអោយផ្លូវចិត្តបានធូរស្រាលផង។

## វឌ្ឍនៈភាពនៃការផ្លាស់ប្តូរលើបញ្ហា និងតម្រូវការ

បញ្ហាមួយចំនួនក៏នៅបន្តកើតឡើងដូចជា ផ្នត់គំនិតអវិជ្ជមានលើស្ត្រី និងបន្ទុកការងារផ្ទះរបស់ស្ត្រី។ លោកស្រី ឡឹក កាពឿន បានលើកឡើងថា “ពេលខ្ញុំចូលរួមជាមួយសហគមន៍កសិកម្ម ខ្ញុំចំណាយពេលច្រើន ធ្វើការនៅក្នុងក្រុម ទាំងការរកសមាជិក និងចុះពិនិត្យបន្ថែមខ្លាចដល់ពេលលក់គ្មាន អ្នកមក រហូតដល់ពេលប្តីខ្ញុំគាត់បាននិយាយ ឯងចុះរហូតចឹង ការងារហ្នឹងគ្មានអ្នកណាធ្វើការទេមែន ធ្វើនោះធ្វើ រហូតភ្លេចការងារខ្លួនឯងនៅផ្ទះហើយ។ ពេលគាត់និយាយចឹងខ្ញុំឡើងយំ។ សម្រាប់ប្រធានសហគមន៍ ពេលខ្ញុំមកចូលរួមជាមួយក្រុមស្ត្រី គាត់មិនសប្បាយចិត្តនោះទេ។ ចំណែកលោកស្រី ម៉េង ហាក់លីនដា បានបន្ថែមថា “អ្នកខ្លះនៅតែនិយាយថា ស្ត្រីដើរទៅណាពិបាក ខ្ញុំឆ្លល់ដែរថា បើស្ត្រីពិបាកចឹង រើសស្ត្រីធ្វើអី ដាក់បុរសតែម្តងទៅ។ ខ្ញុំមានអារម្មណ៍ថា គេរើសយើងឱ្យតែបាន គេគិតថាយើង ជាស្ត្រីមេម៉ាយ ទៅណាជាមួយគេមានប្រុសចឹងខ្លាចប្រពន្ធគេប្រចណ្ឌ។ យើងទៅក្នុងទំនាក់ទំនងការងារ វាមិនលំបាកទេ ខ្ញុំអត់ធ្វើអីខុសទេ តែគេបៃជាផាត់ចេញ គេមិនដាក់ខ្ញុំឱ្យចូលរួមនោះទេ”។ បើឆ្លុះបញ្ចាំងពីស្ថានភាពនៃតម្រូវការរបស់ក្រុមស្ត្រី ដែលធ្លាប់លើកឡើងឃើញថា តម្រូវការមានការផ្លាស់ប្តូរជាវិជ្ជមានបានច្រើន។ សម្រាប់តម្លៃកៅស៊ូក៏មានខ្ពស់ជាងឆ្នាំមុន ទាំងជ័រកៅស៊ូទឹក និងជ័រកក។ សម្រាប់ទីផ្សារជ័រកៅស៊ូនាពេលបច្ចុប្បន្នមានតែឈ្នួញទិញជ័រកក មិនសូវមានទិញជ័រទឹកនោះទេ។ តែសម្រាប់

ក្រុមស្ត្រី ពួកគាត់ចង់លក់ជ័រទឹក ព្រោះជ័រទឹក មិនប្រើអាស៊ីតក្នុងការបង្កក ដែលចំណេញពេល និងមិនប៉ះពាល់សុខភាព។

ជាចុងក្រោយក្រុមស្ត្រី បានលើកឡើងនៅតម្រូវការមួយចំនួន ដើម្បីឆ្លើយតបស្ថានភាព និងដើម្បីកសាងសម្ថត្ថភាព  បន្ថែមសម្រាប់ក្រុមស្ត្រី។ ក្រុមស្ត្រី ចង់បានវគ្គនៃការគ្រប់គ្រងក្រុម ការរៀបចំឯកសារ បញ្ជីស្នាម និងផែនការ អាជីវកម្ម។

# សាច់រឿងទី៩

## ប្អូនស្រី សល់ ធារ៉ា ជាគណៈកម្មការនៅក្នុង សហគមន៍ព្រៃឈើភ្នំទុនតង់

យុវនារី សល់ ធារ៉ា អាយុ១៨ឆ្នាំ ដែលរស់នៅក្នុងភូមិកាណាត ឃុំតាឡាវ ស្រុកអណ្ដូងមាស ខេត្តរតនគីរី បានចូលរួមផ្ដល់កិច្ចសម្ភាសន៍ ស្ដីពីរបៀបវារៈយុត្តិធម៌សេដ្ឋកិច្ចបែបហ្វេមមីនីស។ ធារ៉ា ជាកូនកំព្រាឪពុក ដែលត្រូវរស់នៅជាមួយម្ដាយ និងប្អូនៗចំនួន២នាក់ទៀត នៅក្នុងស្ថានភាពជីវភាពខ្វះខាត។ ដើម្បីចិញ្ចឹមជីវិតក្រុមគ្រួសារធារ៉ា ត្រូវធ្វើស្រែដាំស្រូវ និងដាំដំឡូង។ ធារ៉ាជាក្មេងស្រីម្នាក់ ដែលរៀនបានត្រឹមតែថ្នាក់ទី៦ប៉ុណ្ណោះ ដោយសារតែជីវភាពគ្រួសារខ្វះខាត ហើយជាធម្មតានៅក្នុងសហគមន៍ ក្មេងៗជាពិសេសក្មេងស្រី មិនសូវបានរៀនខ្ពស់នោះទេ ភាគច្រើនត្រឹមកម្រិតបឋមសិក្សាតែប៉ុណ្ណោះ។ មានមនុស្សតិចណាស់ដែលបាន មានរៀននៅសកលវិទ្យាល័យ និងមានការងារធ្វើក្រៅពីការធ្វើស្រែចំការ និងកម្មករ ហើយពេលនេះមានយុវជនប្រហែលជា១០នាក់បានបន្តការសិក្សានៅកម្រិតសកលវិទ្យាល័យ ដែលភាគច្រើនសុទ្ធតែជាមនុស្សប្រុស។

យុវនារីធារ៉ា បានចូលរួមជាអ្នកស្ម័គ្រចិត្ត និងជាប់ជាសមាជិកនៅក្នុងគណៈកម្មការសហគមន៍ព្រៃឈើភ្នំទុនតង់ បន្ទាប់ពីមានការបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣។ នៅក្នុងការបោះឆ្នោតនោះដែរមានបេក្ខភាពសរុប ៣១នាក់ ស្រី០៥នាក់ តែបេក្ខភាពដែលបានជាប់ជាគណៈកម្មការសហគមន៍ព្រៃឈើ មានតែ១៦នាក់ ស្រី០៣នាក់ប៉ុណ្ណោះ។ នៅក្នុងសហគមន៍ព្រៃឈើភ្នំទុនតង់មានទំហំដីប្រហែល ៣០០០ហិចតា ដែលក្រុមអ្នកស្ម័គ្រចិត្ត និងគណៈកម្មការអភិរក្ស តែងតែចុះល្បាត និងដើរធ្វើបច្ចុប្បន្នភាពសត្វព្រៃ និងការពារឈើពីការកាប់បំផ្លាញពីជនដែលមិនមានការយល់ដឹងពីការថែរក្សាសត្វព្រៃ និងព្រៃឈើសហគមន៍។ ជាទូទៅការចុះល្បាតព្រៃសហគមន៍នេះ មានចំនួនអ្នកចូលរួមពី ០៧ទៅ០៨នាក់ មានប្រុសមានស្រីតាមការស្ម័គ្រចិត្ត ដែលមួយខែត្រូវចុះ០៣ដង ហើយមួយដងមាន០៣ថ្ងៃ។ នៅក្នុងអំឡុងពេលចុះអភិរក្សនោះក៏មានការចូលរួមពីប្រជាការពារភូមិ ឬអាជ្ញាធរ ភូមិឃុំផងដែរ។ ក្នុងនាមជាយុវជន និងជាអ្នករស់នៅក្នុងសហគមន៍ព្រៃឈើភ្នំទុនតន់តង់

ធារ៉ាបានលើកឡើងថា "*ខ្ញុំពិតជាស្រលាញ់សហគមន៍នេះណាស់ ហើយនេះជាហេតុដែលខ្ញុំចង់ចូលរួមជាអ្នកស្ម័គ្រចិត្ត ក្នុងសហគមន៍ព្រៃឈើភ្នំទុនតង់ ដើម្បីអោយក្មេងៗនៅជំនាន់ក្រោយបានឃើញសត្វព្រៃ និងព្រៃឈើនៅក្នុងសហគមន៍របស់យើង* ធារ៉ាបានបន្ថែមថា "*ខ្ញុំចង់អោយខ្លួនឯងមានភាពក្លាហាន ហ៊ាននិយាយស្តី ចេះទំនាក់ទំនង និងទទួលបានឱកាសផ្សេងៗ ដូចជាការបានទៅរៀន អំពីសង្វាក់ផលិតកម្មកៅស៊ូ និងចេក និងការរៀនថតរូបជាដើម៉*។ ការចុះល្បាតនៅក្នុងព្រៃឈើសហគមន៍ វាមិនងាយស្រួលនោះទេ ពេលខ្លះផ្លូវពិបាកជិះខ្លាំង ជាក់ស្តែងដូចជាពេលភ្លៀង ពេលខ្លះជិះម៉ូតូដួលហើយមានទាំងរបួស និងពេលខ្លះឈឺថ្កាត់នៅក្នុងព្រៃ ហើយគ្មានថ្នាំសង្កូវគ្រប់គ្រាន់។ មួយវិញទៀតគ្មានការលើកទឹកចិត្តពីអ្នកនៅក្នុងសហគមន៍មួយចំនួនដែលគាត់ថា" *ធារ៉ាអើយបើឈប់បានឈប់ទៅ វាអត់ប្រយោជន៍ ជាស្រីផង ខំម្លេះ យូរៗទៅដីសហគមន៍ហ្នឹងអស់ហើយ មិនបាច់ការពារនោះទេ*"។

តាមការសង្កេតរបស់ធារ៉ាការចុះល្បាតបើទោះបីជាមានស្រី  មានប្រុសចូលរួមក៏ពិតមែន តែយើងមិនបានបែងចែកការងារសម្រាប់មនុស្សស្រី ឬមនុស្សប្រុសផ្សេងគ្នានោះទេ តែជាធម្មតាការងារភាគច្រើនស្ត្រីតែងតែទទួលបន្ទុកលើការងារដាំស្លរ ថែទាំ និងមានការជួយពីបុរសខ្លះដែរ ចំណែកបុរសវិញទទួលបន្ទុកច្រើនលើការងារ រាប់សត្វ ដើរមើលព្រៃឈើ ថតរូប ធ្វើរបាយការណ៍ និងពេលខ្លះក៏មានការចូលរួមធ្វើពីមនុស្សស្រីផងដែរ។ បុរសដែលចូលរួមជាមួយកាងារចុះល្បាតក៏គាត់មានការគាំទ្រ ប្រាប់ជាបទពិសោធន៍ និងយកចិត្តទុកដាក់ក្នុងការមើលថែស្ត្រីដែលគាត់ចុះទៅជាមួយផងដែរ។ ក្រៅពីការងារស្ម័គ្រចិត្តនៅក្នុងសហគមន៍ ធារ៉ាក៏ទទួលបន្ទុកការងារផ្ទះ ធ្វើស្រែចំការ និងថែទាំប្អូនៗ ជាមួយម្តាយផងដែរ។ ធារ៉ាសង្កេតឃើញថានៅក្នុងសហគមន៍មានតែស្ត្រីទេ ដែលធ្វើការងារថែទាំក្នុងផ្ទះ ដូចជាបោកខោអាវ ដាំបាយ ស្លរ មើលកូនចៅ មើលម្តាយឪពុកចាស់ជរា ដាំស្រូវ ដាំដំឡូង ការងារសព្វគ្រប់ស្ត្រីធ្វើទាំងអស់។ កន្លងមកធារ៉ាតែងតែឆ្ងល់ថា "*ចាស់ៗ ថាមនុស្សស្រីតែមិនចេះធ្វើការងារផ្ទះទេ សុទ្ធតែពួកខ្ជិល ស្រីមិនល្អចឹងទៅ តែបើមនុស្សប្រុសមិនចេះធ្វើ ចាស់ៗមិនដែលថាអីអោយនោះទេ តែថាបើបុរសចេះធ្វើការងារផ្ទះវិញ តែតិចៗក៏ដោយ ក៏ចាស់ៗថាជាប្រុសល្អ ពូកែ ប្រពន្ធនោះសំណាងណាស់ដែលមានបុរសនោះធ្វើជាប្តី*"។ មានរឿងមួយទៀតដែលធារ៉ាតែងឆ្ងល់ថា "*ចាស់ៗថា បុរសគាត់ហត់ណាស់ ហត់ជាងស្ត្រីទៀត*"។ តែបើតាមការយល់ឃើញរបស់ធារ៉ាបានលើកឡើងថា "*ស្ត្រីទើបជាអ្នកដែលហត់ជាង ព្រោះស្ត្រី ធ្វើការងារទាំងក្នុងផ្ទះ ការងារក្រៅផ្ទះ (រកលុយ ដាំដុះ និងសហគមន៍) តែបុរសគាត់ធ្វើតែការងាររកលុយ និងការងារសហគមន៍ មកដល់ផ្ទះបើទំនេរ អង្គុយផឹកស៊ី ចុចទូរស័ព្ទ មិនជួយការងារប្រពន្ធទេ*"។ មួយវិញទៀតនៅក្នុងគ្រួសារនីមួយៗមានតែបុរសទេដែល

ជាមេគ្រួសារ ជាអ្នកសម្រេចលើធនធាន លើកូនៗ និងជាអ្នកដាក់ផែនការសម្រាប់គ្រួសារ។

នៅក្នុងសហគមន៍ការជ្រើសរើសគូរស្រករបស់កូនៗមួយចំនួនធំ គឺឪពុកម្ដាយជាអ្នកសម្រេចចិត្ត។ ហើយការរៀបការវ័យក្មេងក៏មានច្រើនខ្លាំងនៅក្នុងសហគមន៍របស់ធារ៉ាផងដែរ ដែលពេលខ្លះសាម៉ីខ្លួនទើបតែអាយុ១៣ឆ្នាំក៏មានដែរ និងភាគច្រើនត្រឹម១៨ឆ្នាំ ទៅ២០ឆ្នាំ គេរៀបការ ឬភ្ជាប់ពាក្យរួចអស់ហើយ។ នៅក្នុងសហគមន៍ តែងតែមានការលើកយកផ្នត់គំនិតសង្គមមកនិយាយប្រាប់ទៅក្មេងស្រីៗ និងធារ៉ាផងដែរថា "*ជាមនុស្សស្រីកុំរៀនច្រើនពេក ត្រឹមចេះសរសេរអក្សរទៅបានហើយ កូនស្រីមិនចេះការងារផ្ទះសម្បែង ខ្មាសគេណាស់*" ។ និងមានផ្នត់គំនិតសង្គមជាច្រើនទៀត ដែលបានប្រើប្រាស់នៅក្នុងសហគមន៍របស់ធារ៉ា។ ដែលផ្នត់គំនិតសង្គមទាំងនោះវាបានចាក់ឫសគល់យ៉ាងជ្រៅ នៅក្នុងផ្នត់គំនិត ឬជាការគិតរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ហើយវាជាបញ្ហាមួយដែលគ្រប់គ្នាគិតថាវាជារឿងធម្មតា ហើយបន្តអនុវត្តមកដល់សព្វថ្ងៃនេះ។







"ខ្ញុំសម្រេចចិត្ត ចូលរួមឈរឈ្មោះ ដោយសារខាងភូមិខ្ញុំអត់មានស្ត្រីចូលរួមច្រើន ហើយ
ខ្ញុំគិតថា ការងារអ្វីក៏ត្រូវការ បុរស និងស្ត្រី ចូលរួមដែរ"

**សម្រង់សម្ដីពីសាច់រឿងទី ១០**





# សាច់រឿងទី ១០

## បងស្រី ញុយ សុខា ជាគណៈកម្មការនៅ ក្នុងសហគមន៍តំបន់ការពារធនធានជាតិអូរ៉ៃ

បងស្រីសុខា មានអាយុ៤២ ឆ្នាំ មកពីភូមិនាងដី ឃុំស្រែពក ស្រុកកូនមុំ ខេត្តរតនគិរី។ ស្ថានភាពគ្រួសារ បងស្រីបានរៀបការ និងមានកូនចំនួន៣នាក់នៅក្នុងបន្ទុក។ កំរិតជីវភាព គ្រួសារ របស់បងស្រីស្ថិតនៅក្នុងកំរិតមធ្យម គ្រួសាររបស់បងស្រីប្រកបរបរកសិកម្មធ្វើស្រែចំការ ចិញ្ចឹមសត្វ ដាំបន្លែ និងចូលព្រៃរកអនុផលព្រៃឈើផងដែរ។ ក្រៅពីប្រកបការងារស្រែចំការ បងស្រីមានតួនាទីជា  គណកម្មការសហគមន៍តំបន់ការពារធនធានធម្មជាតិអូរ៉ៃសមាជិកក្រុម ទ្រទ្រង់ស្មគ្រ័ចិត្តភូមិ ពេទ្យស្មគ្រ័ចិត្ត ព្យាបាលជំងឺគ្រុនចាញ់ក្នុងភូមិ និងជាជំនួយការភូមិផង ដែរ។ បងស្រីបានរៀបរាប់ថា នៅពេលដែលគាត់ មានភារៈកិច្ចការងារចូលរួមជាមួយសហគមន៍ ប្ដីរបស់បងស្រីទទួលបន្ទុកលើការងារផ្ទះ ចំណែកគាត់ធ្វើការងារនៅពេលគាត់ទំនេរដៃពីការងារ ចុះសហគមន៍។ បងស្រីបាននិយាយទាំងទឹកមុខរីករាយថា គាត់ អាចចូលរួមការងារសហគមន៍ បានដោយសកម្មបែបនេះ គឺដោយសារតែគ្រួសារផ្តល់តម្លៃ សហគមន៍ និង ប្រជាពលរដ្ឋគាំទ្រ និងភូមិឃុំទទួលស្គាល់គាត់។ គាត់បានបន្ថែមថា "*គ្រួសារខ្ញុំគាត់ផ្តល់កម្លាំងចិត្ត ដូចថា យើង ទៅណាមកណា គឺគាត់មិនដែលមាន ការឈ្លោះប្រកែក ធ្វើអោយអសកម្មការងារអីយើងទេ ។*"

កាលពីពាក់កណ្តាលឆ្នាំ២០២២ ក្រោមការសម្របសម្រួលនិងសហការពី អាជ្ញាធរ មូលដ្ឋាន នៃភូមិចំនួនបួន មន្ទីរបរិស្ថាន និងអង្គការដៃគូរបានរៀបចំការបោះឆ្នោតសមាសភាព គណៈកម្មការ សហគមន៍តំបន់ការពារធម្មជាតិអូរ៉ៃ ដែលគ្របដណ្តប់ក្នុងភូមិសាស្ត្រភូមិចំនួនបួន នៃស្រុកកូនមុំ។ ការបោះឆ្នោត ជ្រើសរើសសមាភាពគណៈកម្មការអភិរក្សនៅក្នុងអាណត្តិទី២ បានប្រព្រឹត្ត តាមរយៈការបោះឆ្នោតតាម ភូមិនីមួយៗ ដើម្បីយកជនបង្គោលក្នុងមួយភូមិ៤នាក់ មានទាំងបុរស និងស្ត្រី បន្ទាប់ មកសមាសភាព ទាំង១៦នាក់ហ្នឹងត្រូវឈរឈ្មោះបន្តទៀត ដើម្បី ជ្រើសរើសប្រធាន អនុប្រធាន ២នាក់ ហិរញ្ញិក១នាក់ និងក្រៅពីនេះជាសមាជិកគណៈកម្មការ។ បងស្រីបានចែករំលែកថា "*ខ្ញុំសម្រេចចិត្ត ចូលរួមឈរឈ្មោះ ដោយសារខាងភូមិខ្ញុំអត់មានស្ត្រី*

*ចូលរួមច្រើន ហើយខ្ញុំគិតថា ការងារអ្វីក៏ត្រូវការ បុរស និងស្ត្រី ចូលរួមដែរ*"។ បងស្រីលើកឡើងថា "*ដំបូងខាងភូមិ និងខាងអង្គការ តម្រូវអោយមានស្ត្រី ចូលរួម ហើយខ្ញុំយល់ ថាការងារមួយត្រូវមានស្ត្រីបុរស ចឹងខ្ញុំក៏បានដាក់ឈរឈ្មោះ ដល់ពេលបោះឆ្នោតខ្ញុំក៏បានជាប់ កាលឈរឈ្មោះអោយគេបោះឆ្នោះមានស្រី២នាក់ក្នុងចំណោម អ្នកឈរឈ្មោះ គេបោះសរុបទាំងអស់៧នាក់។ ដល់ពេល បោះឆ្នោតរើសគណៈកម្មការដែលមកពី ៤ភូមិ អ្នកឈរឈ្មោះទាំងអស់ ១៦នាក់ មានស្រី៤នាក់។ តាមរយៈចំនួន និងសមាសភាពស្ត្រី អាចមាន ការចូលរួមតិចតួចនៅឡើយ ដោយបងស្រីលើកឡើងថា ដោយសារស្ត្រីនៅ ក្នុងភូមិខ្ញុំផ្ទាល់មិនមានការ ចេះដឹង ហើយគាត់ដូចជាមិនសូវ មានសមត្ថភាព និងមិនចេះ អក្សរជាដើម។ បើតាម មើលភាគច្រើន ដូចជាសកម្មភាពចុះភូមិ ចុះតាមអង្គការអី ស្ត្រីអត់ចង់ចុះទេ ដោយសារគាត់គិតថា គាត់ អត់ចេះ ចឹងវាជាឧបសគ្គសម្រាប់គាត់ តែបើថារឿង ចុះល្បាតអីស្ត្រីអាចចុះបាន។*"

បងស្រីបានរៀបរាប់ អំពីបទពិសោធន៍នៅពេលចុះល្បាតព្រៃដោយធ្វើការបែងចែកជាបួនក្រុមក្នុង មួយក្រុមមានគ្នា៤នាក់ក្នុងនោះមានស្ត្រីម្នាក់ ដែលជាទូទៅចុះមួយ១ខែម្តងប្រដេញគ្នាហើយការចុះ ល្បាតម្តងអាចត្រូវសម្រាកក្នុងព្រៃ២យប់។ ពេលចុះទៅជាក្រុម គឺពួកគាត់មានការបែងចែកការងារគ្នាដែរ បងស្រីសុខាប្រាប់ថា "*ប្រុសគាត់រៀបចំកន្លែងដេក ក៏គេរៀបអោយយើងដែរជួនកាលប្រុសទៅរកអុស ពេលខ្លះប្រុសអត់នៅយើងទៅកាច់ខ្លួនឯង ហើយខ្លះទៅដងកទឹកយកមកប្រើដើម្បីដាំបាយធ្វើម្ហូប ចែកគ្នា ធ្វើការទៅ គឺជួយគ្នា*" ហើយពេលធ្វើដំណើរចុះទៅ គឺម្នាក់ៗត្រូវជិះម៉ូតូរៀងខ្លួនដើម្បីដឹកបាឡូដាក់សម្ភារៈ អាហារខ្ចប់តិចតួចសម្រាប់ចុះល្បាតពីយប់។ បងស្រីសុខាបានសម្តែងចំណាប់អារម្មណ៍ថា "*ការចុះ ល្បាតដំបូងមានអារម្មណ៍ថា លំបាកដែរក៏ប៉ុន្តែតស៊ូ ការលំបាកនោះដូចថា ផ្លូវពិបាកខែវស្សា បើសិនខែប្រាំងស្រួលទោះបីមានក្រលីក្រលុកអីតែវាអត់មានរអិលអី។ ទោះលំបាកបែបណាយើងទៅដល់គោលដៅ ដូចបុរសដែរ បើថាពួកគាត់ (ប្រុសៗ) នៅមុខអីគាត់នៅចាំយើងដែរណា។ ចំពោះខ្ញុំអត់មានភ័យខ្លាចទេ ខ្ញុំទុកចិត្តដោយសារយើងចេះជួយគ្នា។*"

ជាការចាប់អារម្មណ៍ដែរ បងស្រីបានចុះប្រឡូកក្នុងការងារសហគមន៍ទាំងការងារអ្នកស្មគ្រ័ចិត្ត ភូមិ ជំនួយការភូមិ និងជាសមាជិកគណៈកម្មការអភិរក្ស គាត់បានកត់សម្គាល់អំពីការចូលរួមរបស់ ស្ត្រីនៅមាន កំរិត ជាពិសេសការសម្រេចចិត្តពាក់ពន្ធ័ហ្នឹងសហគមន៍។ តួយ៉ាងបងស្រីលើកឡើងថា "*បុរស ចូលរួមប្រជុំ ច្រើនជាង ជាពិសេសការសម្រេចចិត្តធំទាក់ទងហ្នឹងសហគមន៍ តែបើការប្រជុំអត់ មានការសម្រេចចិត្តទេ គឺភាគច្រើនគឺស្ត្រី*"។ បងស្រីចង់អោយស្ត្រីចូលរួមបានច្រើនជាងមុននៅក្នុងការ ជជែកអំពីបញ្ហា និងលើក ឡើងអំពីតម្រូវការ

របស់ពួកគេ ដោយគាត់មានចំណាប់អារម្មណ៍បែបនេះថា "*មនុស្សស្រីយើងក៏មាន តម្រូវការច្រើនដែរ បើអត់បានចូលរួមទេ បញ្ហា និងតម្រូវការហ្នឹងក៏មិនត្រូវបានដោះស្រាយដែរ ហើយក៏មិនដឹងពីព័ត៌មានអ្វីៗទាំងអស់ ។ ថ្ងៃខាងមុខខ្ញុំចង់ឃើញស្រ្តីចូលរួមព្រោះស្រ្តី គឺជាធនធានមួយក្នុង សង្គម គឺស្រ្តីអាចក្លាយខ្លួនជាមេដឹកនាំ ខ្ញុំជឿថា ស្រ្តីអាចធ្វើបាន ដែលទី១ គឺគាត់មានសមត្ថភាព និងទី២កាយសម្បទាគ្រប់គ្រាន់ ទី៣គាត់មានបញ្ញាវាងវៃ។*" ក្រៅពីនេះបងស្រីសុខាបានធ្វើការឆ្លុះបញ្ចាំង ពីការវិវឌ្ឍជាវិជ្ជមានរបស់ស្រ្តីក្នុងការចូលរួមក្នុងសហគមន៍ និងការផ្លាស់ប្តូរផ្នត់គំនិតមួយចំនួន ដែលមានលក្ខណៈរើសអើងស្រ្តី និងបង្កើតបង្កើតគម្លាតរវាងបុរស និងស្រ្តីនេះ ប្រៀបធៀបកាលពីអតីតកាល និង បច្ចុប្បន្ននេះ។ គាត់លើកថា "*បុរសនិងស្រ្តី ដូចមិនសូវមានគម្លាត ឆ្ងាយដែរ ដោយមិនមានការបែងចែក ការងារគ្នាអីដែរ គឺចេះជួយគ្នា ដោយសារឥឡូវយើងទទួលព័ត៌មាន ច្រើន គាត់លះបង់អប្បិយជំនឿខ្លះពី ដើមដែរ ដូចជាពីមុនគេថាចាក់បាយជ្រូក បាយអីហ្នឹង ធ្វើម្ហូបអី គឺប្រុសទៅធ្វើអីវាជាការងារស្រី។*"

ចំពោះការបារម្ភវិញ  គឺបងស្រីបានលើកឡើងថា  "*ខ្ញុំខ្លាចយើងមិនចេះឃោគយល់គ្នាសហគមន៍លែងគាំទ្រយើងក្នុងការធ្វើការងារសហគមន៍។ ចំពោះចុះល្បាតអីខ្លាចជួបមនុស្សបៀតបៀនដូចអ្នកលួចកាប់ ឈើបើត្រឹមសហគមន៍អីអត់អីទេយើងអាចណែនាំនិងធ្វើកិច្ចសន្យាទៅរួចរាល់ហើយតែបើចាប់អីខ្លាំងៗគឺយើងរាយការណ៍ទៅខាងបរិស្ថានដោះស្រាយ*"។

ចុងក្រោយបងស្រីសំណូមពរថា "*ខ្ញុំចង់ស្នើរពង្រឹងសមត្ថភាព និងចំណេះដឹងដល់ស្រ្តីដែល គាត់ កំពុងខ្វះខាត។ ចំពោះខ្ញុំជាគណកម្មការ វិញខ្ញុំត្រូវការចំណេះដឹង ទៅលើការនិយាយស្តី ចង់ថានិយាយទៅ អោយចំគោលដៅច្បាស់លាស់ពេល និយាយជាមួយគេដើម្បីអោយគេស្តាប់យើង។*"















"ពេលខ្ញុំចុះទៅល្បាតព្រៃ លើកដំបូង គឺខ្ញុំមានអារម្មណ៍ ភ័យខ្លាចដែរ ពេលខ្លះយើងស្រី
ចឹងយើងពិបាក ដូចថាពេលបងប្អូន មកលេង(មករដូវ) យើងពិបាកដើរ ហើយអត់បាន
យកអីមកតាម(សំឡី) ហើយដាំបាយអីអត់កើតមាន តែដូរគ្នា"

**សម្រង់សម្ដីពីសាច់រឿងទី ១១**




California

# សាច់រឿងទី១១

## ប្អូនស្រី ឡៃ មៀ ជាគណៈកម្មការនៅក្នុង សហគមន៍ព្រៃឈើភ្នំទុនតង់

ឡៃ មៀ មានអាយុ១៧ឆ្នាំ ជាសមាជិកសហគមន៍ភ្នំទុនតង់ និងកសិករ រស់នៅភូមិកាណាត់ ឃុំតាឡា ស្រុកអណ្តូងមាស ខេត្តរតនគិរី មានស្ថានភាពគ្រួសារ មធ្យម។ ប្អូនស្រីរាល់ថ្ងៃរស់នៅជាមួយ ប៉ាម៉ាក់ មិនទាន់មានគ្រួសារទេ ចំណែកគ្រួសារទាំងមូលគឺធ្វើស្រែចំការផងដែរ សព្វថ្ងៃគាត់មាន បងប្អូនបួន នាក់ ស្រី២ និងប្រុស២នាក់។ សកម្មភាពជាប្រចាំនៅក្នុងគ្រួសារ គឺដាំស្រូវ ដាំដំឡូង ដែលការងារ ត្រូវធ្វើរួមគ្នានៃសមាជិកក្នុងគ្រួសារ ដោយឡែកសម្រាប់ការងារថែទាំ ចង្ក្រានជើងឆ្នាំង ដាំបាយធ្វើម្ហូប ភាគច្រើន គឺជាបន្ទុករបស់សមាជិកស្ត្រីក្នុងគ្រួសារ សម្រាប់គ្រួសារឡៃមៀ គឺគាត់ និងម្តាយជា អ្នកទទួលបន្ទុករ៉ាប់រងការងារទាំងអស់នេះ។ ជាទំលាប់គ្រួសាររបស់ឡៃមៀ គឺបន្ទាប់ពីទៅដាំស្រូវ និងដាំដំ ឡូង ជាប្រចាំថ្ងៃ ពេលមកដល់ផ្ទះស្រីៗបន្តការងារថែទាំ ចំណែកសមាជិកបុរស គាត់មានពេលសម្រាក លេង ទូរសព្ទ័ និងចេញខាងក្រៅជាដើម។ ឡៃមៀបានលើកឡើងថា ការដែលក្មេងស្រីត្រូវទទួលបន្ទុក ការងារផ្ទះ នេះដោយសារទំលាប់ តាមគ្រួសារកូនស្រី ត្រូវគ្រួសារ ឬចាស់ទុំក្នុង ភូមិប្រាប់ថា "*កូនស្រីត្រូវតែ រៀនធ្វើម្ហូប និងការងារផ្ទះសម្បែង ព្រោះពេលរៀបការទៅទើបម្តាយក្មេកមិនមើលងាយ*" ចំណែកក្មេង ប្រុស ឬបុរស វិញ គឺពួកគេមិនរវីរវល់ជាមួយការងារផ្ទះនេះឡើយ។

ដោយឡែកក្រៅពីការងារជាកសិករ និងទទួលបន្ទុកទៅលើការងារថែទាំងក្នុងផ្ទះ ឡៃមៀក៏ជាសមាជិកនៃ សហគមន៍អភិរក្សព្រៃឈើភ្នំផងដែរជាការងារស្ម័គ្រចិត្តមួយដែលឡៃមៀធ្លាប់បានចូលរួម ក្នុងការការពារព្រៃឈើនិងសត្វព្រៃមួយនេះផងដែរ។ ឡៃមៀធ្លាប់មានបំណងក្នុងការឈរឈ្មោះជាសមាជិក នៃ គណៈកម្មការអភិរក្សភ្នំនេះដែរ តែដោយសារមានបញ្ហាសុខភាព គាត់ក៏មិនបានចូលរួម ឈរឈ្មោះជា បេក្ខភាពនាពេលនោះដែរ។ ឡៃមៀលើកឡើងថា "*ខ្ញុំចង់ឈរឈ្មោះជាគណៈកម្មការដែរបើសិនជាសហគមន៍បោះឆ្នោតអោយខ្ញុំ ហើយខ្ញុំគិតថាខ្ញុំអាចធ្វើការងារនេះបាន*"។ ឡៃមៀធ្លាប់បានចុះល្បាតព្រៃចំនួន ២ខែ រួចមកហើយជាមួយសហគមន៍របស់គាត់ ដែលក្នុងនោះមួយខែត្រូវចុះទៅល្បាតព្រៃ ៣ដង ហើយក្នុងមួយដង គឺ៣ថ្ងៃជាប់គ្នា។

ឡែមៀបានប្រាប់ថា "*ពេលខ្ញុំចុះទៅល្បាតព្រៃ លើកដំបូង គឺខ្ញុំមានអារម្មណ៍ ភ័យខ្លាចដែរ ពេលខ្លះយើងស្រីចឹងយើងពិបាក ដូចថាពេលបងប្អូន មកលេង(មករដូវ) យើងពិបាកដើរ ហើយអត់បានយកអីមកតាម(សំឡី) ហើយដាំបាយអីអត់កើតមាន តែដូរគ្នា*"។ ក្រៅពីនេះ ពេលចុះព្រៃ គឺមានតែ ស្រីៗពីរនាក់ ដែលជាមិត្តភក្តិគាត់បានចូលរួមក្នុងការចុះ ល្បាតព្រៃជាមួយក្រុមបុរស ដែលពួកគេ ទាំងពីរត្រូវធ្វើដំណើរដោយម៉ូតូឌុបគ្នា ហើយការងារចំបង ដែលស្ត្រីត្រូវធ្វើ គឺការចំអិនម្ហូប សម្រាប់ក្រុមហូប ចំណែកបុរសៗគឺ ពួកគេបែងចែកគ្នាទៅមើលព្រៃ រាប់ចំនួនសត្វ និងថតរូបដើម្បីធ្វើរបាយការណ៍។ ឡែមៀបានបង្ហាញពី ការចាប់អារម្មណ៍របស់គាត់ដោយ គាត់បានលើកឡើងថា គាត់ចុះល្បាត ព្រៃដោយ សារគាត់ចង់ពង្រឹងភាពក្លាហានរបស់ខ្លួន បង្កើតទំនាក់ ទំនងជាមួយអ្នកដទៃ។ ចំពោះ ការចូលរួមនេះដែរ គឺឡែមៀ មានការ

អនុញ្ញាតិពីឪពុកម្តាយអោយចូលរួម ជាមួយអ្នកផ្សេងទៀត ដើម្បីរៀនសូត្រ ឡែមៀក៏បានបញ្ជាក់ ថាបើឪពុកម្តាយមិនអនុញ្ញាតិទេ គឺគាត់ក៏ មិនហ៊ានចុះទៅដែរ។ ឡែមៀបានលើកឡើងថា សហគមន៍មិនមាន ការរារាំងអីគាត់ទេក្នុងការចុះល្បាត និងការចូលរួមជាមួយគណកម្មការអភិរក្ស។ គាត់ថា បើសិនមានឱកាស នៅពេលខាងមុខក្នុងការចូលរួម ជាគណៈកម្មការឡែមាក៏ចង់ចូលរួមដែរ ដើម្បីមានឱកាសរៀនសូត្រ ចូលរួម និងជជែកពិភាក្សាជាមួយ អ្នកពាក់ពន្ធ័នៅក្នុងសហគមន៍របស់គាត់ ដើម្បីពង្រឹង ភាពអង់អាចរបស់ខ្លួន។ ឡែមៀចង់អោយមាន ចំនួនស្ត្រីចូលរួមបន្ថែមក្នុងការងារអភិរក្ស ដើម្បីរៀនសូត្រ និងចូលរួមការពារ សហគមន៍របស់ពួកគេ។





"មានពេលខ្លះក៏មានអ្នកសរសើរទៅ ថាយើងពូកែ ចេះខិតខំប្រឹងប្រែង ក្លាហាន តែពេលខ្លះក៏មានអ្នកនិយាយថា ធ្វើការងារសហគមន៍អីវាគ្មានប្រយោជន៍ទេ ការងារហ្នឹងគ្មានប្រាក់កម្រៃផង មកពីចេះតែទៅប្រជុំនេះ ទៅប្រជុំនោះហ្នឹងហើយទើបប្តីប្រច័ណ្ឌ"

**សម្រង់សម្តីពីសាច់រឿងទី ១២**





# សាច់រឿងទី១២

## បងស្រី សែន ស៊ីផុន ជាគណៈកម្មការនៅក្នុងសហគមន៍តំបន់ការពារធនធានជាតិអូរ៉ៃ

លោកស្រី សែន ស៊ីផុន ជាអនុប្រធានទី១ នៃគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិអូរ៉ៃ ដែលរស់នៅភូមិប្រាំ ឃុំត្រពាំងច្រេស ស្រុកកូនមុំ ខេត្តរតនគីរី បានចូលរួមផ្តល់កិច្ចសម្ភាសន៍នៅក្នុងគម្រោង បរិយាប័ន្នខ្សែច្រវ៉ាក់ផលិតកម្មចេក និងកៅស៊ូ (Fair4 All) ដែលអនុវត្តន៍ដោយអង្គការសីលការ។ ក្នុងកិច្ចសម្ភាសន៍លោកស្រីបានប្រាប់ថា "*សព្វថ្ងៃលោកស្រីជាស្ត្រីមេម៉ាយ ដែលបានលែងលះគ្នាអស់រយៈពេលកន្លះឆ្នាំមកហើយ កាលនៅជួបជុំគ្នាប្តីលោកស្រីមិនដែលជួយគ្នាក្នុងរកស៊ី ឬធ្វើការងារស្រែចំការអ្វីនោះទេ លោកស្រីជាអ្នករ៉ាប់រងទាំងអស់ គឺគាត់គិតតែផឹក និងរករឿងប្រច័ណ្ឌលោកស្រីពេលចេញទៅធ្វើការងារសហគមន៍ផ្សេងៗ*"។

លោកស្រី ស៊ីផុន បានចូលរួមជាអ្នកស្ម័គ្រចិត្តជាមួយសហគមន៍នេសាទនៅឆ្នាំ២០១៧ បន្ទាប់មកនៅឆ្នាំ២០២២ លោកស្រីបានជាប់ជាអនុប្រធានទី១ ក្នុងការឈរឈ្មោះអោយប្រជាពលរដ្ឋបោះឆ្នោត ជ្រើសរើសគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិអូរ៉ៃ។ គណៈកម្មការសហគមន៍នេះមានសមាភាពចំនួន០៩នាក់ ស្រី០២នាក់បន្ទាប់ពីបោះឆ្នោតហើយ តែបច្ចុប្បន្ននៅសល់តែ០៥នាក់ ស្រី០១នាក់ទេ និងមានសមាជិកសហគមន៍តាមភូមិចំនួន០៤ភូមិទៀត គឺភូមិនាងដី ស្រែពកធំ ស្រែពកតូច ក្នុងឃុំសរីមង្គល និងភូមិប្រាំ ក្នុងឃុំត្រពាំងច្រេស ស្រុកកូនមុំ។ ព្រៃសហគមន៍មានទីតាំងនៅជិតក្រុមហ៊ុនចំការចេកហង់អញលំផាត់ ទើបកន្លងមកតែងតែមានករណីដាក់អន្ទាក់សត្វ ការចូលបរបាញ់ខុសច្បាប់ពីសំណាក់កម្មករ ដែលរស់នៅក្នុងចំការចេក។ មួយវិញទៀតការប្រើប្រាស់ថ្នាំស្មៅ ឬថ្នាំពុលផ្សេងៗ ព្រមទាំងការទុកដាក់សំរាម ដូចជាកំប៉ុងថ្នាំ កាកសំណល់ពីចេក ដែលត្រូវបោះចោល មិនរៀបចំទុកដាក់អោយបានស្រួលបួល និងបានសុវត្ថិភាព ទើបធ្វើអោយសំរាមមួយចំនួនបានធ្លាក់ចូលទៅក្នុងទន្លេស្រែពក ដែលបង្កអោយមានជាតិពុល បណ្តាលអោយងាប់ត្រី ប៉ះពាល់ដល់សត្វព្រៃ ព្រោះថាប្រភពទឹកនោះ មានសត្វព្រៃជាច្រើនមកផឹកទឹកនោះដែរ និងមានប្រជាពលរដ្ឋមួយចំនួនក៏ប្រើប្រាស់ទឹក

នៅក្នុងទន្លេស្រែពកផងដែរ។

តាមប្រសាសន៍របស់លោកស្រី កាលពីជំនាន់ប្រធានគណៈកម្មការមុន ខាងក្រុមហ៊ុនបានសន្យាថា *"ទី១ ក្រុមហ៊ុនហ្នឹងជីកប្រឡាយនៅក្បែរបង្គោលភ្លើង(ដាក់ចូលមកដីព្រៃសហគមន៍) ដើម្បីទប់ស្កាត់បទល្មើសពីកម្មករនៅក្នុងចំការ កុំអោយគេចេញចូលតាមចិត្តបាន ទី២ ក្រុមហ៊ុនសន្យាក្នុងការផ្តល់ថវិកាចំនួន១០០ដុល្លារ/ម្នាក់ ដល់គណៈកម្មការ ទី៣ ក្រុមហ៊ុនសន្យាផ្តល់សម្ភារៈដូចជា តង់ វ៉ាឡូ ស្បែកជើង ។ល។ ក្នុងការចុះទៅល្បាតដល់សហគមន៍ ដែលសរុបជាទឹកប្រាក់អស់ប្រហែល១០០០ដុល្លារ និងទី៤ ក្រុមហ៊ុនសន្យាថាហ្នឹងធ្វើរោងប្រជុំសម្រាប់សហគមន៍ នៅក្នុងតម្លៃ៨០០ដុល្លារ។ នៅក្នុងអាណត្តិថ្មីនេះ ខាងគណៈកម្មការ រួមទាំងខ្ញុំ ក៏បានទៅជួបតំណាងក្រុមហ៊ុនម្តងទៀតដែរ ដើម្បីអោយក្រុមហ៊ុនធ្វើតាមកិច្ចសន្យា តែបុគ្គលិកដែលបាននិយាយសន្យាលើកមុនជាមួយប្រធានចាស់នោះ គាត់បានឈប់ធ្វើការជាមួយក្រុមហ៊ុនហើយ ហើយពេលនេះផ្តល់តួនាទីបន្តដល់អ្នកថ្មីដែរ ហើយក្នុងកិច្ចប្រជុំនេះ គាត់ថា ចាំគាត់ដោះស្រាយ និងផ្តល់ចម្លើយអោយ តែមកដល់ពេលនេះហើយមិនបានអោយអ្វីនោះទេ"*។

សហគមន៍ព្រៃឈើអូររៃមានទំហំផ្ទៃដីសរុប ២,៦៨០ហិចតា បានចុះបញ្ជីទទួលស្គាល់ថាជាដីសហគមន៍អភិរក្សព្រៃឈើ និងសត្វព្រៃរួចហើយ។ គណៈកម្មការសហគមន៍ក៏បានរៀបចំការផែនការចុះល្បាតក្នុង០១ខែ មានចំនួន០៣ដង និងក្នុង០១ដង មាន ០៣ថ្ងៃ ០២យប់។ សម្រាប់ក្រុមចុះល្បាតមានចំនួន០៤នាក់ ស្រី០១ ក្នុង០១ក្រុមផងដែរ។ ដែលអ្នកចុះល្បាតម្នាក់ៗត្រូវជិះម៉ូតូ និងដឹកអីវ៉ាន់ទៅដោយខ្លួនឯង។ ការចុះទៅល្បាតក្នុងព្រៃសហគមន៍អូររៃ ក្នុងគោលបំណងទៅមើលក្រែងមានគេលួចកាប់ឈើ ដាក់អន្ទាក់សត្វព្រៃ និងរាប់សត្វព្រៃជាដើម។ បើមានករណីដែលជនខិលខូចគាត់លួចកាប់ឈើ ឬដាក់អន្ទាក់សត្វ យើងបានត្រឹមតែហាមឃាត់គាត់ ណែនាំគាត់ ដកអន្ទាក់ចេញ តែមានករណីហាមមិនស្តាប់ ឬធ្ងន់ធ្ងរ យើងអាចទៅប្តឹងទៅខាងមន្ត្រីបរិស្ថាន ដើម្បីអោយគាត់ជួយដោះស្រាយ។

ការងារមិនបានបែកចែកភេទក្នុងការធ្វើនោះទេ តែមនុស្សទេដែលជាអ្នកបែកចែកការងារទៅតាមភេទ ជាក់ស្តែងនៅពេលដែលអ្នកស្រមៃទៅដល់ការចុះទៅល្បាតនៅក្នុងព្រៃ អ្នកប្រាកដជាគិតថាមានតែមនុស្សប្រុសទេដែលធ្វើការងារមួយនេះ តែពេលដែលមានមនុស្សស្រីធ្វើ តើអ្នកគិតយ៉ាងណាចំពោះគាត់ ហើយគាត់ទទួលបានការគាំទ្រពីអ្នកជុំវិញខ្លួនដែរឬទេ? ក្នុងនាមជាស្ត្រីម្នាក់ ដែលបានចូលរួមក្នុងការងារស្ម័គ្រចិត្ត និងជាអ្នកចុះល្បាតផ្ទាល់ ទៅជាមួយក្រុមគណៈកម្មការអភិរក្ស លោកស្រី ស៊ីផុន លើកឡើងថា *"ខ្ញុំអត់មានគេរើសអើងដោយសារខ្ញុំជាស្រីទេ បុរសម្នាក់ៗនៅក្នុងក្រុម គាត់ស្តាប់ខ្ញុំ និងយល់ពីទុកលំបាករបស់ខ្ញុំណាស់។ បើ*

*ពីមុនមានតិចតួចដែរ ដែលស្ត្រីនិយាយទៅគេមិនសូវស្តាប់ ដោយសារសម្លេងយើងភាគតិច"*។ លោកស្រីបន្តថា "*មានពេលខ្លះក៏មានអ្នកសរសើរទៅ ថាយើងពូកែ ចេះខិតខំប្រឹងប្រែង ក្លាហាន តែពេលខ្លះក៏មានអ្នកនិយាយថា ធ្វើការងារសហគមន៍អីវាគ្មានប្រយោជន៍ទេ ការងារហ្នឹងគ្មានប្រាក់កម្រៃផង មកពីចេះតែទៅប្រជុំនេះ ទៅប្រជុំនោះហ្នឹងហើយទើបប្តីប្រច័ណ្ឌ*"។ ការចុះល្បាតព្រៃវាមែនជារឿងងាយស្រួលនោះទេ សម្រាប់អ្នកចុះល្បាត ហើយក៏មិនសូវមានអ្នកចង់ចុះទៅល្បាតព្រៃឈើនោះដែរ ជាក់ស្តែងលោកស្រីបាននិយាយថា *"ការចុះល្បាតហត់ណាស់ មនុស្សស្រីគេមិនចង់ទៅនោះទេ ហើយមានការលំបាកច្រើនដូចជា ផ្លូវស្ទាត់ មូសខាំ ផ្លូវពិបាក ពេលភ្លៀងធ្លាក់ ឈឺ អត់ថ្នាំពេទ្យ ណាមួយក្នុងក្រុមមានស្រីតែម្នាក់ និងពេលខ្លះក៏មានអារម្មណ៍ថាខ្លាចមនុស្សផងដែរ*"។ ប៉ុន្តែក្នុងនាមជាស្ត្រីម្នាក់ដែលស្រលាញ់សហគមន៍ ស្រលាញ់ព្រៃឈើ និងសត្វព្រៃ លោកស្រីស៊ីផុន មិនដែលរាថយហ្នឹងបញ្ហាដែលជួប និងចង់បោះបង់ចោលការងារដែលកំពុងតែធ្វើនេះទេ។

ក្នុងការសម្រួលបញ្ហាដែលកើតចំពោះលោកស្រី និងសហគមន៍ អង្គការជីវិត និងធម្មជាតិនៅកម្ពុជាបានផ្តល់អោយសហគមន៍នូវថ្នាំមួយចំនួនដូចជា ថ្នាំបំបាត់ការឈឺក្បាល វិលមុខ ឈឺពោះ ថ្នាំលាបជើង ថ្នាំគ្រុនចាញ់ មានថ្នាំ និងសម្ភារៈជាច្រើនទៀត។ ទទឹមហ្នឹងដែរ លោកស្រីក៏បានលើកជាសំណូមពរផងដែរថា "*ខ្ញុំចង់អោយមានស្ត្រីចូលរួមចុះល្បាតអោយបានច្រើន និងចង់អោយក្រុមចុះល្បាតមាន មនុស្សស្រីទៅមួយវគ្គ ២នាក់ណាស់ ព្រោះងាយស្រួល និងមានគ្នាអាចពឹងពាក់ ទៅងូតទឹកបាន២នាក់ មានអារម្មណ៍ថាមានសុវត្ថិភាព និងយល់ពីគ្នាបានច្រើនជាងបុរស។ មួយទៀតខ្ញុំចង់អោយមានថ្នាំសង្កូវបន្ថែមទៀតក្នុងការព្យាបាលបឋមបាននៅពេលមានបញ្ហាក្នុងការចុះល្បាត និងចង់អោយមានប្រដាប់ប្រដារជុសជុលម៉ូតូនៅពេលជិះទៅចុះល្បាត ហើយខូច*។ "សម្រាប់ការពង្រឹងកការចូលរួមដល់ស្ត្រី លោកស្រីស្នើសុំអោយមានជា "*វគ្គបណ្តុះបណ្តាលដល់សហគមន៍ អំពីភាពជាអ្នកដឹកនាំ សម្របសម្រួល និងការនិយាយជាសាធារណៈ ចង់អោយមានវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនាញកាត់ដេរខោអាវ ឬដេរកាបូបដល់អ្នកនៅក្នុងសហគមន៍ និងសុំអោយបុរសផ្តល់ឱកាសដល់ស្ត្រី កុំរារាំងដល់ស្ត្រីនៅក្នុងការចូលរួមការងារសង្គម*"។ ក្នុងនាមជាអ្នកដែលស្រលាញ់សហគមន៍លោកស្រីថា "*មនុស្សនៅក្នុងសហគមន៍ទាំងអស់គួរតែជួយថែរក្សាព្រៃឈើ និងសត្វព្រៃ ព្រោះយើងម្នាក់ៗក៏រស់ពឹងលើព្រៃឈើដែរ ព្រៃឈើមិនត្រឹមតែជួយស្រូបទឹកមិនជន់លិច ឬទាក់ទាញទឹកភ្លៀងនោះទេ សហគមន៍ក៏អាស្រ័យអនុផលព្រៃឈើដូចជា បេះផ្សិតប៉ក ផ្សិតក្ងោក ផ្សិតតាសេក ផ្សិតកញ្ចោ កាច់ត្រពាំងឬស្សីព្រិច ឬស្សីខ្លី យកទឹកឃ្មុំ និងស្លឹកឈើផ្សេងៗដែលអាចហូបបាន យកមកហូប ឬលក់បានកម្រៃបានទៀតផង*"។





# ការធ្វើបច្ចុប្បន្នភាព ស្ថានភាពរបស់ក្រុមស្ត្រី អភិរក្សធនធានធម្មជាតិ

ក្រុមស្ត្រីអភិរក្សធនធានធម្មជាតិ ជាក្រុមមួយដែលបានចងក្រងឡើងពីស្ត្រីដែលជា យុវជន សមាជិក និងជាអនុប្រធាន នៃគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិអូររ៉ៃ ក្នុងស្រុកកូនមុំ និងគណៈកម្មការសហគមន៍ព្រៃឈើភ្នំទុនតង់ ក្នុងស្រុកអណ្តូងមាស ខេត្តរតនគិរី។ ក្រុមស្ត្រីអភិរក្សធនធានធម្មជាតិ មានសមាជិក ១០នាក់ ដែលបង្កើតឡើងតាំងពីខែសីហា ឆ្នាំ២០២៣។ នៅ ខែមករា ឆ្នាំ២០២៥ កន្លងទៅ ក្រុមស្ត្រីអភិរក្សធនធានធម្មជាតិ បានចូលរួមជជែកពិភាក្សាជាលក្ខណៈក្រុម ដើម្បីធ្វើបច្ចុប្បភាពទៅលើការផ្លាស់ប្តូរ ស្ថានភាព និងតម្រូវការរបស់ពួកគាត់ បន្ទាប់ពីសមាជិក ០៤នាក់ ធ្លាប់លើកឡើងនូវសាច់រឿងពិត របស់គាត់នៅក្នុង សៀវភៅ ទឹកភ្នែកពណ៌ស ដែលបោះពុម្ពនៅឆ្នាំ២០២៣ ។

## តួនាទី និងការទទួលខុសត្រូវ

ក្នុងរយៈពេល១៦ខែ បន្ទាប់ពីចងក្រងសាច់រឿងរបស់ក្រុមស្ត្រីលើកទី០១មកសមាសភាព តួនាទីរបស់ក្រុមស្ត្រី នៅក្នុងជួរនៃគណៈកម្មកាសហគមន៍មិនមានអ្វីប្រែប្រួលនោះទេ។ ជាក់ស្តែងលោកស្រី សែន ស៊ីផុន លើកឡើងថា “ខ្ញុំមានតួនាទីជាអនុប្រធានទី០១ នៃគណៈកម្មការអភិរក្សធនធានធម្មជាតិអូររ៉ៃ។ សម្រាប់គណៈកម្មការសហគមន៍ រយៈពេលប្រាំឆ្នាំទើបបោះឆ្នោតម្តង ដូចនេះនៅសល់មួយឆ្នាំជាងទៀត បានដល់ពេលបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍ម្តងទៀត”។ ការចុះល្បាត និងការចូលរួមការងារក្នុងគណៈកម្មការមានតែក្រុមស្ត្រីចំនួន ០៤នាក់ប៉ុណ្ណោះដែលជាក្រុមស្នូល ហើយមានតួនាទីក្នុងការចូលរួមជាមួយគណៈកម្មការកន្លងមក។ សម្រាប់អ្នកផ្សេងទៀត គាត់ជាក្រុមយុវជននៅក្នុងភូមិ ឃុំ ដែលកន្លងមកបានស្ម័គ្រចិត្តក្នុងការចុះល្បាតជាមួយក្រុមស្នូល។ ក្នុងនាមជាអ្នកស្ម័គ្រចិត្តក្នុងការងារមួយនេះ ពេលវេលាកន្លងមកក្រុមស្ត្រី បានចូលរួមក្នុងការចុះល្បាតនៅក្នុងព្រៃអភិរក្សរបស់សហគមន៍ ដែលការចុះល្បាតត្រូវបានរៀបចំឡើង បីដងក្នុងមួយខែ ដោយការឆ្លាស់វេនគ្នា។

ការចុះទៅល្បាត ដើម្បីទៅមើលអំពីស្ថានភាព និងការពារព្រៃឈើ និងសត្វព្រៃពីការដាក់អន្ទាក់ និងកាប់ព្រៃ។ នាពេលបច្ចុប្បន្ននេះ ការរៀបចំអោយមានវេនចុះល្បាតមានសមាសភាព ០៤រូប ប្រុស០២រូប ស្រី០២រូប ដែលជាគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ លើសពីនោះ អាចមាន ប្រជាពលរដ្ឋដែលគាត់ស្ម័គ្រចិត្ត អាជ្ញាធរភូមិ ឃុំ ចូលរួមផងដែរ។

## ការចូលរួមនិងការផ្លាស់ប្តូរជាវិជ្ជមាន

ការងារស្ម័គ្រចិត្តជាការងារមួយដែលយើង ត្រូវចំណាយទាំងពេលវេលា កម្លាំង និង ធនធាន ដើម្បីចូលរួមក្នុងការធ្វើ  អ្វីមួយជាប្រយោជន៍រួម ឬជួយអ្វីមួយដល់សហគមន៍អោយ ប្រសើរឡើង។ ការចូលរួមរបស់ក្រុមស្ត្រីនៅក្នុងគណៈកម្មការសហគមន៍អភិរក្សធនធានធម្មជាតិ និងការចូលរួមការងារស្ម័គ្រចិត្តជាក្រុមស្ត្រី បានធ្វើអោយពួកគាត់ក្លាយជាគំរូភាព របស់សហគមន៍ ដែលគាត់មានភាពជាអ្នកដឹកនាំ សកម្មក្នុងការងារ និងជាផ្នែកមួយជួយដល់ការការពារធនធាន ធម្មជាតិ នៅក្នុងសហគមន៍របស់ពួកគាត់ ដែលវាអាចឆ្លុះបញ្ចាំងបានថា សហគមន៍មានការគាំទ្រ លើការចូលរួមរបស់មនុស្សស្រី ក្នុងការងារជាអ្នកអភិរក្ស ឬជាគណៈកម្មការនៅក្នុងសហគមន៍។ គ្រួសារក៏ជាផ្នែកមួយដ៏សំខាន់ ក្នុងការបំពេញកម្លាំងចិត្ត ដែលធ្វើឲ្យស្ត្រី មានការចូលរួមមួយ យ៉ាងពេញលេញ ជាមួយការលើកទឹកចិត្ត និងគាំទ្រក្នុងការបន្តការងាររបស់គាត់។ មួយវិញទៀត ការចូលរួមលើកទឹកចិត្ត និងការផ្តល់ឱកាស ពីក្រុមក៏ជាសកម្មភាព ដែលធ្វើអោយការចូលរួម របស់ស្ត្រី កាន់តែមានប្រសិទ្ធភាពផងដែរ។ ជាក់ស្តែង ក្រុមស្ត្រីរបស់យើងបានចែករំលែកថា "សហគមន៍គ្មានការរើសអើង លើការចូលរួមរបស់ពួកយើងទៀតទេ គេមានតែសរសើរ ថាយើង មានឱកាសច្រើន ក្លាហាន និងមានការផ្លាស់ប្តូរច្រើន តាំងពីចូលរួមការងារស្ម័គ្រចិត្តមក។ ហើយ សហគមន៍ គាត់យល់ថា ការងារដែលយើងកំពុងធ្វើ គឺបានជួយក្នុងការការពារធនធានធម្មជាតិ។ បើគ្រួសារវិញ គាត់ផ្តល់ឱកាសអោយរហូតហ្នឹង មិនជំទាស់នោះទេ មានតែជូន ចុះឡើងប្រជុំ នៅខេត្តទៀតផង ព្រោះផ្លូវឆ្ងាយ ហើយពិបាកខ្លាំងទៀត។ គណៈកម្មការពួកយើងផ្តល់ឱកាស អោយគ្នារហូតហ្នឹង ទាំងការចូលរួមប្រជុំ និងការចុះល្បាត"។ ទន្ទឹមហ្នឹងដែរក្រុមស្ត្រី បានបន្តថា "ពេលខ្លះក៏ហត់ដែរព្រោះ យើងមានតួនាទីជាម្តាយផង ជាប្រពន្ធផង ទោះជាយ៉ាងណា ក៏ត្រូវ រ៉ាប់រងបន្ទុកការងារផ្ទះ ច្រើនជាងបុរសដែរ។  ការងារជាគណៈកម្មការ និងការងារចុះល្បាតក៏មិន ងាយស្រួលដែរ តែយ៉ាងណាក៏មិនធ្លាប់ចង់បោះបង់ដែរ"។ ក្នុងនោះ លោកស្រី យួន ណាន បន្ត ថា "តាំងពីចូលរួមជាមួយក្រុមស្ត្រីមក ខ្ញុំមិនធ្លាប់ចង់បោះបង់នោះទេ ព្រោះក្នុងការចូលរួមមួយ នេះ ខ្ញុំបានផ្លាស់ប្តូរច្រើន..."។

នៅក្នុងការចូលរួមជាក្រុមស្ត្រី និងជាក្រុមស្នូលនៃគណៈកម្មការសហគមន៍អភិរក្ស ក្រុមស្ត្រីទទួលបានឱកាស ចូលរួម ក្នុងការកសាងសមត្ថភាព សិក្ខាសាលា វេទិកានៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ជាមួយអង្គការសីលការ និងអង្គការជាដៃគូក្នុងគម្រោង បរិយាបន្នខ្សែច្រវ៉ាកតម្លៃកសិកម្ម និងកិច្ចប្រជុំជាលក្ខណៈក្រុម ឬគណៈកម្មការ។ នៅក្នុងការចូលរួមអស់រយៈពេលជាងមួយឆ្នាំមកនេះក្រុមស្ត្រី មានការផ្លាស់ប្តូរជាច្រើន ទាំងទំនុកចិត្ត ភាពក្លាហាន និងការទំនាក់ទំនង។ តាមរយៈវឌ្ឍនៈភាពជាវិជ្ជមាននេះ លោកស្រី សែន ស៊ីផុន លើកឡើងថា “ ពេលបានចូលរួម មានការលើកទឹកចិត្តពីអ្នកគ្រូ ខ្ញុំអាចទៅនិយាយជាមួយស្ត្រីផ្សេងទៀតក្នុងភូមិឱ្យគេចេះចែករំលែកបញ្ហា រកដំណោះស្រាយ ជួយផ្តល់យោបល់ឱ្យគ្នា នាំឱ្យស្ត្រីមានភាពស្និតស្នាលចែករំលែកចំណេះដឹងដល់គ្នាទៅវិញទៅមក”។ ចំណែក លោកស្រី ញុយ សុខា បានចូលរួមថា “ចេះរាក់ទាក់ ស្និតស្នាលជាមួយអ្នកផ្សេង សប្បាយចិត្ត បានចូលរួមសិក្ខាសាលា នៅភូមិ នៅខេត្ត នៅថ្នាក់ជាតិដែលពីមុនមិនធ្លាប់បានដឹង។ បានរៀនមេរៀនដែល មិនដែលបានដឹងពីមុន។ មេរៀននីមួយៗខ្ញុំបានរៀនពីសិក្ខាសាលា បានយកទៅចែករំលែកវិញក្នុងភូមិនូវមេរៀនណាដែលខ្ញុំចេះចាំ”។ លោកស្រី យូន ណាន លើកឡើងថា “...ចេះពីរបៀបនិយាយ ក្លាហាននិយាយជាងមុនបានច្រើន កាលទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាល លើកទីមួយនៅភ្នំពេញ ពេលនោះមានឱកាសបាននិយាយ ខ្ញុំបានឡើងនិយាយដែរ ខ្ញុំរំភើប ឡើងយំ ខ្ញុំចង់ក្លាហានដូចគេដែរ កាលនោះមានអារម្មណ៍ថាខ្ញុំអស្ចារ្យណាស់។ ក្រោយមកខ្ញុំក៏ចេះនិយាយ ខ្ញុំមិនសូវអៀនខ្មាសទៀតនោះទេ”។ ទាំងនេះជាការរីកចម្រើនមួយ ដែលឆ្លើយតបទៅ ហ្នឹងតម្រូវការដែលក្រុមស្ត្រីធ្លាប់ចង់ពង្រឹងបន្ថែម។

## វឌ្ឍនៈភាពនៃការផ្លាស់ប្តូរលើបញ្ហា និងតម្រូវការ

ក្នុងការសម្របសម្រួលការងារផ្ទាល់ និងជំនួយជាបច្ចេកទេសពីអង្គការជីវិតធម្មជាតិនៅកម្ពុជា បានធ្វើអោយកង្វល់ និងតម្រូវការមួយចំនួនបានឆ្លើយតប។ តាមរយៈនេះផងដែរ គណៈកម្មការសហគមន៍ក៏ទទួលបាន ការគាំទ្រជា សម្ភារៈល្បាត ដូចជាស្បែកជើង អាវភ្លៀង ឯកសណ្ឋាន តង់ និងសម្ភារៈសង្គ្រោះបឋម ជាដើម។ ចំណែកឯកិច្ចសន្យារវាងក្រុមហ៊ុនចំការចេក ដែលជាប់ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិអូររ៉ៃ និងគណៈកម្មការសហគមន៍ បានកត់ត្រាឡើងមានបួនចំណុច ដែលក្រុមហ៊ុនចំការចេក ថាហ្នឹងផ្តល់ជូនដល់សហគមន៍។ មកដល់ពេលនេះ តាមរយៈការជម្រុញ និងការជជែករបស់ក្រុមគណៈកម្មការ បានធ្វើអោយក្រុមហ៊ុន បានអនុវត្តន៍លើសន្យាមួយ ៩ ទៀត គឺការ ជីកប្រឡាយ ដែលជាប់ព្រំប្រទល់

រវាងក្រុមហ៊ុន និងដីសហគមន៍ លើចំណុចនេះ តំណាងក្រុមស្រ្តី ម្នាក់បានលើកឡើងថា "ក្រុមហ៊ុនមិនទាន់បានអនុវត្តន៍តាមសន្យា ទាំងអស់នោះទេ។ ក្រុមហ៊ុនបានជីកតែប្រឡាយស្របបង្គោលភ្លើង តែការជីកក៏មិនទាន់ហើយដែរ"។ ការសន្យាដែល ក្រុមហ៊ុនបានជជែកគ្នាជាមួយគណៈកម្មការសហគមន៍ មានជាកំណត់ហេតុកត់ត្រាបានត្រឹមត្រូវ ដោយលោកស្រី សែន ស៊ីផុន ក៏បានបន្តថា "សន្យាមានលាយលក្ខអក្សរដែរប៉ុន្តែក្រុមហ៊ុនមិនគោរពតាម"។ នៅក្នុងឆ្នាំ២០២៤ នេះខាងគណៈកម្មការក៏ធ្លាប់ជួបប្រជុំជាមួយក្រុមហ៊ុនដែរ ដើម្បីជជែកពីរឿងដែលក្រុមហ៊ុនបានសន្យានៅក្នុងកំណត់ហេតុនោះ និងធ្លាប់ជួបពេលត្រូវប្រគល់លុយ សម្រាប់សំណង់នៃការធ្វើស្ថានីយបូមទឹក លើដីរបស់ហគមន៍ ដែលសហគមន៍ត្រូវទទួលបាន ៣០០ដុល្លារ ក្នុងមួយខែ។ លោកស្រី សែន ស៊ីផុន បានលើកឡើងថា "ពេលទៅទទួលលុយនោះ ខ្ញុំក៏បានទៅដែរ តែការទទួលនោះជាលុយឆ្នាំ២០២៤ទេ សម្រាប់២០២៥ មិនទាន់បាននោះទេ។ ក្នុងការជជែកគ្នាក្រុមហ៊ុនត្រូវអោយ ក្នុងខែមករា ជារៀងរាល់ឆ្នាំ ប៉ុន្តែមកដល់ពេលនេះ ក្រុមហ៊ុនមិនទាន់ហៅខាងគណកម្មការទៅទទួលនោះទេ"។ បើនិយាយពីភាពប្រសើរឡើងនៃការទុកដាក់កាកសំណល់ និងសម្រាមរបស់ក្រុមហ៊ុន ឃើញមានភាពល្អប្រសើរឡើង តាមរយៈការលើកឡើងរបស់ក្រុមស្រ្តី "ដោយក្រុមហ៊ុនមានកន្លែងដាក់សម្រាមបានត្រឹមត្រូវ ទល់តែទឹកជនខ្លាំង ទើបឃើញកំប៉ុងថ្នាំតិចតួចចូលទៅក្នុងទន្លេស្រែពក"។ ទោះជារឿងរ៉ាវដែលបានលើកឡើងខាងលើ មិនទាន់ដល់ការរំពឹងទុករបស់ក្រុមគណៈកម្មការក៏ដោយ តែនេះជាស្ថានភាពវិជ្ជមានមួយ ដែលកើតចេញពីស្មារតី នៃការធ្វើការងារជាក្រុម របស់ក្រុមគណៈកម្មការសហគមន៍។

លើសអំពីការបង្ហាញ ពីវឌ្ឍនៈភាពនៃការផ្លាស់ប្តូរលើបញ្ហា និងតម្រូវការដែលក្រុមស្រ្តីធ្លាប់បានលើកឡើង និងការធ្វើបច្ចុប្បន្នភាពលើស្ថានភាព ដែលបានហ្នឹងកំពុងកើតមានសម្រាប់ក្រុមស្រ្តី និងគណៈកម្មការអភិរក្សសហគមន៍ដែលក្រុមស្រ្តីបានចូលរួម ក្រុមស្រ្តីក៏បានលើកឡើងនៅតម្រូវការមួយចំនួនបន្ថែមទៀត។ បន្ទាប់ពីការជជែកគ្នាជាលក្ខណៈក្រុម អំពីតម្រូវការដើម្បីជួយក្នុងការដោះស្រាយ លើបញ្ហា និងស្ថានភាពដែលក្រុមស្រ្តីបានលើកឡើងខាងលើ ក្រុមស្រ្តីបានលើកឡើងថា "ពួកខ្ញុំចង់អោយក្រុមហ៊ុនគោរពតាមសន្យាដែលមានចំពោះគណៈកម្មការសហគមន៍ និងចង់អោយអាជ្ញាធរភូមិ ឃុំជួយក្នុងការដោះស្រាយលើរឿងនេះ។ សម្រាប់អង្គការសង្គមស៊ីវិលចង់អោយ មានជាវគ្គបណ្តុះបណ្តាល អំពីសិទ្ធិស្រ្តី កិច្ចប្រជុំ សិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធ និងបន្តជួយលើការសម្របសម្រួលជាមួយក្រុមស្រ្តីបន្ថែមទៀត"។

# ដំណើរការនៃការចងក្រងសាច់រឿងរបស់ក្រុមស្ត្រី តាមរយៈការប្រើប្រាស់ឧបករណ៍ “របៀបវារៈយុត្តិធម៌សេដ្ឋកិច្ចបែបហ្វេមមីនីស”



SILAKA

OXFAM